ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមបុគ្គលិកសិក្សាខ្មែរ

រាជរដ្ឋាភិបាលកម្ពុជា

កម្មវិធីទ្រទ្រង់ផ្នែកអប់រំនៅកម្ពុជា
ឧបត្ថម្ភដោយគណៈកម្មការអឺរ៉ុប

# ទស្សនាវដ្តី គ្រូបង្រៀន

លេខ ១០




ខែ មករា - កុម្ភៈ - មីនា ឆ្នាំ ២០០០

ផ្សាយចេញរាល់ត្រីមាស ពីទីចាត់ការសមាគមបុគ្គលិកសិក្សាខ្មែរ

១២៨ មហាវិថីព្រះនរោត្តម ( ភ្នំពេញ )

ទូរស័ព្ទ : ០១៥ ៩១៨ ១២៤

**គណៈកម្មការតំរង់ទិស-អំណាន និង តាមដាន**

| | | |
|---|---|---|
| ១- លោក | យ៉ង់ ធី | ប្រធាន |
| ២- លោក | ណាត ប៊ុណ្ណឿន | សមាជិក |
| ៣- លោក | ធ សោ | - |
| ៤- លោក | អ៊ុម កុច | - |
| ៥- លោក | ជា ជាតិ | - |

## សេចក្តីអំពាវនាវ

គណៈកម្មាធិការនាយក ស.ប.ស.ខ មានមនោសញ្ចេតនារីករាយជំរាបអស់លោក ជាបុគ្គលិកសិក្សាទាំងអស់ថា ទស្សនាវដ្តីគ្រូបង្រៀន បានចាប់ចេញផ្សាយពីលេខ ១០ នេះតទៅ ក្រោយពីខកខានអស់រយៈពេល ១ ឆ្នាំកន្លងមក ។ យើងខ្ញុំសូមអំពាវនាវចំពោះលោកគ្រូ-អ្នកគ្រូ សូមមេត្តាជួយទស្សនាវដ្តីគ្រូបង្រៀន ដោយស្ម័គ្របញ្ចេញមតិយោបល់ទៅលើការអប់រំក្នុងប្រទេស និងក្រៅប្រទេស ដើម្បីចែកជូនបុគ្គលិកសិក្សាយើង បានក្រេបជញ្ជក់ចំនេះដឹងថ្មី ពត៌មានថ្មី ក្នុងគោលបំណងលើកកំពស់ពុទ្ធិទូទៅ និងវិជ្ជាជីវៈនៃអ្នកអប់រំដែលមានភារកិច្ចផ្ទេរចំនេះដឹងទៅអោយយុវជនជំនាន់ក្រោយ ។

យើងខ្ញុំសង្ឃឹមយ៉ាងមាំថា អស់លោកនឹងធ្វើវិភាគទានផ្ដែកបញ្ញា ជូនចំពោះសហសេវិក-វិកាទូទាំងប្រទេស ។

សូមអរគុណទុកជាមុន ។

## មាតិកាអត្ថបទ


ទំព័រ

**១-វិចារណកថា**

**២-ព័ត៌មានពីសមាគមបុគ្គលិកសិក្សាខ្មែរ**

- សេចក្តីសំរេចនៃមហាសន្និបាតវិសាមញ្ញ ថ្ងៃ ១៤-០១-២០០០
- សេចក្តីថ្លែងអំណរគុណចំពោះសមាជិក-សមាជិកា ដែលបានគាំទ្រផែនការ ៥ ឆ្នាំនៃការសាងសង់ផ្ទះគ្រូបង្រៀន

**៣-វប្បធម៌ទូទៅ-ការអប់រំ**

- មនុស្សនិងតំលៃមនុស្ស
- វប្បធម៌
- ការសន្ទនារវាងលោក ក និងលោក ខ
- ការគោរពអ្នកដទៃ
- អំពីសករាជ
- ទោចយំ

**៤- គរុកោសល្យ**

- គោលវិធីមនុស្សនិយម
- ការសិក្សាបុរេប្រវត្តិសាស្ត្រខ្មែរ
- លទ្ធផលសរុបនៃការជំរឿនប្រជារាស្ត្រ
- ដំនោះស្រាយចំនោទនៅបឋមសិក្សា
- អំពីម៉ោងបង្រៀន និង រៀនពិត
- កម្មវិធីបុរេវិជ្ជាជីវៈ

**៥- វេទិកាសេរី**

- លិខិតចំហជូនចំពោះសមាជិកា-សមាជិកា ស.ប.ស.ខ
- តើប្រព័ន្ធសាលារៀនសម្ព័ន្ធមេត្រីជាអ្វី ?
- កំនើតពុម្ពអក្សរ និង ការបោះពុម្ព
- កុមារី គ្រេន សុខនី ទទួលរង្វាន់លេខ ១ នៅប្រទេសជប៉ុន



ទស្សនាវដ្តីនេះ បោះពុម្ពដោយមានការរួមចំណែកជាបច្ចេកទេស និង ហិរញ្ញវត្ថុ
ពីកម្មវិធីទ្រទ្រង់ផ្នែកអប់រំបឋមសិក្សានៅកម្ពុជារបស់សហគមន៍អឺរ៉ុបទី II
Revue publiée avec le concours technique et financier du Programme d'Appui au Secteur de l'Education Primaire au Cambodge (PASEC II) de l'Union Européenne.

# វិចារណកថា

ប្រជាជាតិនីមួយៗ រីកចំរើនទៅបាន អាស្រ័យការអប់រំ ។ ប្រសិនបើវិស័យនេះមិនមានការលូតលាស់ទេនោះ ប្រទេសជាតិច្បាស់ជាមិនមានការអភិវឌ្ឍជាដាច់ខាត ។ គេតែងពោលថា " ការអប់រំជាកូនសោនៃការអភិវឌ្ឍន៍ជាតិ " ។

ទស្សនៈនេះមានអត្ថន័យជ្រាលជ្រៅណាស់ ចំពោះអ្នកនយោបាយ អ្នកដឹកនាំប្រទេស និងប្រជាពលរដ្ឋទូទៅ ។ យកចិត្តទុកដាក់លើវិស័យអប់រំ គឺខ្វល់ខ្វាយរកវិធីសោះស្រាយឧបសគ្គ ដែលរាំងស្ទះដំណើរការរីកចំរើន ពោលគឺមានឧត្តមគតិខ្ពស់ ចំពោះវិស័យអប់រំ និងគិតដល់វាសនាអនាគតប្រទេសជាតិ ។ នៅពេលណាដែលវិស័យអប់រំត្រូវបានមើលស្រាល រឺយកចិត្តទុកតែរូបភាពនោះ ប្រទេសជាតិនឹង មិនមានដំណើរវិវត្តន៍ ទាំងផ្នែកសេដ្ឋកិច្ច និង ផ្នែកបញ្ញាឡើយ ។

គណៈកម្មការអន្តរជាតិ ទទួលបន្ទុកការងារអប់រំសំរាប់សតវត្សរ៍ទី ២១ [១] ដែលមានលោក ហ្សាក ដឺល័រ ( Jacques Delors ) ជាប្រធាន, បានពោលអះអាងថា « កំណប់ទ្រព្យកប់នៅក្នុងការអប់រំ » ។ ខ្មែរយើងបានពោលថា « ចំនេះវិជ្ជាជាទ្រព្យស្រួលទុក ស្រួលដាក់ ហើយចោរលួចយកមិនបាន » ។ ដូចនេះ យើងត្រូវយល់ថា ការអប់រំអាចអភិវឌ្ឍមនុស្សផង និង សង្គមផង ។ ការអប់រំជា មធ្យោបាយសំរាប់អភិវឌ្ឍធនធានមនុស្ស អោយកាន់តែល្អប្រសើរ មានគុណភាព មានសមត្ថភាព ដើម្បីជួយកាត់បន្ថយភាពក្រីក្រ និងលើកកំពស់ជីវភាពសង្គម ។

រដ្ឋាភិបាលសេដ្ឋកិច្ច និងប្រជាពលរដ្ឋ កំពុងតែខិតខំអោយមានកំណើនសេដ្ឋកិច្ច ដើម្បីអោយមានកិរិតរីកចំរើន ប្រហាក់ប្រហែល នឹងប្រទេសជឿនលឿននានានៅក្នុងតំបន់ ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលថ្មី ដែលមានបំណងចង់អោយប្រជាពលរដ្ឋគ្រប់រូបមានជីវភាពរស់នៅសមរម្យ នឹងថ្លៃថ្នូរ ។ ទន្ទឹមនឹងការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ការអភិវឌ្ឍន៍ធនធានមនុស្ស ដែលជាបញ្ហា គន្លឹះត្រូវដើរទៅជាមួយគ្នា ។ យើងគួរយល់ដឹងពី :

១- ស្ថានភាពបច្ចុប្បន្ននៃការវិវត្តន៍សង្គម-សេដ្ឋកិច្ចនៃ ប្រទេសយើងជាមុនសិន តើវាមានទំនាស់ រឺឥទ្ធិពលមកលើការសិក្សាដែររឺទេ ?

២- ស្ថានភាពបច្ចុប្បន្ននៃការអប់រំ ដើម្បីឆ្លុះបញ្ចាំងអោយឃើញតថភាពជាក់ស្តែងនៃការអប់រំ គឺឃើញចំនុចខ្លាំង ចំនុចខ្សោយ ។

៣- យុទ្ធវិធី ដើម្បីដោះស្រាយបញ្ហាប្រឈមមុខនៅពេលអនាគត ។

ទស្សនៈរបស់ខ្ញុំខាងលើនេះ ជាវិភាគទានដើម្បីរួមចំណែកកសាងវិស័យអប់រំអោយបានរីកចំរើន ។ យើងទាំងអស់គ្នាយល់ថា ការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច នឹងសំរេចទៅបានដោយសារមនុស្ស ។ មនុស្សមានចំណេះដឹងជ្រៅជ្រះ មានសមត្ថភាពជំនាញ មានចរិយាធមិ និងគុណធមិ គឺជាធនធានមួយដ៏សំខាន់សំរាប់ប្រទេសជាតិ ។

ដើម្បីសំរេចការអភិវឌ្ឍន៍ធនធានមនុស្សទៅតាមទិសដៅកំនត់ ខ្ញុំសូមអំពាវនាវដល់គ្រប់មជ្ឈដ្ឋានសង្គមៈ គ្រួសារ-សាលារៀន-សមូហភាព សូមអោយមានការប្រយុទ្ធរួមគ្នា (même combat) និងសូមអោយមានសេចក្តីសង្ឃឹមទៅលើអនាគតកាលនៃប្រទេសកម្ពុជា ។

---

(១) - របាយការណ៍របស់គណៈកម្មការនេះ ជូនទៅអង្គការ UNESCO ឆ្នាំ ១៩៩៦




## សេចក្តីសំរេចនៃមហាសន្និបាតវិសាមញ្ញ
## នាថ្ងៃ ១៤-០១-២០០០ សំរាប់ការអនុវត្តន៍

* * *

ខ្ញុំសូមលោកប្រធាន ស.ប.ស.ខ គ្រប់ខេត្ត-ក្រុង មេត្តាផ្សព្វផ្សាយសេចក្តីសំរេចនៃមហាសន្និបាត ដែលមានខ្លឹមសារដូចខាងក្រោម ហើយសូមខិតខំអនុវត្តអោយបានត្រឹមត្រូវ និងម៉ត់ចត់ ក្នុងគោលបំនងជៀសវាងការទិតៀនពីសមាជិក-សមាជិកានៃសមាគម ។

ដូចអស់លោកបានជ្រាបហើយថា អង្គមហាសន្និបាតយើង បានសំរេចជាឯកច្ឆ័ន នូវបញ្ហាដ៏សំខាន់ពីរគឺ :

១- ផែនការ ៥ ឆ្នាំនៃការសាងសង់ផ្ទះគ្រូបង្រៀនជំហានទី ១ និងទី ២

២- ការបង្កើនប្រាក់គរុមរណបូបត្ថម្ភ

ដើម្បីអនុវត្តសេចក្តីសំរេចនេះអោយមានតម្លាភាព ទំនុកចិត្តលើសេចក្តីស្មោះត្រង់ពីគណៈកម្មាធិការ ស.ប.ស.ខ ខេត្ត-ក្រុង ខ្ញុំសូមលោកប្រធានធ្វើបញ្ជីមួយដូចគំរូជូនភ្ជាប់ ។ ប្រាក់ភាគទាន ៣០០រ ក្នុងមួយខែនឹងត្រូវប្រមូលចាប់ពីខែ កុម្ភៈ ឆ្នាំ ២០០០ តទៅ ហើយផ្ញើទៅតំកល់ទុកនៅគណៈកម្មាធិការនាយក ដើម្បីប្រមូលទុកក្នុងគណនីថ្មីនៅធនាគារភ្នំពេញ ។

រីឯប្រាក់គរុមរណបូបត្ថម្ភ ដែលត្រូវបង្កើននោះ អង្គមហាសន្និបាតបានសំរេចអនុវត្ត ចាប់ពីម៉ោង ០ ថ្ងៃទី ០១ ខែ កុម្ភៈ ២០០០ តទៅ ។ ចំពោះបញ្ហានេះ ខ្ញុំសូមលោកប្រធានផ្សព្វផ្សាយដោយស្នើសុំសមាជិក-ជិកា កុំអោយមានចិត្តលោភលន់ នាំអោយខូចកិត្តិយសជាបុគ្គលិកសិក្សា ។ ប្រាក់គរុមរណបូបត្ថម្ភត្រូវបានកំរិតដូចតទៅ :

ក- ១.៥០០.០០០ រៀល ចំពោះសមាជិកម្នាក់អនិច្ចកម្ម ។

ខ- ១.៥០០.០០០ រៀល ចំពោះសមាជិកដែលរាជការបញ្ឈប់ដោយហេតុ ឆ្កួត ខ្វាក់ទាំងសងខាងនិងខ្វិន ក្នុងករណីដែលធ្វើការមិនកើត

គ- ៧៥០.០០០រ ចំពោះភរិយាទី ១ រឺស្វាមីពេញច្បាប់របស់សមាជិកអនិច្ចកម្ម ។

ឃ- បើស្វាមី-ភរិយាជាសមាជិកទាំងពីរនាក់ ហើយទទួលមរណភាពក្នុងពេលជាមួយគ្នា សាមីជនត្រូវទទួល

អំណោយរៀង១ខ្លួន ២.២៥០.០០០៛ គឺ :

- ១.៥០០.០០០៛ ក្នុងឋានៈជាសមាជិក
- ៧៥០.០០០៛ ក្នុងឋានៈជាប្ដី រឺ ប្រពន្ធសមាជិក ។

ង- បើស្វាមី-ភរិយាជាសមាជិកទាំងពីរនាក់ ហើយអ្នកណាម្នាក់ទទួលមរណភាពនោះ ត្រូវទទួលជំនួយគឺ:

២.២៥០.០០០៛ :

- ១.៥០០.០០០ ៛ ក្នុងឋានៈជាសមាជិក
- ៧៥០.០០០ ៛ ក្នុងឋានៈប្ដី រឺ ប្រពន្ធសមាជិក

ជាមួយគ្នានេះដែរ ខ្ញុំសូមផ្ដាំផ្ញើសាជាថ្មីម្ដងទៀត ចំពោះគណៈកម្មាធិការ ស.ប.ស.ខ គ្រប់ខេត្ត-ក្រុង សូមមេត្តាជួយ :

១- ពង្រឹងយន្តការគ្រប់គ្រងសមាគមលើផ្នែករដ្ឋបាល និងហិរញ្ញកិច្ចអោយកាន់តែល្អប្រសើរ ។

២- ផ្សព្វផ្សាយអោយបុគ្គលិកសិក្សា ដែលទើបចេញទៅបំរើការថ្មី បានយល់ជ្រួតជ្រាបពីស្មារតីសាមគ្គីភាពក្នុងការជួយគ្នាទៅវិញទៅមក ។ ក្នុងករណីដែលគេមិនស្ម័គ្រចូលជាសមាជិក ស.ប.ស.ខ ទេនោះ យើងក៏មិនត្រូវបង្ខំគេឡើយ ។ យើងបានពិភាក្សាគ្នា ស៊ីជំរៅ រួចហើយអំពីបញ្ហានេះ ក្នុងពេលមហាសន្និបាត ។

ខ្ញុំមានជំនឿដ៏មុតមាំលើវឌ្ឍនការរបស់សមាគមយើងទៅអនាគត និងសង្ឃឹមថាអស់លោកនឹងគំកល់ចិត្តថ្លើមជាគ្រូ ហើយជួយគ្រូទៅវិញទៅមក ។

យ៉ង់ ធី

# សេចក្តីថ្លែងអំណរគុណ

តាងនាមគណៈកម្មាធិការនាយក ស.ប.ស.ខ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅជាទីបំផុត ចំពោះគណៈកម្មាធិការ ស.ប.ស.ខ គ្រប់ខេត្ត-ក្រុង និងចំពោះសមាជិក-សមាជិកាសមាគមទូទាំងប្រទេស ដែលមានមតិយោបល់ស្របនិងសេចក្តីអំពាវនាវរបស់គណៈកម្មាធិការនាយក ក្នុងការអនុវត្តផែនការ ៥ ឆ្នាំ នៃការកសាងសង់ផ្ទះគ្រូបង្រៀន នៅដំណាក់កាលទី ១ និងទី ២ ។ មហាសន្និបាតវិសាមញ្ញ នាថ្ងៃទី ១៤-០១-២០០០ ដែលមានសមាជិក-សមាជិកា ១១០ នាក់ចូលរួម បានអនុម័តគាំទ្រ ១០០ % នៃផែនការ ។ នេះជាសក្ខីភាពបង្ហាញនូវសាមគ្គីធមិពិត; បានសេចក្តីថា ព្រមព្រៀងគ្នា ស្រុះស្រួលគ្នា ទាំង ៧៩.៨៥១ នាក់ (សមាជិកសរុប) ។

នេះជាមោទនភាពនៃអង្គគ្រូបង្រៀនយើង ។ សមិទ្ធផលសំរេចបានពីសាមគ្គីធមិនេះ នឹងអាចឃើញនៅដំណាច់ឆ្នាំ ២០០០ នូវអគារមួយខ្នង មានទំហំ ៤៤ម × ៧ម ដែលស្ថិតក្នុងបរិវេណសាលាគរុកោសល្យ និង វិក្រឹតការខេត្ត សៀមរាប ។

ជាថ្មីម្តងទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះសមាជិក-សមាជិកា ស.ប.ស.ខ ទូទាំងប្រទេស និងសូមជូនពរសុខភាពល្អ និងជ័យជំនះលើគ្រប់ភារកិច្ច កសាងវប្បធមិជាតិ ។

ភ្នំពេញ, ថ្ងៃទី ២៦ មករា ២០០០

ជ.គណៈកម្មាធិការនាយក

ប្រធាន

ហត្ថលេខានិងត្រា យ៉ង់ ធី




# មនុស្ស និង តំលៃមនុស្ស

## I- <u>សារជាតិរបស់មនុស្ស</u> (The nature of man)

យើងតែងចោទសួរថា អ្វីទៅដែលហៅថាមនុស្ស ? នេះជាសំនួរមួយក្នុងចំនោមសំនួរទាំងឡាយដែលមានសារៈសំខាន់បំផុត ។ បញ្ហាផ្សេងៗជាច្រើនទៀតដែលផ្អែកលើទស្សនៈរបស់យើង ស្តីពីធម្មជាតិ រឺសារជាតិរបស់មនុស្ស សុទ្ធសឹងទាក់ទងនឹងសំនួរនេះ ។ ន័យ និងគោលបំណងនៃជីវិតមនុស្ស គឺជាអ្វីដែលយើងត្រូវបំពេញ និងជាអ្វីដែលយើងអាចសង្ឃឹមថា យើងនឹងសំរេចបាន ។ កត្តាទាំងអស់នេះ ទាក់ទងជាមួយនឹងការគិតត្រូវអំពីសារជាតិរបស់មនុស្ស ។

ចំពោះធម្មជាតិនៃមនុស្សនេះ ទស្សនៈជាច្រើនបានលើកឡើងតាមបែបផ្សេងៗគ្នា ។ នៅទីនេះ យើងនឹងលើកយកទស្សនៈនៃទស្សនវិទូមួយចំនួនមកពិចារណាដូចតទៅ :

**១-<u>កាល់ម៉ាក</u>** (Karl Marx) ពុំយល់ថា អាទិទេពបង្កើតមនុស្សទេ តែលោកអះអាងថា " ធម្មជាតិពិតរបស់មនុស្ស គឺភាពសរុបនៃទំនាក់ទំនងសង្គម " (The real nature of man is the totality of social relations) ។

**២-<u>តូម៉ាស់ ហូប</u>** (Thomas Hobbes) យល់ថា " បើតាមធម្មជាតិរបស់មនុស្ស មនុស្សពុំមែនជាសត្វចេះធ្វើនយោបាយទេ តែជាអត្តទត្ថបុគ្គល អានាធិបតេយ្យដែលមានបំនងពោរពេញទៅដោយសេចក្តីលោភលន់ ព្រោះប្រសិនបើគេអាចប្រព្រឹត្តទៅបាន គេនឹងកំទេចរដ្ឋ និងសង្គមដោយប្រើសង្គ្រាមស៊ីវិលយ៉ាងឃោរឃៅ ... ។ ស្ថិតនៅក្រោមច្បាប់មេកានិច, កិរិយាមារយាទរបស់មនុស្ស តែងតែត្រូវជាប់នឹងកំនត់និយម ទោះបីនៅក្នុងល្អងរូបធាតុណាមួយក៏ដោយ (L'homme n'est pas, de par sa nature, un animal politique, mais un égoïste anarchique dont les désirs ambitieux, s'ils pouvaient se réaliser, détruiraient, l'Etat et la société au cours d'une sanglante guerre civile... Soumis aux lois de la mécanique, leur conduite est sujette au même déterminisme que celle de n'importe quelle particule matérielle) ។ ប៉ុន្តែលោកបានបញ្ជាក់ថា ដើម្បីរស់នៅជាមួយគ្នា មនុស្សត្រូវបង្កើតកិច្ចសន្យាសង្គមមួយ ។

គឺកិច្ចសន្យាសង្គមនេះហើយ ដែលអាចទប់ស្កាត់កុំអោយមានសង្គ្រាមរវាងមនុស្ស និងមនុស្ស ។

**៣-ហ្សង់ហ្សាក់រូស្សូ** (Jean Jacques Rousseau) មានទស្សនៈផ្ទុយស្រលះពីតូម៉ាស់ហូប ។ រូស្សូពោលថា " មនុស្សពីធម្មជាតិល្អ តែសង្គមទេ ដែលធ្វើអោយមនុស្សពុករលួយ " (L'homme est naturellement bon, mais la société le corrompt) ។ ប៉ុន្តែ លោកបញ្ជាក់បន្ថែមថា " ស្គាល់ច្បាស់ថាមនុស្សល្អពីធម្មជាតិ គឺគ្រាន់តែជាការលួងលោមមួយដែលគ្មានតំលៃ ប្រសិនបើប្រវត្តិសាស្ត្រកែប្រែមនុស្ស និងធ្វើអោយមនុស្សមានភក្ដីភាពចំពោះភាពជាខ្ញុំបំរើ (Savoir que l'homme est naturellement bon est une piètre consolation, si l'histoire le dénature et le voue à la servitude) ។ ពំនោលនេះ មានន័យថា បើសិនជាប្រវត្តិសាស្ត្រ និងសង្គមកែប្រែមនុស្សអោយខុសពីសភាពដើម ពោលគឺ មិនធ្វើអោយមនុស្ស មានលក្ខណៈជាម្ចាស់ទេ ការយល់ថា មនុស្សល្អពីធម្មជាតិ គ្រាន់តែជាការលួងលោមមួយគ្មានតំលៃអ្វីឡើយ ។

**៤-ហ្សូសេអង់តូនីញ៉ូ អាឌង់ហ្សា** (Jose Antonio Ardanza) យល់ថា " មនុស្សត្រូវបានចាត់ទុកដូចជាសត្វនិមិត្តរូប ពោលគឺ ជាភាវៈដែលមានសមត្ថភាពយល់ដឹង និងមានសមត្ថភាពជ្រួតជ្រាបទៅក្នុងភាវៈផ្ទាល់ខ្លួនក្នុងសង្គម ក្នុងពិភពលោក និងតថភាពដែលស្ថិតនៅជុំវិញខ្លួន នៅក្នុងប្រព័ន្ធនិមិត្តរូបមួយដ៏សំបូរបែប " ។ គឺប្រព័ន្ធនិមិត្តរូបនេះហើយ ដែលធ្វើអោយមនុស្សយល់ពិភពលោក និងរស់នៅក្នុងពិភពលោក ដោយឆ្លងកាត់ការប្រើភាសាជាពិសេស (L'être humain a été défini comme un animal symbolique, c'est-à-dire comme un être capable d'entendre et d'intégrer son propre être, le monde, la société et la réalité qui l'entoure dans un système symbolique pluriel. Ce système symbolique rend apte l'être humain à comprendre le monde principalement à travers la langue ) ។

**៥-ហ្វេដេរីកូ ម៉ាយើរ** (Federico Mayor) យល់ថា និយមន័យពីរយ៉ាងស្ដីពីមនុស្សដែលអារីស្តូតផ្ដល់អោយយើងថា " មនុស្សជាសត្វចេះធ្វើនយោបាយ " និង " ជាភាវៈដែលមានសម្បទាពីកំណើតខាងការនិយាយស្ដី " ធ្វើអោយយើងឈានទៅដល់តថភាពៈ ជីវិតនៅក្នុងសង្គមនឹងអាចប្រព្រឹត្តទៅបាន ប្រសិនបើការងាររួមត្រូវលើកមកជជែក វែកញែក និងដោះស្រាយដោយសារការចរចា និងការស្រុះស្រួលគ្នាដោយមិនប្រើកំលាំងបាយ (Les deux définitions que nous donnent Aristote de l'homme " animal politique " et " être doué de parole " nous renvoient vers une même réalité : la vie --- dans la société n'est possible que si les affaires en commun sont discutées et résolues grâce au dialogue et l'arrangement et non au moyen de la force) ។

**៦-អង់តុង ម៉ាការ៉ែងកូ** (Anton Makarenko) ផ្ដល់អាទិភាពយ៉ាងធំទៅលើការអប់រំ ក្នុងការបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈរបស់មនុស្ស ។ លោកយល់ថា គេអាចពត់សារជាតិមនុស្សអោយល្អ រឺ អាក្រក់ បានដោយសារការអប់រំនេះ ហើយការអប់រំល្អ រឺអាក្រក់ អាចពត់និស្ស័យពីកំណើតបាន ។

ទោះបីទស្សនវិទូ និង គរុកោសល្យវិទូទាំងឡាយបញ្ចេញទស្សនៈផ្សេងៗ អំពីសារជាតិរបស់មនុស្សក៏ដោយ ក៏យើងយល់ថា មនុស្សខុសពីសត្វ ដោយសត្វផ្អែកលើសភាវគតិជាធំ ឯមនុស្សផ្អែកលើញាណជាធំ ។ សត្វមានតែសភាវគតិប៉ុននោះ ។ មនុស្សមានសភាវគតិផង និង មានញាណផង ហើយមានតែខួរក្បាលមនុស្សទេ ដែលមានញាណនេះ ។ សម្បទា

ពីកំណើតមួយទៀត គឺមនុស្សចេះធ្វើពលកម្មផលិតសំភារៈផ្សេងៗ ចេះនិយាយ និងចេះកសាងប្រវត្តិសាស្ត្ររបស់ខ្លួន ។ កាល់ម៉ាក់ (Karl Marx) បានធ្វើការប្រៀបធៀបមនុស្ស នឹងសត្វឃ្មុំថា " ភាពខុសគ្នារវាងស្ថាបត្យករអន់ម្នាក់ និងឃ្មុំដ៏ប៉ិនប្រសប់មួយ ឋិតនៅត្រង់ស្ថាបត្យករមានប្លង់ផ្ទះនៅក្នុងខួរក្បាល មុននឹងចាប់ផ្ដើមសង់ផ្ទះនោះ " ។

## II- តំលៃរបស់មនុស្ស ( The human value )

### ១- តំលៃជាអ្វី ?

តំលៃជាអ្វី ស្ថិតនៅក្នុងមនុស្សដែលពោរពេញទៅដោយសេចក្ដីថ្លៃថ្នូរ គួរអោយរាប់អានដោយសារមនុស្សនោះមានគុណសម្បត្តិនៅក្នុងវិស័យសីលធម៌ ក្នុងបញ្ញា និងមុខរបរចិញ្ចឹមជីវិតរបស់ខ្លួន ។ គេតែងពោលថា តំលៃខ្ពស់បំផុត គឺមនុស្ស ព្រោះមនុស្សមានសមត្ថភាពគូសវាសនាខ្លួនដោយខ្លួនឯង ប្រកបដោយស្មារតីច្នៃប្រឌិតខ្ពស់ ។ តំលៃទូទៅ រឺតំលៃស្មារតី ដែលនៅក្នុងនោះមានតំលៃស្ដីពីការពិត លំអ និង កុសល គឺជាតំលៃដែលស្ដែងអោយឃើញក្នុងពេលតែមួយ នូវលក្ខណៈដែលគួរអោយចង់បាន និងគួរអោយត្រេកត្រអាល (តំលៃអត្តនោម័ត) និងលក្ខណៈសាកលដែលសមនឹងបានទទួល (តំលៃបរានុម័ត) ( La valeur en général ou valeur spirituelle, qui comprend principalement les valeurs du vrai, du beau et du bien, présentant à la fois le caractère du désiable, du délectable (valeur subjective) et le caractère de l'universel, qui mérite d'être désiré (valeur objective) ។

### ២- តំលៃរបស់មនុស្ស

មនុស្សមានតំលៃដោយសារមនុស្សមានខួរក្បាលពិសេសជាងខួរក្បាលសត្វនានា ។ វត្ថុជាក់ស្ដែងដែលត្រូវបានបញ្ជូនទៅក្នុងខួរក្បាលដោយអង្គវិញ្ញាណទាំងឡាយ ធ្វើអោយមនុស្សមានញាណ ។ គឺញាណនេះហើយ ដែលធ្វើអោយមនុស្សខ្ពស់ជាងសត្វនានា ។ ប៉ុន្តែ បើញាណនោះពោរពេញទៅដោយអំពើអសីលធម៌ បុគ្គលក៏គ្មានតំលៃដែរ ។ គេមានតំលៃ លុះត្រាតែគេមានសីលញាណ ហើយយកសីលញាណនោះទៅបំរើសង្គមមនុស្ស ។ បើគេមិនបំរើសង្គមមនុស្សទេ មានន័យថា គេមិនបំរើខ្លួនគេ ហើយគេក៏មិនមែនជាមនុស្សដែរ ។ ហ្សង់ ប៉ូលសាត្រ (Jean Paul Sartre) ពោលថា " គេមិនមែនជាមនុស្សទេ ប្រសិនបើគេមិនបានរកឃើញអ្វីមួយ ដើម្បីអ្វីដែលគេព្រមទទួលយកសេចក្ដីស្លាប់ (On n'est pas un homme tant qu'on n'a pas trouvé quelque chose pour quoi on accepterait de mourir) ។ លោកបញ្ជាក់ថា " មនុស្សជាអ្នកទទួលខុសត្រូវគ្រប់នាទី ។ គេទទួលខុសត្រូវអ្វីៗទាំងអស់ នៅចំពោះមុខអ្នកទាំងអស់គ្នា ។ គេរែកពុនទំងន់នៃពិភពលោកទាំងមូលនៅលើស្មារបស់គេ (L'homme est responsable à toute minute. Il est responsable de tout devant tous. Il porte le poids du monde entier sur ses épaules.) ។ បើតាមន័យខាងលើនេះ មុននឹងស្លាប់ទៅ មនុស្សត្រូវបំពេញករណីយកិច្ច និងកាតព្វកិច្ច ដើម្បីរួមចំណែកសងគុណជាតិ និងមាតុភូមិ ។ បើប្រព្រឹត្តផ្ទុយពីនេះ មនុស្សពិតជាគ្មានតំលៃចំពោះជាតិ និងមាតុភូមិឡើយ ។ បើដកសីលញាណចេញ មនុស្សអាចក្លាយជាសត្វមួយបែបដែលកាចឃោរឃៅ ព្រៃផ្សៃជាងសត្វតិរច្ឆាននានា ព្រោះសត្វតិរច្ឆានសំលាប់គ្នាវាដោយសេចក្ដីស្រេកឃ្លាន ដោយសភាវគតិ ឯមនុស្សសំលាប់ពូជមនុស្សយ៉ាងរង្គាលដូចសង្គ្រាមលោកទាំងពីរលើក រឺដូចរបបប្រល័យពូជសាសន៍នៅកម្ពុជាជាដើម ។

បណ្ឌិត ឆយ យីហ៊ាច

# វប្បធម៌
## La culture

ក្នុងអត្ថបទរបស់ខ្ញុំ ដែលបានផ្សាយក្នុងទស្សនាវដ្ដីគ្រូបង្រៀនកន្លងមក ខ្ញុំបានជំរាបជូនខ្លះហើយ អំពីបញ្ញត្តិវប្បធម៌ ។ វប្បធម៌មានន័យទូលំទូលាយណាស់ ។ ខ្ញុំសូមលើកយកពាក្យនេះមកអធិប្បាយពន្យល់បន្ថែមទៀត ដើម្បីជាជំនួយស្មារតីចំពោះបុគ្គលិកសិក្សាខ្មែរទូទាំងប្រទេស ទៅតាមការចេះដឹងរបស់ខ្ញុំ ។ ខ្ញុំមិនហ៊ានអះអាងថា នឹងបានល្អគ្រប់គ្រាន់ និងពេញលេញចំពោះអត្ថន័យដ៏ទូលំទូលាយនៃពាក្យវប្បធម៌នេះឡើយ ។

ឥឡូវនេះ ខ្ញុំសូមធ្វើអត្ថាធិប្បាយពី :

១- ទំនាក់ទំនងរវាងវប្បធម៌ និង ចំនេះដឹងទូទៅ

២- ទំនាក់ទំនងរវាងវប្បធម៌ និង អរិយធម៌

៣- អន្តរកម្មរវាងការអប់រំ និង វប្បធម៌

## I- ទំនាក់ទំនងរវាងចំនេះដឹង និង វប្បធម៌ ( Rapports entre Instruction et Culture )

**ក- ចំនេះដឹង** : កិច្ចផ្ដល់ចំនេះដឹង ( ចេះ + ដឹង) អោយដល់បុគ្គលណាមួយ ទោះចាស់ក្ដី ក្មេងក្ដី និង លទ្ធផលបានមកពីការផ្ដល់នេះ ហៅថា ចំនេះដឹង ។ សិស្សទទួលចំនេះដឹងពីគ្រូដោយការបង្រៀន ។ ចំនេះដឹងនេះ ត្រូវបានចងចាំដោយសិស្ស ។ វាចូលទៅស្ថិតនៅក្នុងខួរក្បាលសិស្ស ។ វាទៅជាទ្រព្យសម្បត្តិខាងផ្នែកបញ្ញារបស់សិស្ស ។ វិជ្ជាជាទ្រព្យមិនអាចចោរលួចបាន ។ ចំនេះដឹង កាលណាសិស្ស រឺអ្នករៀនសូត្រទទួលបាន សន្សំទុកបាន ដោយការចេះពន្យល់ រឺការដឹកនាំល្អរបស់គ្រូបណ្ដុះគំនិតសិស្សអោយចេះគិតពិចារណា ចេះវិនិច្ឆ័យ និង ចេះរែកញែក ។ ចំនេះដឹងជាផ្នែកមួយនៃការអប់រំ ។

ដូចនេះ ទង្វើបំពាក់ចំនេះដឹង រឺចំនេះវិជ្ជា ចំពោះមនុស្សមិនទាន់ចេះដឹងអ្វី អោយមានពន្លឺ គឺការចេះ និងការដឹងស្របនឹងពាក្យបារាំង Instruction ។ មុនដំបូង ចំនេះដឹងបានមកពីបង្រៀន និង រៀន ។ វាក្លាយទៅជាទ្រព្យហៅថា connaissance រឺ savoir ដែលយើងធ្លាប់ប្រែថា វិជ្ជា រឺ វិទ្យា រឺ ចំនេះ ។ អ្នកចេះដឹង (un homme instruit) គឺអ្នកមានចំនេះផ្សេងៗគ្នាជាច្រើន ។ ចំនេះដឹងដែលបានទទួលមក ហាក់ដូចជាដាក់បន្ទាប់គ្នា (juxtaposé) មិនចងភ្ជាប់គ្នាដោយចំនងអ្វីមួយ ។ ក្នុងន័យនេះ វាអាចចូលលាយឡំ និងពាក្យវប្បធម៌ ។

**ខ- វប្បធម៌**: វប្បធម៌ ជាកន្សោមនៃចំនេះដឹង ដែលបានមកជាទ្រព្យហើយ បាននាំអោយគំនិតរីកដុះដាលអភិវឌ្ឍ ឆ្ពោះទៅរកការចេះប្រៀបធៀប ចេះពិចារណា ចេះវិនិច្ឆ័យ ចេះមានចំនូលចិត្តទៅលើអ្វីមួយ ដូចជាអំនាន រឺ វិចិត្រកម្មជាដើម -៧- ។

ជាការពិតណាស់ដែលថា ចំនេះដឹង (le savoir) ជាលក្ខណសម្បត្តិចាំបាច់នៃវប្បធម៌ ប៉ុន្តែមិនមែនជាលក្ខណសម្បត្តិគ្រប់គ្រាន់នៅឡើយទេ ។ គឺគុណសម្បត្តិនៃគំនិតបញ្ញា (qualité de l'esprit), គុណសម្បត្តិនៃការវិនិច្ឆ័យ (qualité du jugement) និងគុណសម្បត្តិខាងមនោសញ្ចេតនា (qualité du sentiment) ឯណោះវិញទេ កាលណាគេបន្លឺពាក្យវប្បធម៌ ។

(១)- ស្នើផ្សព្វផ្សាយអោយសមាជិក ស.ប.ស.ខ បានអាន ក្នុងគោលបំនងបង្កើនចំនេះដឹង ។

ម្យ៉ាងទៀត វប្បធម៌ទាមទារចំនេះដឹងរៀបចំអោយស៊ីសង្វាក់គ្នា បង្កើតបានជាទស្សនៈរួម និងទស្សនទានទូទៅ ។ វប្បធម៌ពិត (la vraie culture) ប្រឆាំងនឹងឯកទេសកម្មហួសហេតុ ដែលធ្វើមនុស្សអោយទៅជាគ្រឿងយន្ត និងនាំអោយអប្បប្រាជ្ញាថែមទៀត ។ ក៏ប៉ុន្តែ អ្នកឯកទេសមែនទែនមិនដូច្នោះទេ ។ គេចេះដោះខ្លួន និងចេះបិតនៅខ្ពស់ជាងឯកទេសកម្មរបស់គេ ។ ក្រៅពីនេះទៀត មនុស្សមានចំនេះដឹងប្រកបដោយវិចារណញ្ញាណ គឺមានវប្បធម៌ទូលំទូលាយ មិនដែលប្រកាសខ្លួនថាចេះប៉ុននេះគ្រប់គ្រាន់ហើយនោះទេ ។ គេនៅតែស្វែងយល់អំពីអ្វីដែលថ្មី ដោយជានិច្ចកាល គេអានកាសែត ទស្សនាវដ្តី សៀវភៅបោះពុម្ពថ្មី ទាក់ទងនឹងចំនេះដឹងទូទៅ និងចំនេះដឹងនៃមុខវិជ្ជារបស់គេ ។ ឧទាហរណ៍ អ្នកបង្រៀនត្រូវអានសៀវភៅមានខ្លឹមសារទាក់ទងនឹងវិទ្យាសាស្ត្រអប់រំ (Sciences de l'éducation) ពីព្រោះចំនេះដឹងបានរៀនមកហើយ មានការប្រែប្រួល និង វិវត្តទៅតាមកាលៈទេសៈ ។ អ្នកមិនឈានទៅមុខ គឺថយក្រោយ " Qui n'avance pas, recule " ។ នេះជាសំដីប្រកបដោយគតិបណ្ឌិត ។ យើងត្រូវយល់ថា មិនមានមនុស្សមានវប្បធម៌ជាស្ថាពរនោះទេ គឺមានតែមនុស្សស្វះស្វែងចង់ចេះចង់ដឹងបន្ថែមទៀត " Il n'est pas d'hommes cultivés, une fois pour toutes, mais des hommes qui se cultivent, a affirmé avec raison le philosophe H. Bouasse ។

មនុស្សមានវប្បធម៌ពិត ត្រូវបានគេសង្កេតឃើញថា ជាមនុស្សមានគតិបណ្ឌិត មានមេត្តាធម៌ មានសប្បុរសធម៌ គិតដល់បញ្ហាមនុស្សទូទៅ ជាមនុស្សនិយម ។

ជាការសន្និដ្ឋានផ្នែកទី ១ វាមិនមានភាពបដិបក្ខនឹងគ្នាទេ រវាងចំនេះដឹង និង វប្បធម៌ ។ ចំនេះដឹងជាមធ្យោបាយឈានទៅចាប់យក រឺទៅដល់វប្បធម៌ ។ យើងមិនមានបំនងប្រាថ្នាបំបែកពាក្យទាំងពីរនេះទេ ។ យើងត្រូវតែផ្គុំគ្នាវិញល្អជាង ព្រោះវប្បធម៌មិនអាចមានទេ បើខ្វះចំនេះដឹង ។ គេមិនអាចបណ្តុះបញ្ញាបានទេ បើមិនមានអ្វីជាចំណីរបស់វា ។

## II-ទំនាក់ទំនងរវាងវប្បធម៌ និង អារ្យធម៌ : ( Rapports entre culture et civilisation )

ក្នុងផ្នែកទី ២ នេះ វប្បធម៌មានន័យប្លែកអំពីពាក្យវប្បធម៌ក្នុងផ្នែកទី ១ ត្រង់ចំនុចថា វប្បធម៌ជាព្រលឹងរបស់ជាតិ ។ ជាតិរស់ ព្រោះវប្បធម៌ ។ វប្បធម៌រលត់ ជាតិរលាយ ។ បំផ្លាញវប្បធម៌ជាតិ គឺបំផ្លាញខ្លួនឯង -ល- ។

ចំពោះបញ្ហាវប្បធម៌នេះ ខ្ញុំបានអានសៀវភៅជាច្រើន ដែលអ្នកនិពន្ធ និងរៀបរៀង បានចងក្រងជាសៀវភៅសំរាប់សិស្សថ្នាក់ទីបញ្ចប់ និងថ្នាក់ត្រៀមមហាវិទ្យាល័យ ។ ការអធិប្បាយសឹងតែប្រហាក់ប្រហែលគ្នាទាំងអស់ ព្រោះដកស្រង់ចេញពីប្រភពដូចគ្នា គឺសៀវភៅលោក **សរ សារុន**, លោក និងលោកស្រី **ត្រឹង ងា**, លោក **វ៉ាន់នី កានុន** ។ ការអោយនិយមន័យ គឺគ្រាន់តែអោយសិស្សទន្ទេញចាំមាត់ សំរាប់ប្រលងប៉ុននោះ ។ រីឯការយល់ជ្រួតជ្រាប ស៊ីជំរៅ ហាក់ដូចជានៅសើៗ ស្មាក់ស្មើរ មិនច្បាស់លាស់សោះ ។

ខ្ញុំឆ្លៀតឱកាសនេះ ដើម្បីបំភ្លឺបន្ថែមតាមការយល់ដឹងរបស់ខ្ញុំ ថាអ្វីទៅដែលហៅថា វប្បធម៌ ក្នុងបរិបទទស្សនវិជ្ជា និង អភិសមាចារ (វិទ្យាសាស្ត្រខាងសីលធម៌) ។

យើងគួរលើកពាក្យស្លោកទាំងប៉ុន្មានខាងលើមកវែកញែក មកធ្វើជាកម្មវត្ថុសំរាប់ពិចារណា ។

វប្បធម៌ ជាព្រលឹងរបស់ជាតិ រឺវប្បធម៌ = ព្រលឹង ។ យើងសួរថា ព្រលឹងស្ថិតនៅនឹងអ្វី ? អ្វីជាតួខ្លួននៃព្រលឹងជាតិ ? បើយករូបភាពមនុស្សមកប្រៀបធៀប គឺតួខ្លួនមនុស្សជាទីជំរកនៃចិត្តគំនិត វិញ្ញាណ រឺ ព្រលឹង ។ ការលូតលាស់បច្ចេកទេស និង សំភារៈនៃសង្គម ជាមូលដ្ឋាន រឺជាតួខ្លួន រឺជាអារ្យធម៌ ។ រីឯវប្បធម៌ ជាព្រលឹងនៃអារ្យធម៌ ។ បានសេចក្តីថា អារ្យធម៌លូតលាស់បានខ្ពស់ ដោយបញ្ញាញាណ ។ «A l'image de la personne humaine, la technique constitue le corps d'une civilisation, la culture représente son âme »

សូមពិចារណាលើល្បះនេះ « អរិយធម៌អង្គរ គឺជាការលូតលាស់ដល់កំពូលនៃសង្គមធម៌ និង វប្បធម៌របស់ប្រទេសខ្មែរនាសតវត្សរ៍ទី ១២ » ។ វប្បធម៌ = ព្រលឹង រឺ ចិត្ត គំនិត រឺ វិញ្ញាណ រឺ ស្មារតី ។ បើព្រលឹងបាត់បង់ហើយ ក្នុងរបបប្រល័យពូជសាសន៍ ហើយនៅក្រោយថ្ងៃ ៧-១-៧៩ ដោយវាបាក់ស្បាត វារត់ទៅពូនសំងំយកសុខតែឯកឯង តើសង្គមខ្មែរមានការលូតលាស់ដែររឺទេ ខាងចិត្តគំនិត ? ហើយសង្គមខ្មែរនឹងក្លាយទៅជាយ៉ាងណា ? ។ ដើម្បីបំភ្លឺអោយកាន់តែច្បាស់ថែមទៀត ខ្ញុំសូមអ្នកអានក្រឡេកមើលសម័យអង្គរជាមួយខ្ញុំ ។ នាសតវត្សរ៍ទី ១២ ការលូតលាស់ខាងស្ថាបនកម្ម ខាងសិល្បះ អក្សរសិល្ប៍ អក្សរសាស្ត្រ -ល- និងការលូតលាស់ខាងបច្ចេកទេសកសិកម្ម ដូចជា ការជីកបារាយ ប្រឡាយទឹកបញ្ចូលស្រែ ដែលទុកជាកេរមរតកអោយកូនចៅមកទល់បច្ចុប្បន្នកាលនេះ ទុកជាតួខ្លួន គឺអរិយធម៌អង្គរ ។ ប្រាសាទបាយ័ន ដែលមានកំពូល ៤៧ ក្លោងទ្វារ ៥ ។ កំពូលនីមួយៗមានមុខ ៤ ជាតួអរិយធម៌ ។ រីឯទស្សនទាន នៃព្រះបាទជ័យវរ្ម័នទី ៧ ទ្រង់ឈ្វេងយល់ដូចម្តេចបានជាត្រាស់បង្គាប់អោយសាងប្រាសាទប្លែកពីប្រាសាទដទៃនោះ គឺមិនមកពីការលូតលាស់ខាងបញ្ញាញាណ ខាងគំនិតច្នៃប្រឌិតខាងសីលធម៌ គុណធម៌ និងគតិបណ្ឌិត នាសម័យនោះទេរឺ ដែលព្រះអង្គចាត់អោយសាងប្រាសាទបាយ័ន ដែលមានរចនាបទខុសប្លែកដូច្នេះ ។ ប្រាសាទបាយ័នជានិមិត្តរូបនៃអំណាចកណ្តាល ដែលមានតួអង្គព្រះបាទជ័យវរ្ម័នទី ៧ ជាតំណាង និងអំណាចតំបន់ភូមិភាគ រឺមូលដ្ឋាន ។ ម្យ៉ាងទៀត **លោកេស្វរៈ** ដែលមាន ព្រះភក្ត្រ ៤ បែរទៅគ្រប់ទិសទាំង ៤ តំណាងគុណធម៌ ៤ គឺ មេត្តា ករុណា មុទិតា និង ឧបេក្ខា ។ ទស្សនទានរបស់ព្រះបាទ ជ័យវរ្ម័នទី ៧ នេះ យើងចាត់ទុកជាវប្បធម៌ រឺជាព្រលឹងរបស់ជាតិ រឺសង្គមខ្មែរនៅសម័យនោះ ។ យើងចង់អោយខ្មែរមានព្រលឹង គឺវប្បធម៌ឡើងវិញ ។ អន្ទងហៅព្រលឹង រឺជញ្ជាត់ព្រលឹងមកវិញ បានសេចក្តីថា បណ្តុះវប្បធម៌ខ្មែរចំពោះប្រជាពលរដ្ឋខ្មែរ យុវជនខ្មែរ អោយយល់ដឹងពីតំលៃនៃវប្បធម៌ខ្មែរឡើងវិញ ដែលជាគ្រឹះនៃការអភិវឌ្ឍន៍សង្គម -ល- ។ វប្បធម៌ខ្មែរ រឺ ព្រលឹងខ្មែរបាត់បង់ទៅណា ? នរណាជាអ្នកបំបាត់ព្រលឹងខ្មែរ គឺសង្គ្រាម និងរបបប្រល័យពូជសាសន៍ដ៏ព្រៃផ្សៃ ដែលបានធ្វើអោយប្រជាពលរដ្ឋខ្មែរដែលធ្លាប់តែសុចរិត ទៀងត្រង់ ស្លូតបូត ក្លាយជាមនុស្សកាច មានចិត្តច្រណែន ហឹង្សា ចេះភូតកុហក ចេះលួច -ល- ។ គេពង្វក់ស្មារតីយុវជន យុវតី អោយស្អប់អ្នក ១៧ មេសា អោយលែងដឹងពីតំលៃមនុស្សអោយស្គាល់តែពាក្យកំទេច ព្រោះទុកមិនចំណេញ ដកចេញមិនខាត ។ នេះជាជនដាច់ខាតចំពោះ « **អង្គការ** » ។ ការអប់រំអោយស្រលាញ់ និង ចេះថែរក្សាវប្បធម៌កុំអោយបាត់បង់ អោយវប្បធម៌ជ្រួតជ្រាប និងដុះជ្រៅទៅក្នុងចិត្តថ្លើមនៃប្រជាពលរដ្ឋជាទង្វើដ៏ប្រពៃនាបច្ចុប្បន្នកាលនេះ ។ អត្តសញ្ញាណជាតិ នឹងស្ថិតជាប់ក្នុងក្រអៅបេះដូងនៃពលរដ្ឋខ្មែរ ។

អធិប្បាយមកដល់ត្រឹមនេះ ខ្ញុំសង្ឃឹមថា អ្នកអានយល់បានមួយកំរិតហើយ នៃពាក្យវប្បធម៌ ។ អ្នកអក្សរសាស្ត្រ និងអ្នកសង្គមសាស្ត្រ ប្រើពាក្យវប្បធម៌ ជាវេវចនៈ និងពាក្យអរិយធម៌ ដូចជាគេអាចនិយាយថា វប្បធម៌បារាំង ចិន ឥណ្ឌា ជាដើម ។

ដោយមិនបានផ្តល់និយមន័យនៃពាក្យវប្បធម៌អោយបានចប់សព្វគ្រប់ ដូចអ្នកនិពន្ធ និងរៀបរៀងមេរៀនវប្បធម៌ និងអរិយធម៌ ខ្ញុំសូមលើកយកន័យពីរនៃពាក្យវប្បធម៌ លើកឡើងដោយអ្នកនិពន្ធពីរនាក់ ហើយសូមអ្នកអានប្រៀបធៀប និងវិនិច្ឆ័យចុះ ។ ខ្ញុំសូមអនុញ្ញាតមិនបញ្ចេញនាមអ្នកនិពន្ធ ដើម្បីសំរួលដល់ការវិនិច្ឆ័យសេរី ។

*** <u>ន័យផ្តល់អោយដោយអ្នកនិពន្ធទី ១</u> :**

« វប្បធម៌ » មានន័យថា អ្វីៗដែលមនុស្សបង្កើត រឺបន្ថែមពីលើធម្មជាតិ រឺទំនៀមទំលាប់ដើមទៀត ។ វប្បធម៌រាប់បញ្ចូលនូវអ្វីៗដែលបង្កើតដោយស្នាដៃមនុស្ស ជាពិសេស គឺផ្នែកបញ្ញាពលកម្ម រួមទាំងកាយពលកម្មផងដែរ ។ ប៉ុន្តែ ទោះបីមានន័យច្រើនបែបយ៉ាងនេះក៏ដោយ ក៏និយមន័យទាំងនោះសុទ្ធតែឯកភាពគ្នា ទៅលើការរីកចំរើនផ្នែកចំនេះដឹង និងបញ្ញាស្មារតីរបស់មនុស្ស ។ ដូចនេះ វប្បធម៌ គឺធម៌ទាំងឡាយណាដែលទ្រទ្រង់ក្តោបក្តាប់បណ្តាត់លៃច្នៃប្រឌិតរបស់មនុស្សទៅលើហេតុ ធាតុភូតផ្សេងៗនៃធម្មជាតិ សំដៅបង្កើនផលល្អប្រសើរ ចំរើនលូតលាស់ ដើម្បីបន្ថែមទៅលើធម្មជាតិ រឺទំនៀមទំលាប់ចាស់តាមបញ្ញាពលកម្មក្តី កាយពលកម្មក្តី ។

*** <u>ន័យផ្តល់អោយដោយអ្នកនិពន្ធទី ២</u> :**

វប្បធម៌គឺជាសមិទ្ធផលនៃជ័យជំនះដោយហត្ថពលកម្ម និងបញ្ញាពលកម្មរបស់មនុស្សលើធម្មជាតិ លើអវិជ្ជា លើភាពអន្ធការ ពិសេស គឺលើចំនុចខ្សោយរបស់មនុស្ស ដោយមនុស្សខ្លួនឯង ។ គោលដៅជាមូលដ្ឋានរបស់វប្បធម៌គឺមនុស្សធម៌ ។ កាលណាស្នាដៃវប្បធម៌កាន់តែខ្ពង់ខ្ពស់ គោលដៅមនុស្សធម៌[(១)] កាន់តែជ្រាលជ្រៅ និងសុក្រឹត្យ ។

បន្តទៅនេះ ខ្ញុំសូមជូនន័យនៃពាក្យវប្បធម៌ដែលសន្និសីទអន្តររដ្ឋាភិបាល ស្តីពីគោលនយោបាយវប្បធម៌ ដើម្បីអភិវឌ្ឍន៍បានប្រារព្ធធ្វើនៅ Stockholm រដ្ឋធានីនៃប្រទេស ស៊ុយអែត កាលពីថ្ងៃទី ៣០ មិនា ដល់ថ្ងៃ ២ មេសា ១៩៩៨ កន្លងទៅនេះ ។ សន្និសីទនេះ ដែលមានអ្នករួមប្រជុំ ២.៤០០ នាក់នោះ បានមូលមតិយល់ព្រមយកន័យនៃពាក្យវប្បធម៌ដូចខាងក្រោម :

«ក្នុងន័យទូលាយរបស់ពាក្យវប្បធម៌ វប្បធម៌នាពេលនេះ ត្រូវបានចាត់ទុកជាកន្សោមនៃលក្ខណៈសំគាល់ខាងស្មារតី សំភារៈ បញ្ញា និង មនោសញ្ចេតនា ដែលអាចសំគាល់នូវលក្ខណសង្គមមួយ រឺមនុស្សមួយក្រុម ។ ក្រៅពីសិល្បៈ និងអក្សរសាស្ត្រ របៀបរបបរស់នៅ និងសិទ្ធិជាសារវន្តនៃមនុស្ស វប្បធម៌មានរួមបញ្ចូលប្រព័ន្ធតំលៃទំនៀមទំលាប់និងជំនឿ...» ។

(១) - ក.អ. មនុស្សនិយមត្រូវជាង (Culture est synonyme d'humanisme)

<u>ការសន្និដ្ឋាន</u> (ផ្នែកទី ២)

ដូចដែលខ្ញុំបានជំរាបរួចមកហើយ (ក្នុងផ្នែកទី ១) ថា វប្បធម៌ ជាចំនេះដឹងប្រកបដោយបញ្ញាញាណ ស្មារតី និង គំនិតច្នៃប្រឌិត ។ យើងបានដឹងហើយថា កម្ពុជានាសម័យអង្គរ មានអ្នកប្រាជ្ញ ស្ថាបត្យករ កវី ជំនាងខាងចម្លាក់ខាងអក្សរសាស្ត្រ -ល- ប៉ុន្មាននាក់ ។ បញ្ញាញាណនេះឯងហើយ ដែលដឹកនាំសាងសង់ប្រាង្គប្រាសាទ ស្ថាបនាអាងទឹកសំរាប់កសិកម្ម និង អក្សរសាស្ត្រ ព្រមទាំងចម្លាក់ដ៏រស់រវើកនៃប្រាង្គប្រាសាទ ជាពិសេស ប្រាសាទបន្ទាយស្រី ។

ក្នុងផ្នែកទី ២ នេះ វប្បធម៌ចាត់ទុកជាព្រលឹងរបស់ជាតិ ។ សូមស្តាប់មតិអ្នកនិពន្ធម្នាក់ឈ្មោះ Juma A. Kapuya ដែលបានសរសេរថា «Une nation sans culture est une nation sans avenir, c'est une nation morte » ប្រែថា ប្រជាជាតិមួយមិនមានវប្បធម៌ ជាប្រជាជាតិមួយមិនមានអនាគត គឺជាប្រជាជាតិស្លាប់ ។ រីឯអរិយធម៌ ជាសមិទ្ធិផលបានមកពីបញ្ញាញាណ គឺវប្បធម៌នេះឯង ។ ដូចនេះ យើងអាចសន្និដ្ឋានបានថា ពាក្យវប្បធម៌ និង អរិយធម៌ ជាគូគ្នាមិនអាចផ្តាច់ពីគ្នាបានឡើយ ។ វឌ្ឍនធម៌ និង អារ្យធម៌លូតលាស់បាន លុះណាតែមាន :

- ទី ១ : វឌ្ឍនធម៌ខាងបច្ចេកទេសដែលបញ្ជាក់ពីជ័យជំនះលើធម្មជាតិ
- ទី ២ : វឌ្ឍនធម៌ខាងសង្គម និង ស្មារតី

## III- <u>អន្តរកម្មរវាងការអប់រំ និង វប្បធម៌</u> ( Interaction entre éducation et culture )

ខ្មែរយើងច្រើននិយាយថា " កូនគេនេះមិនបាច់ស្រោចទឹកច្រើនទេ វាដុះខ្លួនឯងតែម្តង " ។ សំដីនេះបានន័យដូចម្តេច ? ប្រជាជនអាល្លឺម៉ង់ ហៅសាលាមត្តេយ្យថា សួនកុមារ ។ ហេតុអ្វី ? សួនកុមារដែលយើងធ្លាប់ស្គាល់ថា ជាសួនសំរាប់កុមារា កុមារី រត់លេងរី ? មិនមែនទេ ។ នេះជាការភន្ត័ច្រលំធំហើយ ។ ប្រជាជនអាល្លឺម៉ង់យកកូនទៅដាក់នៅក្នុងសាលានេះតាំងពីអាយុ ៣ ឆ្នាំឡើងទៅ ព្រោះគេទុកកុមារជាកូនរុក្ខជាតិ ត្រូវយកវាទៅដាំ ។ ពាក្យទាំងពីរម៉ាត់ " **វាដុះមិនចាំបាច់ស្រោចទឹក** " និង " **បណ្តុះកូននៅសួនកុមារ** " តើអស់លោកគ្រូ-អ្នកគ្រូ យល់យ៉ាងណា ? ចំពោះសំដីទី ១ ខ្ញុំសូមមិនធ្វើអត្ថាធិប្បាយទេ ។ សូមអ្នកគ្រូ-លោកគ្រូ អានទស្សនាវដ្តីគ្រូបង្រៀនលេខ ៥ និងលេខ ៦ ។

ចំពោះសំដីទី ២ ដែលថា បណ្តុះកុមារ (cultiver l'enfant) ចាប់ពីមត្តេយ្យសិក្សាឡើងទៅ តើបានន័យដូចម្តេច ? មិនពិបាកយល់ទេ ។ បណ្តុះក្នុងន័យនេះ គឺបំពាក់ចំនេះដឹង និងអប់រំ ។ គ្រូជាអ្នកបង្រៀន, សិស្សជាអ្នករៀន ។ ការបង្រៀន-រៀន (apprentissage) នេះមានទិសដៅអ្វី ? រី បណ្តុះកុមារក្នុងគោលបំនងអ្វី ? នេះជាសំនួរដែលលោកគ្រូ-អ្នកគ្រូត្រូវឆ្លើយ និងយល់អោយច្បាស់ ទើបបណ្តុះសិស្សបានចំទិស ។ ខ្ញុំសូមឆ្លើយជំនុសសិនចុះថា បណ្តុះសិស្ស រឺកុមារ គឺអប់រំ (១) កុមារអោយបានទៅជាពលរដ្ឋ ដែលសង្គមទាមទារចង់បាននៅពេលអនាគត ។ គឺបំពាក់អាវុធអោយគេ ដើម្បីយកជ័យជំនះលើធម្មជាតិ ។ បណ្តុះកុមារទទួលបានគុណសម្បត្តិពីរ :

១- សិស្សមានគំនិតបញ្ញាចេះត្រិះរិះពិចារណា ។

២- សិស្សមានសកម្មភាពប្រកបដោយថាមពលក្នុងជីវិត ច្នៃជីវិតអោយរស់រវើកជានិច្ច ។

(១)- បង្រៀន + អប់រំ

រួមសេចក្តីមកវិញ សាលារៀនផ្តល់ចំនេះដឹងអោយសិស្ស និងអប់រំសិស្សអោយមានចរិយាសុភាពរាបសា និងចិត្តគំនិតជាពលរដ្ឋថ្លៃថ្នូរ ស្គាល់សិទ្ធិ និង ករណីយកិច្ចរបស់ខ្លួន ។

ការបង្ហាត់បង្រៀនប៉ុននេះ មិនទាន់គ្រប់គ្រាន់នៅឡើយទេ ។ ពីព្រោះអ្វី ? ព្រោះអត្តសញ្ញាណជាតិ រឺ វប្បធម៌ជាតិ មិនទាន់បានបំផុសអោយសិស្សយល់ថា ខ្លួនជានរណា ? កំពុងរស់នៅទីណា ? តើមានភារកិច្ចធ្វើអ្វីចំពោះប្រទេសជាតិ ? ដូចនេះ វប្បធម៌ជារឹសកែវនៃកូនឈើ ជារឹសកែវនៃការអប់រំ ។ រឹសកែវនេះ បើបានដុះជ្រៅទៅក្នុងដី គឺដុះជ្រៅទៅក្នុងចិត្តគំនិតនៃពលរដ្ឋ នោះនឹងទប់ដើមឈើមិនអោយរលំងាយ កាលណាមានខ្យល់ខ្លាំង ។ រីឯមនុស្សក៏ដូចនោះដែរ ។ សព្វថ្ងៃនេះ ដោយសញ្ញាណវប្បធម៌ខ្សោយ គេកំពុងតែដករឹសវប្បធម៌ខ្មែរដោយឥតដឹងខ្លួន ។

ជាទីបញ្ចប់នៃផ្នែកទី ៣ នេះ ខ្ញុំសូមបញ្ជាក់ថែមទៀតថា ការអប់រំមានទិសដៅបណ្តុះ និងពត់តំរង់ (former) មនុស្ស អោយបានជាមនុស្សល្អ ជាពលរដ្ឋល្អ ជាពលករល្អ ។ ការបណ្តុះនេះ រឹងមាំបាន ស៊ីជំរៅបាន លុះត្រាតែវប្បធម៌ = ព្រលឹងជាតិ រួមជាកំលាំងស្នូល ទើបជាប់ល្អ និងឋិតថេរ ។ សូមស្តាប់សំដីខាងក្រោមនេះ ដើម្បីទុកជាគោលគំនិត « La culture et l'éducation ont une relation symbiotique réciproque et mutuellement génératrice (Kidd et Coletta 1980) ប្រែថា វប្បធម៌ និងការអប់រំមានទំនាក់ទំនងគ្នាស្អិតល្អួតណាស់ ហើយផ្តល់ផលអោយគ្នាទៅវិញទៅមក ។

យ៉ង់ ធី

« មួយសោតឪពុកផ្តាំ ចូរបាចាំកុំផឹកស្រា
វានាំចិត្តពាលា ពាលាលន់ពន់ពេកក្រៃ ។
ផឹកស្រាជាអ្នកកាច ពុំក្រែងខ្លាចអ្នកដទៃ
វានាំបាត់ស្មារតី នឹងរកស៊ីបាត់ប្រាជ្ញា ។
នៅនាលោកីយហោង អស់អ្នកផងគេនិន្ទា
លុះខ្លួនជូនមរណា ទៅនរកវេទនាក្រៃ ។ »

**វប្បធម៌ជាគ្រឹះនៃការអភិវឌ្ឍសង្គម**

# ការសន្ទនារវាងលោក ក និងលោក ខ

## ( លោក ក អាយុច្រើនជាងលោក ខ )

**លោក ខ** : សូមបងមេត្តារៀបរាប់ពីនាមក្រសួងអប់រំ ចាប់តាំងពីប្រទេសកម្ពុជានៅក្រោមអាណាព្យាបាលបារាំង រហូតមកដល់សព្វថ្ងៃនេះ ។

**លោក ក** : សូមថ្លែងអំណរគុណចំពោះប្អូន ដែលលើកសំនួរនេះមកសួរបង ។ ដូចនេះ សូមប្អូនចាំស្តាប់ ។ ប្រទេសកម្ពុជា នៅមុនពេលបារាំងចូលមកធ្វើជាអាណាព្យាបាល មិនមានក្រសួងអប់រំទេ ការសិក្សាត្រូវបានប្រគល់ជូនទៅលើព្រះសង្ឃ ។ ព្រះរាជាជំនាន់បូរាណ មានតែសេនាបតីបួនរូបតែប៉ុននោះ ហៅថា ចតុស្តម្ភ ( ចតុ + ស្តម្ភ : សសរ) [(១)] ។

- លោកអ្នកឧកញ៉ាចក្រី គុណ្ឌរាធិបតី សេនាបតីទទួលបន្ទុកកិច្ចខាងក្រសួងយុទ្ធនាការចំបាំងជើងគោក ។
- លោកអ្នកឧកញ៉ាយោមរាជ [(២)] សេនាបតីក្រសួងយុត្តិធម៌ ។
- លោកអ្នកឧកញ៉ាក្រឡាហោម ជាសេនាបតីខាងអាណាចក្រ ។
- លោកអ្នកឧកញ៉ាវាំងវរវៀងជ័យ សេនាបតីក្រសួងព្រះរាជវាំង និងហិរញ្ញវត្ថុ ។

នៅក្នុងរជ្ជកាលព្រះបាទអង្គឌួង ចំនួនសេនាបតីមានប្រាំ គឺ សម្តេច ចៅហ្វាទឡ្ហ ទទួលបន្ទុកជាអគ្គសេនាបតី ។ ប៉ុន្តែ ក្នុងរជ្ជកាលព្រះបាទនរោត្តម សម្តេចចៅហ្វាទឡ្ហ ត្រូវបានទទួលឋានន្តរៈជាអគ្គមហាសេនាវិញ ។ ចាប់ពីឆ្នាំ ១៨៨៤ ក្នុងព្រះរាជវាំង បារាំងតែងតាំងក្រុមប្រឹក្សារដ្ឋមន្ត្រីដែលមានរ៉េស៊ីដង់ស៊ូបេរីយ៉េរ ជាប្រធាន ។ ក្រុមប្រឹក្សារដ្ឋមន្ត្រីមានក្រសួង ( ៥)

- ក្រសួង មហាផ្ទៃ និង ធម្មការ
- ក្រសួង យុត្តិធម៌
- ក្រសួង វាំង ហិរញ្ញវត្ថុ និង សិល្បៈ
- ក្រសួង នាវាចរ ពាណិជ្ជកម្ម និង កសិកម្ម
- ក្រសួង សង្គ្រាម និង អប់រំ

សេនាបតី (Minister ) ម្នាក់ៗ មានភូឈួយម្នាក់ និងលេខាធិការ ៤ នាក់តែប៉ុននោះ ។

ឆ្នាំ ១៩១១ រាជការបារាំងបានបង្កើតទីចាត់ការមួយសំរាប់ត្រួតត្រា និងគ្រប់គ្រងវិស័យអប់រំទូទាំងប្រទេសកម្ពុជា ។ អ្នកគ្រប់គ្រងនេះ ជាជនជាតិបារាំង ធ្វើការក្រោមបង្គាប់លោកអគ្គនាយកសាធារណៈសិក្សានៅក្រុងហាណូយ ។ អ្នកគ្រប់គ្រងការសិក្សានៅកម្ពុជាមាននាមជា Chef de service de l'enseignement local គឺនាយសិក្សាធិការនៅកម្ពុជា ។

---

(១) - ប្រវត្តិសាស្ត្រខ្មែរ ត្រឹង ងា - វចនានុក្រមខ្មែរ

(២) - ក្លាយមកពីពាក្យ យមរាជ

ខ្ញុំសូមទាញអារម្មណ៍ប្អូនថា ខ្មែរយើងដោយចេះចាំពីសម័យអាណាព្យាបាលបារាំងមក ច្រើននិយាយថា ក្រសួងសិក្សាធិការ ។ ពាក្យសិក្សាធិការ ជាសមាសនាមផ្គុំសិក្សា និងអធិការ ។ អធិការប្រែថា អ្នកត្រួតត្រា រឺគ្រប់គ្រង ។ សិក្សាធិការ គឺជាអ្នកត្រួតត្រា រឺគ្រប់គ្រងការសិក្សា ។ មានអ្នកខ្លះពោលថា វិបត្តិអប់រំ និងសិក្សាធិការធ្ងន់ធ្ងរណាស់នាបច្ចុប្បន្នកាលនេះ ។ ការនិយាយសិក្សាធិការដូចនេះខុស រឺ ត្រូវ ។ សូមប្អូនឆ្លើយ ។

លោក ខ ៖ ខ្ញុំយល់ថា មិនត្រូវទេ ។ នេះមកតែពីអ្នកនិយាយរត់មាត់ទៅហើយ ឥតពិចារណា ខ្ញុំយល់ថា កាលជំនាន់ដើម អ្នកប្រែភាសាបក service de l'enseignement ជាសិក្សាធិការ ។ ដូចគ្នានឹងពាក្យ សុខ + អភិបាល = សុខាភិបាល ។

លោក ក ៖ ដូចនេះ យើងបន្តការសន្ទនាគ្នាទៅទៀត ។ នាយសិក្សាធិការនៅកម្ពុជា (Chef de service de l'ense ignement local) មានអត្ថិភាពរហូតដល់ឆ្នាំ ១៩៤៥ ។

ចាប់ពីថ្ងៃ ១៧ មីនា ១៩៤៥ រាជរដ្ឋាភិបាលបានបង្កើតក្រសួងមួយមាននាមថា ក្រសួងអប់រំជាតិ (Ministère de l'Education) ដែលមានមករហូតដល់សព្វថ្ងៃនេះ ។

**យ៉ង់ ឌី**

## ទស្សនៈថ្មី

* * *

កាលពីថ្ងៃ ២៦ ខែ កក្កដា ឆ្នាំ ១៩៧១ អវកាសយានិក ជែម.ប.អឺរវិង (James.B. Irving) បានត្រលប់មកដីវិញ ក្រោយពីបានបំពេញបេសកកម្មនៅលើព្រះច័ន្ទ ។ គាត់មានប្រសាសន៍ថា កាលណាយើងខ្ញុំហោះនៅក្នុងអវកាសវេហា យើងខ្ញុំមានទស្សនៈមួយថ្មីពីយើងទាំងអស់គ្នា ។ កាលណាក្រលេកមើលមកផែនដី ខ្ញុំមានចិត្តចង់បញ្ជាក់ប្រាប់អ្នកថា ទីស្ថានដែលមនុស្សយើងមានជីវិតរស់នៅមានតែមួយគត់ ។ ដូចនេះ មនុស្សត្រូវតែរៀនរស់ជាមួយគ្នាអោយបានរអីករអីន ។

# ការគោរពអ្នកដទៃ

ក្នុងទស្សនាវដ្ដីលេខ ៨ និង ៩ ខ្ញុំបានអធិប្បាយអំពី : ការដឹង រឺ ស្គាល់ខ្លួនឯងដោយខ្លួនឯង និងការគោរពខ្លួនឯង ។ តើលោកអ្នកអានបានត្រិះរិះពិចារណាខ្លះដែររឺទេ ? តើហេតុអ្វីបានជាត្រូវស្គាល់ខ្លួនឯងដោយខ្លួនឯង និងត្រូវគោរពខ្លួនឯង តើបានប្រយោជន៍អ្វី ?

នៅលើទំព័រទស្សនាវដ្ដីលេខ ១០ នេះ ខ្ញុំបន្តអធិប្បាយពីការគោរពអ្នកដទៃ ។ តើមូលហេតុអ្វី បានជាត្រូវគោរពអ្នកដទៃ ? ។ ព្រោះមនុស្សកើតមក មិនអាចរស់នៅតែឯកឯងបានទេ គឺត្រូវរស់នៅក្នុងសង្គមមួយជាក់លាក់ តែក៏អាចផ្លាស់ប្ដូរមជ្ឈដ្ឋានរស់នៅតាមកាលៈទេសៈបានដែរ ។ ឧ : កាលនៅពីក្មេង គេរស់នៅក្នុងសង្គមខ្មែរ ។ ដល់គេធំឡើង គេទៅរស់នៅក្នុងប្រទេសដទៃផ្សេងវិញ ។ ការគោរពអ្នកដទៃ គឺការគោរពអ្នកជិតខាង ជាញាតិ ជាមិត្ត និងអ្នកមិនមែនជាមិត្ត ជាជនបរទេស ដោយយល់ថា មនុស្សដទៃមានសិទ្ធិសេរីភាព មានតំលៃជាមនុស្សដូចគ្នា ។

យើងរៀនគោរពអ្នកដទៃ តាំងពីយើងស្ថិតនៅក្នុងវ័យកុមារ រហូតដល់ចាស់ស្លាប់ ។ យើងត្រូវតែមានចិត្តរាប់អានអ្នកដទៃ គោរពអ្នកដទៃ ទើបរស់នៅបានសុខដុមរមនាជាមួយគ្នា ។ កាលនៅតូច កុមារា កុមារី រស់នៅជាមួយឪពុកម្ដាយបងប្អូនបង្កើត ។ ដល់ធំពេញវ័យ គេរស់នៅដោយមានទំនាក់ទំនងជាមួយបងប្អូនជីដូនមួយ ជីទួតមួយ ញាតិមិត្តជិតខាង ។

តើយើងត្រូវមានគុណធមិអ្វី ដើម្បីកំចាត់នូវអាកប្បកិរិយារើសអើង ឆ្មើងកន្ទ្រើង មើលងាយ ស្អប់ខ្ពើម ដែលនាំអោយយើងប្រកាន់អាកប្បកិរិយាអាត្មានិយមហួសហេតុ ។

ជាដំបូង ម្នាក់ៗត្រូវមានធមិសន្ដោសប្រណី រឺអត់អោន (Tolérance ) ។

ចំពោះសំនេរនិយាយពីការគោរពអ្នកដទៃ ខ្ញុំបានអធិប្បាយជំរាបជូនក្នុងសៀវភៅ " សីលធមិ និងគោលធមិទ្រទ្រង់មនុស្សជាតិ " របស់ខ្ញុំរួចហើយ ចាប់ពីទំព័រ ៣២ ដល់ ៣៦ ។ ប៉ុន្តែ ដើម្បីផ្សព្វផ្សាយគុណធមិគោរពអ្នកដទៃអោយបានជ្រួតជ្រាប និងទូលំទូលាយបន្ថែមទៀត ខ្ញុំសូមដកស្រង់ចេញពីសៀវភៅខ្ញុំនេះ នូវខ្លឹមសារដែលលោកគ្រូ-អ្នកគ្រូ គួរតែយល់ដឹង និងអប់រំសិស្សអោយក្លាយជាមនុស្សល្អ ប្រកបដោយសីលធមិ និងគុណធមិទៅអនាគត ។ សិស្សនឹងក្លាយជាពលរដ្ឋល្អ ចេះដឹងពីតំលៃរបស់មនុស្ស និងសិទ្ធិសេរីភាពអ្នកដទៃ ។

**<u>ការគោរពអ្នកដទៃ</u>**

## ក. <u>ការសន្ដោស រឺ ការអត់អោន</u> ( La tolérance )

សីលធមិនេះ នាំយើងអោយគោរពបុគ្គល ។ ដូចនេះ ជាចាំបាច់ យើងត្រូវមានធមិសន្ដោស គឺយើងត្រូវទទួលស្គាល់ថា បុគ្គលម្នាក់ៗមានសេរីភាព សំដែងមតិ និងធ្វើអ្វីទៅតាមជំនឿរបស់គេ ទោះជាខ្លួនយើងមិនយល់ស្របនឹងគំនិតគេនោះក៏ដោយ ។ទោះជាគេប្រព្រឹត្តអំពើផ្ទាំផ្ទួងលើគោលការណ៍សីលធមិក៏ដោយចុះ ក៏យើងមិនត្រូវឡូឡា ស្ដីបន្ទោសគេឡើយ ។

ចាំឱកាសល្អស្ងាត់តែពីរនាក់ យើងគួរណែនាំគេមករកផ្លូវល្អវិញ ដើម្បីជាបុព្វហេតុសង្គមមនុស្ស ។ ប្រសិនបើគេមិនមកតាមមតិយើង នោះក៏ស្រេចតែគេទៅចុះ ។ យើងបំពេញកិច្ចនេះ ព្រោះជាករណីយកិច្ចរបស់យើង ។ យើងគ្រាន់តែទាញ រឺរំលឹកគេអោយមករកផ្លូវត្រង់វិញ ។ ការក្រើនរំលឹកនេះ មិនមែនចេះតែធ្វើទៅគ្រប់មនុស្សទេ គឺចំពោះតែមនុស្សណាដែលយើងស្គាល់ច្បាស់ធ្លាប់ប្រាស្រ័យទាក់ទងជាយូរមកហើយ ។ ព្រះគ្រូ ខុង ជឺ បានមានប្រសាសន៍ថា : " ចូរអ្នកតបនឹងអំពើល្អដោយអំពើល្អ ប៉ុន្តែចូរអ្នកតបនឹងអំពើអាក្រក់ដោយយុត្តិធម៌ " ។

ជារួម ការមិនប្រកែប្រកាន់ ជាការគោរពសេរីភាពអ្នកដទៃ គឺសុខចិត្តពង្រួញសេរីភាពរបស់យើង ។ ចំពោះការគោរពសេរីភាពអ្នកដទៃ ខ្ញុំសូមលើកយករឿងហេតុមួយដែលជារឿងពិត មកជូនជ្រាបដូចតទៅ : កាលពីឆ្នាំ ១៩៣៨ លោកគ្រូបង្រៀនម្នាក់ ចង់បញ្ចេញខ្លួនថា ជាអ្នក " ធម៌ថ្មី "(១) បានទិតៀនឧបាសក ឧបាសិកា ជើងវត្តមហានិកាយមួយ ដោយលោកគ្រូនោះសង្កេតឃើញលោកគ្រូចៅអធិការវត្តបានស្រោចទឹក ចងខ្សែគាថា រលាស់ទឹកមន្តដល់គូស្វាមី ភរិយាពេលមង្គលការ ។ លោកគ្រូបង្រៀននេះត្រូវអ្នកស្រុក-ភូមិ ស្អប់ខ្ពើម ហើយមកសួររករឿង រកហេតុទាល់តែលោកគ្រូនេះ សុំផ្លាស់ចេញពីឃុំនេះឯង ។

សូមបងប្អូនពិចារណា ។ ពិតមែនហើយ លោកគ្រូបង្រៀននេះ មានសេរីភាពទិតៀនអំពីអ្វីមួយ ដែលគាត់មិនពេញចិត្ត គឺទាស់ភ្នែក ។ ប៉ុន្តែ អំពើទាស់ភ្នែកគាត់នេះ ជាជំនឿ ជាទំនៀមរបស់អ្នកស្រុក អ្នកភូមិ ដែលមានសេរីភាពធ្វើដូច្នេះបានដែរ ។ ដូចនេះ ដើម្បីគោរពសមធម៌ លោកគ្រូបង្រៀនរូបនេះ ត្រូវតែនៅស្ងៀម ចាំមានឱកាសល្អ សឹមឆ្លៀតទូន្មាន ។

**ខ. <u>បរទត្ថភាព</u> (<u>ភាពយកចិត្តទុកដាក់ចំពោះអ្នកដទៃ រឺការស្រឡាញ់រាប់អានអ្នកដទៃ</u>)** ( L'altruisme )

ការស្រឡាញ់រាប់អានអ្នកដទៃ ការយកចិត្តដាក់ឈឺឆ្អាលនឹងអ្នកដទៃ គឺផ្ទុយគ្នាស្រឡះនឹងអត្តទត្ថភាព ។ អ្នកស្រឡាញ់រាប់អានគេ យកអាសាគេ គឺជាមនុស្សដែលយល់ថា ខ្លួនបានទទួលផលពីសង្គមមនុស្សច្រើនណាស់ ។ ដើម្បីតបស្នងសងគុណគេវិញអោយបានច្រើន ខ្លួនត្រូវតែខិតជិតរកគ្នា រាប់អានគ្នាជាបងប្អូន ។ រួមមក គឺមានចិត្តទូលាយ ។ អំពើអមនុស្សធម៌ អសីលធម៌ ត្រូវបានឃ្លាតឆ្ងាយពីសន្តានចិត្តនៃបុគ្គលនោះ ។ ឧទាហរណ៍តូចមួយ បញ្ជាក់បាននូវបរទត្ថភាព ដូចជាការគួរសម (la politesse ) ។ អ្នកតូចតាច ខំលើកដៃសំពះញញឹមទៅរកចៅហ្វាយ តែចៅហ្វាយធ្វើព្រងើយ មិនមើលដៃគ្នាផង ។ នេះគឺមិនមានការគួរសមតបមកវិញ អាងតែចៅហ្វាយ ។ ការគួរសមស្តែងចេញដោយកាយ ដោយវាចា និងដោយចិត្ត (La politesse des manières ou savoir – vivre – la politesse des paroles – la politesse du coeur ) ។

ម្យ៉ាងទៀត គុណធម៌សមានចិត្ត (Vertu de sympathie) ដែលមានសភាពទោរទន់រកគ្នា ដោយសេចក្តីស្រឡាញ់ អាចញ៉ាំងអត្តទត្ថបុគ្គល អោយមានការផ្លាស់ចិត្តគំនិតបានដោយគេភ្ញាក់រលឹកទៅលើភាព "អញ " រឺមានតែអញ ហើយគេមានឆន្ទៈវៀរចាកកំហុសគេ ។

---

(១) - នៅពេលដែលអ្នកស្រុកនៅវត្តខ្លះ សូត្រធម៌បាលី ប្រែជាភាសាខ្មែរ ។

## គ. សេចក្ដីស្មោះ (La sincérité )

ការពោលពាក្យកុហក ញុះញង់ បំបែកបំបាក់ បោកប្រាស់ និយាយដើមគេ បង្អាប់បន្ថោកគេ បង្ខូចកេរ្តិ៍ឈ្មោះអ្នកដទៃ ជាអំពើមួយផ្ទុយស្រឡះពីតំលៃជាមូលដ្ឋានសមធម៌ បានសេចក្ដីថា មិនគោរពអ្នកដទៃ មើលងាយអ្នកដទៃ ។ សីលធម៌តំរូវអោយនិយាយដោយស្មោះ គឺមិនលំអៀងពីការពិត ។ ក៏ប៉ុន្តែ នៅក្នុងស្ថានភាពមួយ ពិសេស ត្រូវតែចេះភូតកុហកខ្លះដើម្បីដោះខ្លួនអោយផុតពីសេចក្ដីស្លាប់ ពីការចាប់ចងធ្វើទារុណកម្ម ។

ភាសិតបារាំងមួយចែងថា " ពាក្យពិតទាំងអស់ មិនមែនត្រូវតែនិយាយនោះទេ " " Toute vérité n'est pas bonne à dire " ភាសិតខ្មែរចែងថា " ពាក្យពិតវែងស្លែង " ។

ចំពោះរឿងនេះ បងប្អូនដែលបានរស់នៅក្នុងគុកឥតជញ្ជាំងបានជ្រាបអស់ហើយ ។ គេថា ពេលនោះ នរណាចេះភូត ទើបបានរស់ គឺត្រូវតែចេះលាក់ប្រវត្តិរូប ដូចជា ទាហាន, អ្នករដ្ឋការ តូច ធំ, សិស្ស, និស្សិត, ព្រោះអ្នកអស់នោះ, ចូលក្នុង " បញ្ជីខ្មៅ " " អង្គការ " ត្រូវតែកំទេច ។

ពួកក្រុមពេជ្ឈឃាត សំឡុតអោយនិយាយអោយស្មោះ កុំក្បត់នឹង " អង្គការ " ។ ប៉ុន្តែពេលនោះ សភាពការណ៍មិនជំរុញអោយនិយាយពាក្យពិត ។ ត្រូវតែភូត ។ ត្រូវចេះធ្វើឫកពាជាកសិករ ជាអ្នករកស៊ីដោយកំលាំងញើស ដូចជា ធាក់ស៊ីក្លូ, លីបាវ, អ្នកបើកបរឡានឈ្នួល ។ល។

ដូចខ្ញុំជំរាបហើយថា សីលធម៌ប្រែប្រួល និងមិនស្លាប់ស្លូកនោះទេ ។ វាវេទៅតាមពេលមានអាសន្ន ដើម្បីរំដោះខ្លួនអោយរួចពីសេចក្ដីស្លាប់ ។

## ឃ. សេចក្ដីស្មោះត្រង់ (La fidèlité )

សេចក្ដីស្មោះត្រង់ គឺឆន្ទៈនិងអំពើស្របគ្នាជាមួយសំដី និងមនោសញ្ចេតនា ។ គឺជាការអនុវត្តជាក់ស្តែងនៃសច្ចធម៌ដែលនាំអោយកិច្ចសន្យាអ្វីទាំងពួង និងកាតព្វកិច្ចអ្វីផ្សេងៗ បានសំរេចដូចប្រាថ្នា ។ វាតំរូវអោយយើងបំពេញករណីយកិច្ច និងកាន់ខ្ជាប់នូវពាក្យសន្យា ។ អ្នកមានចិត្តមិននឹងនរ ម្ដងថាដូច្នេះ ក្រោយមក ត្រឡប់ជាប្រែក្រឡាស់ថាដូច្នោះវិញ មិនសមស្របនឹងលក្ខណៈវិនិច្ឆ័យសមធម៌ឡើយ ។

នរណាមានវាចាអាចអោយអ្នកដទៃទុកចិត្តបាន អ្នកនោះជាអ្នកមានសីលធម៌ ។

## ង. សេចក្ដីទៀងត្រង់ (L'honnêteté )

សេចក្ដីទៀងត្រង់ ជាអំពើទាំងឡាយដែលប្រព្រឹត្តបានយ៉ាងម៉ត់ចត់ត្រឹមត្រូវ តាមមាគ៌ាសីលធម៌ នឹងសម្មាអាជីវៈកំណត់ដោយសមធម៌ ។ ឧទាហរណ៍ : បញ្ញវ័ន្តដែលមិនក្បត់សម្បជញ្ញៈរបស់ខ្លួនជាអ្នកត្រឹមត្រូវ ជាអ្នកទៀងត្រង់ ។

យ៉ខ ឌី

# ០៧ អំពីសករាជ

សករាជ មានពាក្យ សកៈ និង រាជ ។ សកៈមានន័យថា កាលសម័យ ការរាប់លំដាប់ឆ្នាំ រឺយុគ ។ រាជ មាន ន័យថា ស្តេច រឺអធិរាជ ឬបុគ្គល ។

សករាជ មានន័យថា ការរាប់ថ្ងៃខែឆ្នាំ រឺយកត្រឹមតែឆ្នាំរៀងមក ដែលបុគ្គលអស្ចារ្យ រឺហេតុអស្ចារ្យណាមួយជាកេណ្ឌ (១) ។

ក្នុងជំនាន់ដើម គេប្រើត្រឹមតែ សកៈ ប៉ុណ្ណោះ ។ លុះសម័យក្រោយមក ប្រមាណក្នុងសម័យឧដុង្គ ទើបមានប្រើជា សករាជ ដល់សព្វថ្ងៃនេះ ។

## សករាជមាន ៤ យ៉ាងគឺ :

១. ពុទ្ធសករាជ

២. គ្រិស្តសករាជ

៣. មហាសករាជ

៤. ចុល្លសករាជ

## ប្រវត្តិពុទ្ធសករាជ

ពុទ្ធសករាជ ជាសករាជដែលរាប់ចំនួនថ្ងៃខែឆ្នាំ ពីថ្ងៃពុធ ១ រោច ខែវិសាខ ឆ្នាំម្សាញ់ ក្រោយថ្ងៃដែលព្រះសម្មាសម្ពុទ្ធទ្រង់ព្រះនាមសមណគោតម បរិនិព្វានទៅបានមួយថ្ងៃរៀងមក ។

ព្រះសម្មាសម្ពុទ្ធទ្រង់បរិនិព្វាននៅថ្ងៃអង្គារ ១៥ កើត ខែវិសាខ ឆ្នាំម្សាញ់ ។ ហេតុនោះ បានជារាប់ពីត្រឹមថ្ងៃ ១ រោច ខែវិសាខ ឆ្នាំម្សាញ់ មកជាកេណ្ឌ ។ ពុទ្ធសករាជ សរសេរអក្សរកាត់ថា ព.ស ។

សម័យបុរាណព្រះសង្ឃ ពុទ្ធសាសនិកគ្រប់វត្តអារាមក្នុងប្រទេសកម្ពុជាយើង នារដូវចូលវស្សា ៣ ខែ រៀងរាល់ឆ្នាំ បន្ទាប់ពីស្វាធ្យាយធម៌វេនតាមកិច្ចវត្តប្រចាំថ្ងៃរួមគ្នា នៅក្នុងរោងឧបោសថរួចហើយ ភិក្ខុជាព្រះថេរៈ រឺភិក្ខុអង្គណាមួយដែលចេះស្ទាត់ជំនាញ លោកសូត្របកពុទ្ធសករាជរាល់ថ្ងៃ ។ ម្យ៉ាងវិញទៀត ភិក្ខុសង្ឃជាធម្មកថិក សំដែងធម៌ទេសនាក្នុងពិធីបុណ្យធំៗ មានបុណ្យពុទ្ធាភិសេក បុណ្យបញ្ចុះសីមាជាដើម មុននឹងសំដែង លោកសូត្របកពុទ្ធសករាជជាមុនសិន ដើម្បីជាកិច្ចគោរព និងនឹករលឹកដល់ថ្ងៃខែឆ្នាំ ដែលព្រះសម្ពុទ្ធទ្រង់បរិនិព្វាន ដោយមានសទ្ធាច្បាស់ថា នឹងបានផលានិសង្សច្រើន ។

---

(១) - កេណ្ឌ : អានថា កែន បានសេចក្តីថា : បង្គាប់ , កំនត់ , សំគាល់ , ។

## ប្រវត្តិគ្រិស្តសករាជ

គ្រិស្តសករាជ កើតឡើងក្រោយពុទ្ធសករាជចំនួន ៥៤៣ ឆ្នាំ ដោយសាស្តាម្នាក់ឈ្មោះ យេស៊ូ រឺ យេស៊ូគ្រិស្ត ជាអ្នកបង្កើតសាសនាគ្រិស្ត ។ យេស៊ូកើតនៅប្រទេសអ៊ីស្រាអែល(១) ក្នុងសតវត្សរ៍ទី ៦ នៃពុទ្ធសករាជ (ព.ស ៥៤៣) ទទួលមរណភាពក្នុងពុទ្ធសករាជ ៥៣៦ ក្នុងជន្មាយុ ៣៣ ឆ្នាំ ។ គ្រិស្តសករាជ រាប់ពីត្រឹមឆ្នាំកំណើតយេស៊ូ ជាកាលកំនត់ ។

គ្រិស្តសករាជ សរសេរអក្សរកាត់ថា : **គ.ស** ។

## ប្រវត្តិមហាសករាជ

មហាសករាជ កើតឡើងក្នុងរាជព្រះបាទសកៈ រឺ សាលីវាហនៈ នៅក្នុងប្រទេសឥណ្ឌា ក្នុងព.ស ៦២១ ដោយប្រារព្ធយកជ័យជំនះយ៉ាងសម្បើមរបស់ក្សត្រិយ៍អង្គនេះជាកេណ្ឌ ។ ប៉ុន្តែ ក្នុងជំនាន់មុន ហៅត្រឹមតែស័ក រឺ សករាជ ប៉ុននោះ ។ លុះខាងក្រោយមក មានសករាជថ្មីកើតឡើងទៀត ទើបហៅសករាជព្រះចៅសាលីវាហនៈថា មហាសករាជ ។

មហាសករាជ សរសេរអក្សរកាត់ថា ម.ស ។

ក្នុងព្រះរាជពង្សាវតារខ្មែរថា ព្រះបាទសម្តេចព្រះអរិជ្ជពលពាហនោព្រះកេតុមាលាសូរ្យវង្ស បានតាំងមហាសករាជ ១ ក្នុងព.ស ៦២១ ឆ្នាំ ។

ព្រះបាទសម្តេចព្រះសិទ្ធពរអមរិន្ទ បរមព្រហ្មកិល (ពញាក្រែក) បានតាំងសករាជ ១ ក្នុង ព.ស ១១៨១ ឆ្នាំ ។

ក្នុងពង្សាវតានគរជៀងហៃ (លាវ) ថា ព្រះបាទពន្ទុមតីក្នុងប្រទេសលង្កា ទ្រង់តាំងមហាសករាជនេះឡើង ។ តែបើតាមការពិតនោះ គឺព្រះបាទសាលីវាហន ទ្រង់តាំងឡើងហើយ ព្រះបាទពន្ទុមតីគ្រាន់តែយកទៅប្រកាសប្រើក្នុងប្រទេសខ្លួនប៉ុននោះ ។

## ប្រវត្តិចុល្លសករាជ

ស្តេចភូមាទ្រង់ព្រះនាម សង្ឃរាជ រឺហៅថាបុព្វសោរហន៍ ជាក្សត្រិយ៍ទី ១៩ ក្នុងវង្សសមុទ្ទរិទ្ធី ទ្រង់តាំងឡើង (ក្នុងឆ្នាំកុរ ហើយរាប់ឆ្នាំជាឯកស័ក) ក្នុងព.ស ១១៨២ ដោយយកសុរិយគតិ គឺពេលប្រជុំបខ្ចូននៃព្រះអាទិត្យ ដែលគោចរចេញអំពីមេសរាសី ហើយត្រលប់ចូលមេសរាសីវិញជាកេណ្ឌ ។

ឯការដែលប្រើពាក្យថា ឯកស័ក, ទោស័ក, ត្រីស័ក, ចត្វាស័ក, បញ្ចស័ក, ឆស័ក, សប្តស័ក, អដ្ឋស័ក, នព្វស័ក, សំរិទ្ធិស័ក ប្រកបនឹងឈ្មោះឆ្នាំទាំង ១២ គឺ ជូត, ឆ្លូវ, ខាល, ថោះ, រោង, ម្សាញ់, មមី, មមែ, វក, រកា, ច, កុរ, ក៏កើតឡើងក្នុងវេលាដែលកើត ចុល្លសករាជ នេះដែរ ។

ឈ្មោះស័កចំនួន ១០ ឈ្មោះ ឆ្នាំចំនួន ១២ មិនស្របគ្នារៀងរហូតទេ គឺរយៈពេល ៦០ ឆ្នាំ ទើបស្របគ្នាម្តង ។

ឧទាហរណ៍ : ឆ្នាំនេះជាឆ្នាំខាល សំរិទ្ធិស័ក ព.ស ២៥៤២ លុះដល់ព.ស ២៦០២ ទើបឆ្នាំខាលប្រកបនឹងសំរិទ្ធិស័កម្តងទៀត ។

ទំនៀមទំលាប់ចូលឆ្នាំខ្មែរ ក្នុងខែ មេសា គឺត្រូវនឹងខែចេត្រតាមចន្ទគតិ ក៏កើតមានឡើងក្នុងសម័យដែលកើតចុល្លសករាជនេះដែរ ។

---

(១) - នៅណាហ្សារ៉េត (Nagareth) ក្នុងខេត្ត Galilée ស្ថិតនៅខាងជើងប្រទេសបាឡេស្ទីន ។

ចុល្លសករាជ សរសេរអក្សរកាត់ ច.ស ។

សករាជ ទាំង ៤ នេះ សម័យនេះនិយមប្រើតែពុទ្ធសករាជ និង គ្រិស្តសករាជ ។ ពុទ្ធសករាជ ប្រើក្នុងកិច្ចការពុទ្ធសាសនា, គ្រិស្តសករាជ ប្រើក្នុងកិច្ចការរដ្ឋបាល លិខិតស្នាមផ្សេងៗ -ល- និងប្រើជាអន្តរជាតិ ។ រីឯមហាសករាជ និង ចុល្លសករាជ សម័យនេះ មិនមានប្រើជាផ្លូវការអ្វីទេ ប៉ុន្តែ យើងបានរក្សាទុកក្នុងសៀវភៅមហាសង្ក្រាន្ត និងប្រតិទិនប្រចាំឆ្នាំ ដើម្បីមិនអោយបាត់បង់ប៉ុននោះ ។

លោក អ៊ុយ សុន
នាយកសាលាបឋមសិក្សាព្រែកកំពីស
ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល

**គេអោយកិត្តិយសទៅឃ្មុំ ពីព្រោះវាធ្វើការ**
**ពុំមែនដើម្បីតែខ្លួនវាឡើយ គឺដើម្បីសំបុកទាំងមូល ៗ**

សុភាសិតគ្រិត សវ ទី ២

# ទោចយំ *

៙-៚-៙

កាលណាព្រះអាទិត្យរះឡើង នៅក្នុងព្រៃស្តុកហ៊ុំព័ទ្ធអង្គរវត្តប្រាសាទបុរាណខ្មែរ សម័យទសវត្ស ៥០ សំលេងគ្រលួចលន់លឺរំពងព្រៃ ។ ពេលព្រលឹមស្រាងៗ នៅលើចុងឈើ ទោចយំអបអរសាទរ ចំពោះពន្លឺក្រហមនៃវត្តមានព្រះទិនករ ។

អ្នកខ្លះនិយាយថា ទោចយំហាក់បីដូចសំលេងកូនឆ្កែវាលូរ រឺសំលេងព្រាបថ្ងូរ អ្នកខ្លះទៀតថា ទោចយំហាក់បីដូចសូរតំអូញរបស់អ្នកចំរៀងនៅមហាសាល មហោស្រពអូប៉េរ៉ា " OPERA " ទីក្រុងប៉ារីស ប្រទេសបារាំង ... ការសន្និដ្ឋានទាំងអស់នេះ ជាសំនៀងទោចយំ ។ សំលេងទោចយំធ្វើអោយយើងចាប់អារម្មណ៍ជាខ្លាំង ជាងសំលេងផ្សេងៗទៀត ដែលកើតមាននៅក្នុងធម្មជាតិ ហើយយើងក៏មិននឹកស្មានថា អង្គរសមបើស្ថិតនៅក្នុងព្រៃសំសាន្តដូច្នេះសោះ ។ តាមការពិត សត្វទោចមិនមែនជាសត្វស្វាបទេ តែវាជាអំបូរសត្វស្វា គឺប្រភេទសត្វស្វាមិនរពិស មានលក្ខណៈសម្បទនឹងធំ ឯស្វារិញរបុិលរប៉ូច ។ សត្វទោចមានភ្នែកធំៗ មូល ដុះព័ទ្ធជុំវិញដោយរោមពណ៌ស ។ ទោចឈ្មោលមានសំបុរខ្មៅ រឺឯញី និងកូនតូច មានសំបុរពណ៌ស្គរត្នោត ។ ទំនួញសត្វទោច សំរាប់ជីវិតរស់នៅរបស់វា វាយំដើម្បីពញាក់ប្រាប់កូនចៅវាថា មានអាសន្នហើយ រឺវាយំដើម្បីផ្តោះផ្គងសេចក្តីស្នេហារវាងញី និងឈ្មោល ។ ពួកវារស់នៅតាមគ្រួសារ ហាក់បីដូចប្តីប្រពន្ធ ប្តូរផ្តាច់ចិត្តថែរក្សាគ្នាអស់មួយជីវិត ។ ក្នុងរយៈពេលរួមរស់ជាមួយគ្នា ៣ ទៅ ៤ ឆ្នាំ ទើបទោចញីបង្កើតកូនបានម្តង គឺកូនទោល ដែលវាបានពរពោះ ២១០ ថ្ងៃ ។ កូនទោចរស់នៅជាមួយមេបាវា រហូតដល់អាយុ ៨ ឆ្នាំ លុះត្រាវាចេះរកស៊ីហើយ ទើបវាបែកចេញ សមស្របនឹងពេលវេលាដែលវានេះចេះយំផងដែរ ។ ដោយឡែក សត្វទោចមានជីវិតរស់នៅ និងបន្តពូជពង្សនៅក្នុងព្រៃឧបទ្វីបអាស៊ីនេះ ចាំបាច់ត្រូវចេះយំ ដែលជាមធ្យោបាយរបស់ពួកវា សំរាប់ការពារសត្រូវ និងពង្រីកវិសាលភាពទឹកដីការពារពូជ និងបងប្អូនវា តាមរយៈសំលេងយំគ្រលួចនេះ ។ សំលេងយំរបស់ទោចឈ្មោល លន់ខ្ទរពេញព្រៃ ពង្រីកបរិមាណអំនាចនៅលើទឹកដីនោះ អោយពួកទោចរស់នៅប្រកបដោយសុវត្ថិភាព និងការពារពង្សវង្សត្រកូលទៅវិញទៅមកផង ។ ក្នុងឆាកជីវិតរបស់ទោច មេបារបស់វាយំមានពីរបែប ដែលប្រៀបបាននឹងឧបករណ៍ភ្លេងមានសំលេងតែពីរ គឺសំលេងគរ និង សំលេងឯក ។ ពេលព្រឹកព្រហាម ជាអចិន្ត្រៃយ៍ ទោចតោងមែកឈើតែដៃម្ខាង ព្យួរខ្លួននៅក្នុងអាកាស ស្រែកយំពេញព្រៃ ធ្វើអោយយើងហ៊ឹងត្រចៀកស្តាប់អ្វីមិនបាន ក្នុងរយៈពេលមួយម៉ោង ។ ពេលនោះ យើងអាចដឹងបានថា ទីនោះជាព្រៃពួកទោចប៉ុននោះ ។ ទោចឈ្មោលក៏វាចង់សន្មតថា ជាទីកន្លែង និងអំនាចរបស់វាពេញលេញនៅទីនោះដែរ គ្មានអ្វីមករំខានសេចក្តីសុខរបស់វាទេ ។ វាយំមួយបែបទៀត តាមសូរគ្រលួចខ្លាំង គឺវាហៅទោចញីអោយមកក្បែរវា ។ ទោចញីណាមួយមិនទាន់មានពាក់ព័ន្ធនឹងឈ្មោលណាទេ ហើយដល់វ័យត្រូវមានគូស្រករផង ក៏បង្ហាញរីកពារអោយទោចឈ្មោលដឹង ។ ទោចឈ្មោលក៏បន្លឺសំលេងគ្រលួចឡើង ដើម្បីអបអរសាទរ ។ គេទាំងពីររួមរស់ជាមួយគ្នា លុះត្រាអស់ជីវិត ហើយក៏យំរកគ្នាទៅវិញទៅមក តាមសំលេងពីរបែប លុះអវសាននៃជីវិតដោយៗខ្លួន ។ គ្រប់

(*) - គេហៅសត្វទោចប៉ុននេះក៏បាន ។ គ្រប់សត្វទោច ចេះយំទាំងអស់ ។

សំរែករបស់ទោច កូនទោចផ្ទៀងត្រចៀកស្តាប់ តើសំលេងណាមួយរបស់មេបាវា ដើម្បីចងចាំអោយបាន និងសំលេងស្រួចស្រាវរបស់មេវា ដែលមានការខុសឆ្គងគ្នាបន្តិចបន្តួចពីទោចដទៃ ។ ពេលខ្លះកូនទោចរក្សាការស្ងៀមស្ងាត់ ដូចជាប្រុងប្រៀបអ្វីមួយ ហើយក៏រៀនបញ្ចេញសូរ តាមលក្ខណៈពីរប្រភេទ ដែលមេបាវាតែងតែយំ ។ ទោចបាលួចមើលកូន ដែលខំធ្វើត្រាប់តាមវា ដូចជាយំ លោតផ្លោះពីមែកមួយទៅមែកមួយ និងហក់ពីដើមឈើមួយទៅដើមឈើមួយទៀត ដោយប៉ិនប្រសប់ ហើយនោះ ទើបវាអោយបំបែកខ្លួនចេញពីគ្រួសារ ។ ពីដើមឈើមួយទៅដើមឈើមួយ សត្វទោចលោតហក់ហោះទៅតោងដោយរហ័សរហួនបំផុត ហើយវាអាចហើរបានទៀតផង ។ តាមធម្មតា ទោចឈ្មោលដឹកនាំគ្រួសារវាអោយចេះលោត ហក់ ហោះទៅតោងមែកឈើរឹងទន់ ពីកំពស់ចុះមកក្រោម ពីក្រោមឡើងទៅកំពស់វិញ និងឈានទៅអនុវត្តសកម្មភាពនេះបានចំងាយ ៣០ គីឡូម៉ែត្រក្នុងមួយម៉ោង ។ ទោចញីត្រូវរត់តាមទោចឈ្មោលដោយគ្មានអល់អែក រឺគ្មានហត់នឿយអ្វីឡើយ វាយកទៅជាមួយនូវកូនតូចដែលដៃវាម្ខាងអោបនៅក្រោមពោះ ។ ពេលស៊ីផ្លែឈើ ពេលសំរាក វាផ្អាកការលោតផ្លោះ និងហោះហើរ ។

ទោចរស់នៅតែលើដើមឈើ កាលណាវាធ្លាក់ដី វាដើរជើងពីរ លែងឡើងទៅវិញហើយ តែដៃម្ខាងរបស់វា ចេះតែលើកឡើងលើ ហាក់បីដូចជាចង់ឡើងដើមឈើវិញ ។



ប្រែសំរួលពីអត្ថបទរបស់លោក
**SYLVAINE DE DAULIN ( OKADI 94 )**
ដោយលោក **ឌិ សាវ៉ាន់**
ធ្វើការនៅមន្ទីរ អ.យ.ក ខេត្តកំពង់ចាម

<u>**សេចក្ដីបញ្ជាក់**</u> : សូមជំរាបលោក ឌិ សាវ៉ាន់ និងអស់លោកគ្រូ-អ្នកគ្រូថា សត្វទោចមិនទាន់បាត់បង់ពូជអស់ពីទឹកដីកម្ពុជានៅឡើយទេ មិនដូចលោកសាវ៉ាន់ មានប្រសាសន៍នោះឡើយ ។ សព្វថ្ងៃនេះក្រសួងកសិកម្មរុក្ខាប្រមាញ់ បានចិញ្ចឹមសត្វនេះនៅភ្នំតាម៉ៅ ស្រុកបាទី ខេត្តតាកែវ ដូចរូបថតផ្ដិតជាប់មកជាមួយនេះ ។




# គោលវិធីសិស្សមជ្ឈមណ្ឌល

## ( HUMANISTIC APPROACH )

**ទត្ថុបំណង :**

- ផ្តល់ចំនេះដឹងជាក់ច្បាស់អំពីគោលវិធីសិស្សមជ្ឈមណ្ឌល
- ផ្តល់បំនិនក្នុងការអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល
- បណ្តុះឥរិយាបថចូលចិត្ត និងយកគោលវិធីសិស្សមជ្ឈមណ្ឌលមកអនុវត្តក្នុងសកម្មភាពបង្រៀនរបស់ខ្លួន ។

### ១- គោលទិធីជាអ្វី ? ( គោលវិធី = Approach )

គោលវិធីជាពាក្យដែលយើងបានយកមកប្រើ ដើម្បីសំគាល់នូវគោលការណ៍មួយ ទស្សនៈមួយ ឬជំនឿមួយរបស់យើង ដូច្នេះ " គោលវិធីសិស្សមជ្ឈមណ្ឌល " ជាគោលការណ៍បង្រៀនមួយដែលមានទស្សនៈ " មនុស្សនិយម [១] " ជាមូលដ្ឋានគ្រឹះ ។ លោក Carl Roger (USA 1902 – 1972) ជាអ្នកបានរកឃើញទស្សនៈនេះ ។ ទ្រឹស្តីរបស់គាត់មានគោលបំនងជួយមនុស្សអោយមានសមត្ថភាពជួយខ្លួនឯង ។ ដូច្នេះគាត់បានកំនត់ថា " យើងជួយតែមនុស្សណាដែលមានសំនូមពរអោយជួយ " « ការជួយមិនបានផលល្អទេ ក្នុងករណីដែលមនុស្សនោះមិនទាន់មានបំនងចង់អោយជួយ រឺមានបំនងចង់អោយមានសមត្ថភាព ដើម្បីជួយខ្លួនឯង » ពីព្រោះបែបនេះ មិនអាចដើរដោយខ្លួនឯង រឺម្ចាស់ការនៅពេលអនាគត ។ តាមរយៈស្នាដៃជាច្រើនរបស់គាត់បានបញ្ជាក់យ៉ាងច្បាស់ថា ការអប់រំត្រូវតែផ្សារភ្ជាប់ជាមួយការគោរព ការផ្តល់សេរីភាព និងផ្តល់សិទ្ធិដល់អ្នកសិក្សាអោយធ្វើសកម្មភាពទំនាក់ទំនងគ្នា ធ្វើការពិសោធន៍ និងធ្វើការសំរេចចិត្តដោយផ្ទាល់ខ្លួនរបស់គេ ។ លោកគ្រូត្រូវតែ

---

(១) - ជាទ្រឹស្តីទស្សនវិជ្ជាមួយ ដែលអោយតំលៃមកលើមនុស្ស ។ កាលណាមានការលើកទឹកចិត្ត ទទួលស្គាល់ រឺគោរពមនុស្សដូចគ្នានោះ មនុស្សនឹងមានកំលាំងផ្លូវចិត្តមួយ ដែលជំរុញអោយមនុស្សនោះមានលក្ខណៈសកម្ម និងមានភាពម្ចាស់ការ ។

អោយតំលៃសិស្សក្នុងនាមជាមនុស្ស ទទួលស្គាល់ការរីកចំរើនតាមរយៈការអប់រំ និងការសាកល្បងរបស់គេ ។ នៅក្នុងគោលវិធីសិស្សមជ្ឈមណ្ឌល លោកគ្រូមានជំនឿជាក់ទៅលើសមត្ថភាពរបស់សិស្ស ក្នុងការដោះស្រាយបញ្ហាផ្ទាល់របស់គេ ។

**ឧទាហរណ៍** : លោកគ្រូមិនត្រូវបង្ខំអោយសិស្សជឿតាមមតិរបស់ខ្លួន ហៅអោយសិស្សកត់តាមមតិរបស់ខ្លួន ដើម្បីអោយសិស្សយល់តាម ទន្ទេញអោយចាំមាត់នៅពេលដែលសិស្សមិនទាន់បានពិសោធន៍ វិភាគប្រៀបធៀប និងធ្វើការសំរេចចិត្តនោះទេ ព្រោះការធ្វើបែបនេះ ពុំបានរួមចំនែកធ្វើអោយការគិតរបស់សិស្សរីកចំរើនឡើយ ។

" គោលវិធីមនុស្សនិយម " ត្រូវបានយកមកអនុវត្តក្នុងសាលារៀន ក្នុងអង្គប្រជុំ ក្នុងការព្យាបាលជំងឺ និងក្នុងសាលាបណ្តុះបណ្តាលនានា និងក្នុងសង្គម ។

**ឧទាហរណ៍** :

ក- ក្នុងអង្គប្រជុំ : ប្រធានអង្គប្រជុំត្រូវបែងចែកសមាជិកអង្គប្រជុំជាក្រុមល្អិត១ រួចហើយផ្តល់ឱកាសអោយបានច្រើនបំផុត ដើម្បីសមាជិកអង្គប្រជុំប្តូរយោបល់ដោះស្រាយបញ្ហា តាមរយៈការស្តាប់មតិគ្នាទៅវិញទៅមក ។

ខ- ក្នុងការព្យាបាលជំងឺ : លោកគ្រូពេទ្យប្រើកាយវិការរាក់ទាក់ គោរពអ្នកជំងឺ សំនេះសំនាលជាមួយអ្នកជំងឺ ដើម្បីធ្វើអោយអ្នកជំងឺមានសេចក្តីសង្ឃឹម ព្រមទាំងប្រព្រឹត្តនូវអំពើទាំងឡាយដែលពង្រឹងសុខភាពដោយខ្លួនឯង ។ ពោលគឺលោកគ្រូពេទ្យជួយអ្នកជំងឺអោយចេះការពារ និងថែរក្សាសុខភាពដោយខ្លួនឯង ។

គ- ក្នុងសកម្មភាពអប់រំប្រជាជន ដើម្បីលើកកំរិតជីវភាពរបស់គាត់ អង្គការអន្តរជាតិតែងតែផ្តល់អង្ករ ប្រាក់កាស និងការអប់រំជាជំហ៊ាន១ដល់ពលរដ្ឋទាំងឡាយណា ដែលមានសេចក្តីក្លាហាន ចេះជួយខ្លួនដោយខ្លួនឯង ព្រមទាំងមានសំនូមពរអោយអង្គការនោះជួយ ។

ឃ- ក្នុងសកម្មភាពរៀនសូត្រ : លោកគ្រូមិនមែនយកសកម្មភាពបង្រៀនជាធំទេ ប៉ុន្តែ គាត់យកសកម្មភាពរៀនសូត្ររបស់សិស្សជាសកម្មភាពធំ ។ លោកគ្រូមិនមែនជាអ្នកប្រាប់ការពិតត្រង់១តែម្តងដល់សិស្សទេ ប៉ុន្តែ គាត់ជាអ្នកជួយដល់សិស្សមានចំងល់ ចង់ចេះ ចង់ដឹង ពោលគឺ លោកគ្រូជាអ្នកដឹកនាំសកម្មភាពរៀន និងជាអ្នកជួយសិស្សកែលំអកិច្ចការសិស្ស ។

**ឧទាហរណ៍** : ដើម្បីផលិតគំនិតដល់សិស្ស លោកគ្រូបង្ហាញរូបភាព រួចហើយចោទជាសំនួរដឹកនាំការសង្កេតរបស់សិស្ស រឺ នាំសិស្សធ្វើទស្សនៈកិច្ចសិក្សា រឺលោកគ្រូនិទានរឿង ដើម្បីដឹកនាំសិស្សធ្វើការសង្ខេប ធ្វើការវិភាគ និងទាញយកបញ្ញត្តិអរូបិយ រឺពាក្យស្លោក ។ល។ រួចនាំសិស្សធ្វើលំហាត់នុវត្ត ។

ង- ក្នុងសង្គមជាតិ : ការចិញ្ចឹមបីបាច់កូនចៅ ទាមទារអោយមានដំណាក់កាល ដែលឪពុកម្តាយបណ្តោយអោយកូនជឿលើសមត្ថភាពខ្លួន រៀនដោះស្រាយបញ្ហាជីវិតដោយខ្លួនឯង ដើម្បីផ្តាច់ការពឹងពាក់លើឪពុកម្តាយជាជំហ៊ាន១ ។

## ២- តួនាទីរបស់លោកគ្រូ-អ្នកគ្រូ ក្នុងពេលអនុវត្តគោលវិធីសិស្សមជ្ឈមណ្ឌល

### ក- លោកគ្រូ-អ្នកគ្រូជាអ្នកធ្វើផែនការ (Planner)

- គ្រូត្រូវតែគំនត់ជាមុន វត្ថុបំនងនៃមេរៀន និងធ្វើផែនការបង្រៀន រឺកិច្ចតែងការបង្រៀន ។

- គ្រូជាអ្នកគ្រោងទុកជាស្រេចនូវរូបភាព សំនួរ និងរយៈពេលដែលសិស្សត្រូវធ្វើសកម្មភាព ព្រមទាំងបញ្ជាក់អោយបានច្បាស់ អំពីតួនាទីរបស់សិស្ស ដែលត្រូវធ្វើសកម្មភាពអ្វីខ្លះ អោយបានច្បាស់ជាមុន ដូចជារកសំភារៈសង្ខេបខ្លឹមសារ-ដោះស្រាយសំនួរ ។ល។

ខ- <u>លោកគ្រូ-អ្នកគ្រូជាអ្នកសំរបសំរួល</u> (Facilitator )

- លោកគ្រូជាអ្នកធ្វើអោយសកម្មភាពរៀនសូត្ររបស់សិស្សកើតមានឡើង ប៉ុន្តែ លោកគ្រូមិនមែនជាអ្នកបង្ខិតបង្ខំ រឺធ្វើសកម្មភាពជំនួសសិស្សទេ ។ លោកគ្រូផ្តល់ការណែនាំច្បាស់លាស់អំពីលំនាំសកម្មភាព ប៉ុន្តែធ្វើជាអ្នកមិនចេះចំពោះខ្លឹមសារនៃមេរៀន ដើម្បីទុកឱកាសអោយសិស្សខិតខំគិតពិចារណា ។

- លោកគ្រូរក្សាទំនាក់ទំងជាមួយសិស្សទូទាំងថ្នាក់ ព្រមទាំងធ្វើសកម្មភាពជួយដើម្បីធ្វើអោយសកម្មភាពរបស់សិស្សកើតមានឡើង ។

- លោកគ្រូ-អ្នកគ្រូជាកត្តាសំខាន់ក្នុងការសំរបសំរួល ធ្វើអោយសកម្មភាពចូលរួមរបស់សិស្សចំនួនដ៏ច្រើនកើតមានឡើង ។

**<u>ឧទាហរណ៍</u>** : ប្រសិនបើសិស្សក្នុងក្រុមណាមួយអសកម្ម លោកគ្រូចូលទៅជួយភ្លាម ។

គ- <u>លោកគ្រូជាអ្នកដឹកនាំ</u> (Leader ) : ដឹកនាំដោយផ្ទាល់ និងដឹកនាំដោយប្រយោល

លោកគ្រូត្រូវពន្យល់អោយសិស្សយល់អំពីវត្ថុបំនងរបស់សកម្មភាពខ្លួន ក៏ដូចជាវត្ថុបំនងរបស់មេរៀន ព្រោះតាមរយៈការយល់វត្ថុបំនងនេះ សិស្សក្លាយទៅសកម្ម ក្រោមបញ្ជោមនសិការផ្ទាល់របស់គេ ទោះបីនៅក្នុងថ្នាក់រៀនក្តី នៅក្រៅថ្នាក់រៀនក្តី ( ការដឹកនាំដោយប្រយោល) លោកគ្រូ-អ្នកគ្រូ ផ្តល់ឱកាសគ្រប់គ្រាន់សំរាប់សិស្សបញ្ចេញមតិ ត្រិះរិះដោះស្រាយបញ្ហា ។

- លោកគ្រូផ្តល់សេរីភាពក្នុងការបញ្ចេញមតិរបស់សិស្ស និងស្តាប់មតិរបស់អ្នកដទៃ ព្រមទាំងធ្វើការសំរេចចិត្តទៅតាមមតិរួមរបស់ក្រុម ពុំមានការបង្ខិតបង្ខំអោយជឿតាមមតិរបស់លោកគ្រូទេ ពោលគឺ ទុកអោយសិស្សមានភាពរីកចំរើន (បំនិនគិត-បំនិនវិភាគ-បំនិនវាយតំលៃ) តាមរយៈបទពិសោធន៏ ការសង្កេតបាតុភូតជាក់ស្តែង ទើបទៅដល់បញ្ញត្តិនោះ ។

- លោកគ្រូដឹកនាំ ក៏មានន័យផងដែរថា លោកគ្រូលើកទឹកចិត្តសិស្សអោយចូលរួមសកម្មភាព ព្រមទាំងធ្វើអោយសិស្សពេញចិត្តចំពោះលទ្ធផលដែលខ្លួនបានប្រឹងប្រែង ព្រមទាំងលើកទឹកចិត្តអោយសិស្សមានសេចក្តីក្លាហាន ប្រឹងប្រែងបន្តទៅទៀត ។ គ្រូត្រូវដឹកនាំការគិតពិចារណារបស់សិស្ស ។

ឃ- <u>លោកគ្រូជាអ្នកត្រួតពិនិត្យតាមដាន</u> (Monitor )

លោកគ្រូជាអ្នកដើរតាមដានក្នុងក្រុមនីមួយៗ ដើម្បីចាត់ចែង ត្រួតពិនិត្យ និងវាយតំលៃលើភាពរីកចំរើនរបស់សិស្ស ។ ចំពោះតួនាទីនេះ លោកគ្រូត្រូវនៅស្ងៀមមួយរយៈ មិននិយាយស្តី ដើម្បីទុកឱកាសសិស្សបានធ្វើសកម្មភាព ។

ដូច្នេះគោលវិធីសិស្សមជ្ឈមណ្ឌល (Student Centred Approach) ជា "ទស្សនៈមនុស្សនិយម" (Humanism) មួយដែលយើងជឿ និងវាយតំលៃមកលើសិស្ស ព្រមទាំងគោរព និងមានទំនុកចិត្តទៅលើសមត្ថភាពរីកចំរើនរបស់សិស្ស ក្នុងការដោះស្រាយបញ្ហាដោយខ្លួនគេ ។ ទ្រឹស្តីមនុស្សនិយម រឺគោលវិធីមនុស្សនិយម ទាមទារអោយលោកគ្រូ-អ្នកគ្រូ បណ្តុះទឹក

ចិត្តចង់រៀនសូត្ររបស់សិស្ស ដូចជា សិស្សខំរៀនសូត្រ ដើម្បីបានលេខមួយក្នុងថ្នាក់ សិស្សខំរៀនសូត្រ ដើម្បីបានក្លាយជាសិស្សពូកែទូទាំងប្រទេស ។ ដូច្នេះហើយ បានជាយើងពោលថា គោលវិធីសិស្សមជ្ឈមណ្ឌល រួមចំណែកអោយសិស្សចេះរៀនដោយខ្លួនឯងទៅអនាគត ។ សូមលោកគ្រូ-អ្នកគ្រូចងចាំថា " សិស្សចេះរៀនដោយខ្លួនឯង លុះត្រាសិស្សមានចិត្តចង់រៀន ព្រមទាំងលោកគ្រូបង្ហាត់អោយសិស្សចេះរៀននៅក្នុងថ្នាក់ជាបណ្ដើរៗ " ។

<u>សំនួរ</u> : តើមួយណាជារូបភាពតំនាងគោលវិធីសិស្សមជ្ឈមណ្ឌល ? ហេតុអ្វី ?

ក :



ខ :



<u>អត្ថន័យរបស់សញ្ញា</u>

● លោកគ្រូ

○ សិស្ស

← ទំនាក់ទំនង

បណ្ឌិត អ៊ុឹម តុច

<u>ពាក្យស្លោករបស់ប្រទេសសឹង្ហបូរី</u>

« ផ្ដល់ឱកាសអោយសិស្សខិតខំគិតពិចារណាមួយនាទី មានតំលៃជាងនិយាយបូរបាច់អោយសិស្សស្ដាប់មួយម៉ោង » ។

<u>ពាក្យស្លោកបុរាណ</u>

« អ្វីដែលសិស្សបានលឺ សិស្សភ្លេច »

« អ្វីដែលសិស្សបានឃើញ សិស្សចាំ »

« អ្វីដែលសិស្សបានធ្វើ រឺ ដោះស្រាយ សិស្សចេះ »

លោក ខុង ជឺ

# ការសិក្សាបុរេប្រវត្តិសាស្ត្រខ្មែរ

ការសិក្សាបុរេប្រវត្តិសាស្ត្រខ្មែរ មានការរីកចំរើនចាប់ពីសង្គ្រាមលោកលើកទីពីរ ។ ដោយសារស្ថានីយ៍នានា គេអាចធ្វើកាលវិទ្យាមួយពិស្តារជាងមុន ប៉ុន្តែ មិនទាន់គ្រប់គ្រាន់នៅឡើយ ។ ការរកឃើញទាំងឡាយ ចាប់ពីទសវត្សឆ្នាំ ៦០ នោះ បានផ្តល់ចំនេះដឹងជាច្រើនអំពីសម័យបុរេប្រវត្តិសាស្ត្រ ។

## ប្រវត្តិនៃការស្រាវជ្រាវ

### ១. ជំនាក់កាលដំបូង

នៅឆ្នាំ ១៨៧៦ លោក រ៉ុក (Roque, directeur des Messageries de Cochinchine) បានធ្វើកំណាយនៅស្ថានីយ៍បុរេប្រវត្តិសាស្ត្រ សំរោងសែន ខេត្តកំពង់ឆ្នាំង ។ បន្ទាប់មក លោក មូរ៉ា J. Moura បានទៅទស្សនាដល់ស្ថានីយ៍ ដោយប្រមូលចងក្រងឧបករណ៍ទាំងនោះ រួចប្រគល់ទៅអោយលោក J.B. Noulet ជានាយកសារមន្ទីរប្រវត្តិសាស្ត្រធម្មជាតិនៅក្រុង Toulouse ដែលបានបោះពុម្ពផ្សាយនូវការសិក្សាដំបូងបង្អស់ មានចំណងជើងថា " យុគថ្មរំលីងនៅប្រទេសកម្ពុជា តាមការរកឃើញរបស់លោកមូរ៉ា ( L'âge de la pierre polie au Cambodge, d'après les découvertes de M. Moura) (1877) ។ នៅឆ្នាំ ១៨៧៩ លោក J.B. Noulet បានបោះពុម្ពផ្សាយការសិក្សាលើកទីពីរ ដែលទូលាយជាងមុន ដោយផ្អែកលើឯកសារថ្មីៗ ដែលលោកមូរ៉ាបញ្ជូនទៅអោយ ។

ចាប់ពីពេលនោះមក អ្នកប្រាជ្ញមួយចំនួន បានចាប់ផ្តើមយកចិត្តទុកដាក់ចំពោះសម័យដើមរបស់មនុស្ស ។ ការរកឃើញនៅសំរោងសែន បាននាំអោយមានការពិភាក្សាមួយថ្មី ស្តីពីសម័យដើមរបស់មនុស្សនៅទ្វីបអាស៊ី ។

នៅឆ្នាំ ១៨៨៧-១៨៨៨ លោក L. Jammes ជាគ្រូបង្រៀនបានមកកាន់ឥណ្ឌូចិន និងធ្វើការស្រាវជ្រាវនៅតំបន់ទន្លេសាប ។ គាត់ជីករកឃើញឧបករណ៍ជាច្រើន រួចបានផ្សព្វផ្សាយនៅក្នុងសមាជអន្តរជាតិអំពីនរវិទ្យា និងបុរាណវត្ថុវិទ្យាបុរេប្រវត្តិសាស្ត្រ (Congrès international d'anthropologie et d'archéologie préhistorique ) ឆ្នាំ ១៨៨៩ នៅក្នុងប៉ារីស ។ បន្ទាប់មក លោក E. Cartailhac បានបោះពុម្ពផ្សាយអត្ថបទមួយមានចំណងជើងថា : " យុគលង្ហិនបុរេប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា និងការស្រាវជ្រាវរបស់លោក Ludovic Jammes ( Les bronzes préhistorique du Cambodge et les découvertes de M. Ludovic Jammes) (1890) ។ ដោយផ្អែកលើពត៌មានទាំងនេះ គាត់បានរំលឹកអំពីលទ្ធផលនៃការរកឃើញនៅសំរោងសែន និងនៅកន្លែងជិតខាង មានស្ថានីយ៍ទាំងអស់ចំនួន ៦ ក្នុងចំនោមស្ថានីយ៍ទាំងនោះមានតែអន្លង់ផ្តៅប៉ុំនោះ ដែលមានការបញ្ជាក់ឡើងវិញ ដោយការស្រាវជ្រាវរបស់លោក H. Mansuy ។ នៅឆ្នាំ ១៩៨១ លោក Mourer បានរកឃើញនៅឯសារមន្ទីរជាតិផ្នែកប្រវត្តិសាស្ត្រធម្មជាតិ (Musée national d'histoire naturelle) នៅ

ក្រុងវ៉ាស៊ិងតុន (Washington ) នូវវត្ថុចំនួនប្រហែល ៤០០ ដែលលោក L. Jammes បានប្រគល់ទៅអោយសារមន្ទីរនេះ នៅឆ្នាំ ១៨៩៧ ។ នៅឆ្នាំ ១៩៨៣ Smithsonian Institution បានប្រគល់វត្ថុទាំងនេះទៅអោយសារមន្ទីរគីមេ ផ្នែកប្រវត្តិសាស្ត្រធម្មជាតិនៅក្រុងលីយ៉ុង (Musée Guimet d'histoire naturelle de Lyon ) ដើម្បីបង្គ្រប់បញ្ជីឯកសារ សំរោងសែនរបស់ Jammes ។ វត្ថុដែលលោក L. Jammes និង H. Mansuy នាំយកទៅ ត្រូវបានតំកល់ទុកនៅឯសារមន្ទីរស្តីពីមនុស្ស (Musée de l'Homme ) នៅក្រុងប៉ារីស ។ នៅឆ្នាំ ១៩០២ ដោយសារការផ្សាយនូវការសិក្សារបស់ H. Mansuy ទើបគេទទួលស្គាល់លក្ខណៈបុរេប្រវត្តិសាស្ត្រនៃសំរោងសែន ។ តាមរយៈកំណាយរបស់លោក H. Mansuy គេអាចដឹងថា ស្ថានីយ៍សំរោងសែនស្ថិតនៅក្នុងយុគថ្មថ្មី ។ ម្ភៃឆ្នាំក្រោយមក (១៩២៣) លោកបានធ្វើកំណាយនៅទីនេះឡើងវិញ ឃើញថា សេចក្តីសន្និដ្ឋានពីពេលមុន នៅតែមានតំលៃដដែល ។ នៅទីនោះ គេជីករកឃើញឧបករណ៍ធ្វើពីថ្មរំលីង ពីលង្ហិនជាដើម ។ នៅឆ្នាំ ១៩៣៨ លោក P.Lévy បានធ្វើកំណាយនៅម្លូព្រៃ (ខេត្តកំពង់ធំ) ។ នៅស្ថានីយ៍កណ្តាលវាលនោះ មានឧបករណ៍ធ្វើពីថ្ម និងគ្រឿងអលង្កាពីលង្ហិន ។ កំណាយនៅម្លូព្រៃកំណត់នូវការបញ្ចប់ដំណាក់កាលដំបូង នៃការស្រាវជ្រាវបុរេប្រវត្តិសាស្ត្រនៅប្រទេសកម្ពុជា ។

## ២. ដំនាក់កាលថ្មី

ពាក់កណ្តាលទី ២ នៃសតវត្សទី ២០ កំណត់នូវវបត់មួយក្នុងការស្រាវជ្រាវបុរេប្រវត្តិសាស្ត្រខ្មែរ ។ ការស្រាវជ្រាវបានចាប់ផ្តើមឡើងវិញ នៅដំណាច់ទសវត្សឆ្នាំ ៥០ ដោយសារលោក L. Malleret ការរកឃើញ (១៩៥៩) ស្ថានីយ៍នៅតំបន់មេមត់ (ខេត្តកំពង់ចាម) ។ នៅឆ្នាំ ១៩៥៩ នេះដែរ លោក B.P. Groslier បានសំគាល់ឃើញស្ថានីយ៍យុគថ្មថ្មីមួយនៅក្រោមគ្រឹះនៃប្រាសាទអង្គរ ប៉ុន្តែ ពុំមានការអះអាងបញ្ជាក់នៅពេលក្រោយមកទេ ។

នៅឆ្នាំ ១៩៦២ លោក B.P. Groslier បានចាប់ផ្តើមធ្វើកំណាយនៅមេមត់ ហើយលទ្ធផលដំបូងត្រូវបានផ្សព្វផ្សាយនៅឆ្នាំ ១៩៦៦ ។ ស្ថានីយ៍នេះ ស្ថិតនៅក្នុងយុគថ្មថ្មី ។ ក្រោយមកទៀត គេបានធ្វើកំណាយនៅតំបន់អង្គរ ដោយបានប្រទះឃើញឧបករណ៍ជាច្រើនពីយុគថ្មថ្មី រឺយុគលោហៈ (ការផ្សព្វផ្សាយផ្ទាល់របស់លោក Groslier នៅឆ្នាំ ១៩៧២ និង ១៩៧៩) ។

នៅឆ្នាំ ១៩៦៣ និងឆ្នាំ ១៩៦៦ លោក E. Saurin បានរកឃើញស្ថានីយ៍យុគថ្មបំបែកដំបូងបង្អស់នៅប្រទេសកម្ពុជា ក្នុងតំបន់ចន្លោះស្ទឹងត្រែង និង ស្នួល នៅត្រើយខាងឆ្វេងនៃទន្លេមេគង្គ ។

នៅឆ្នាំ ១៩៦៧ លោក J.P. Carbonnel បានរកឃើញស្ថានីយ៍បុរេប្រវត្តិសាស្ត្រនៅភ្នំល្អាង (ខេត្តកំពត) ។ លោក A. Pavie បានប្រាប់អោយដឹងស្ថានីយ៍ក្បាលរមាសនៅឆ្នាំ ១៨៨១ ប៉ុន្តែ តាំងពីពេលនោះមក គេពុំបានធ្វើកំណាយទេ ។ ស្ថានីយ៍ដែលបានរកឃើញថ្មីៗ និងកំណត់អាយុដោយ 14 C ស្ថិតនៅតំបន់ដីក្រហម គឺចំការអណ្តូង (នៅចំការកៅស៊ូចំការអណ្តូង) និងជប់ថ្មពេជ្រ (ចំការកៅស៊ូជប់) ។ សង្គ្រាមឆ្នាំ ១៩៧០ បានកាត់ផ្តាច់ការស្រាវជ្រាវទាំងនោះ ។

លទ្ធផលនៃការស្រាវជ្រាវថ្មី ស្តីពីប្រទេសកម្ពុជា ។ បោះពុម្ពផ្សាយក្រោមការដឹកនាំនៃលោក François Bizot សាលាបារាំងចុងបូព៌ាប្រទេស ១៩៨៩ ។



ចលនា និង ការបរិវត្តន៍ ក្នុងប្រវត្តិសាស្ត្រ ។

* សម័យ (Epoque) : មានរយៈពេលខ្លីជាងកាលសម័យ សំរាប់សំគាល់រចនាបទសិល្បៈ ... ជាដើម ។

## ៣~ បុរេប្រវត្តិវិទ្យា និង ប្រវត្តិវិទ្យា

មានកាលសម័យវែងពីរនៅក្នុងប្រវត្តិវិទ្យាគឺ : កាលសម័យបុរេប្រវត្តិសាស្ត្រ និងកាលសម័យប្រវត្តិសាស្ត្រមានការកំនត់កាលបរិច្ឆេទផ្សេងៗ ចំពោះកាលសម័យបុរេប្រវត្តិសាស្ត្រដូចខងក្រោមនេះ :

កំនើតព្រះយេស៊ូគ្រិស្ត

ជិតមួយលានឆ្នាំ សង្គមបុព្វកាល ៦០០០ឆ្នាំ (តាមឯកសារ ស.ភ.៣)

កំនកំនើតសង្គមមនុស្ស

៦០០.០០០ឆ្នាំ ៤.០០០ ឆ្នាំ

កាលសម័យដែលមនុស្សពុំទាន់មានអក្សរ គេដឹងដោយសារឯកសារគ (តាមឯកសារខេមរយានកម្មថ្នាក់ទី ៦)

ចាប់ពីយុគទឹកកក (Ice Ages)

(តាមឯកសារ Basic world History, Cambridge Book...)

(១លានឆ្នាំ) មនុស្សលេចឡើងនៅលើផែនដី (៥០០០ឆ្នាំ)

មុនពេលមនុស្សរក្សាទុកឯកសារសរសេរ (Before man kept written records)

ឯកាលសម័យប្រវត្តិសាស្ត្រ ត្រូវបែងចែកជាកាលសម័យ ៤ ខ្លីៗផ្សេងទៀតគឺ :

- បុរាណសម័យ (Antiquité)
- មជ្ឈិមសម័យ (Moyen Age)
- នវសម័យ (Temps Modernes) និង
- សហសម័យ (Epoque Contemporaine)

**តាមប្រវត្តិវិទូបារាំង :**

| បុរាណសម័យ | មជ្ឈិមសម័យ | នវសម័យ | សហសម័យ |
|---|---|---|---|

ប្រហែល ៣២០០ ឆ្នាំ  ០ ស.វ ទី ៥ (៤៧៦)
(ការដួលរលំចក្រភពរ៉ូមខាងលិច
រី ឆ្នាំ ៣៩៥ ជាឆ្នាំដែលចក្រភព
រ៉ូមត្រូវចែកជាពីរ
( ចុងសតវត្សទី ៤ )

សតវត្សទី ១៥  ១៧៨៩
(១៤៩២)  បដិវត្តន៍បារាំង
( Christophe
Colombe
ឃើញទ្វីបអាមេរិក
រីឆ្នាំ ១៤៥៣ ជាឆ្នាំដែល
ចក្រភពរ៉ូមខាងកើតដួលរលំ)

**តាមប្រវត្តិវិទូអាមេរិក :**

| | |
|---|---|
| ប្រវត្តិវិទ្យាបុរាណសម័យ (Ancient history) | ៥០០០ឆ្នាំ មុនគ.ស ដល់ ៥០០ ឆ្នាំក្រោយ គ.ស<br>( 5000 B.C to 500 A.D) |
| ប្រវត្តិវិទ្យាមជ្ឈិមសម័យ (Medieval history) | ៥០០ឆ្នាំ ក្រោយគ.ស ដល់ ១៥០០ ឆ្នាំក្រោយ គ.ស<br>( 500 A.D to 1500 A.D) |
| ប្រវត្តិវិទ្យានវសម័យ (Modern history) | ១៥០០ឆ្នាំ ក្រោយគ.ស មកដល់បច្ចុប្បន្ន<br>( 1500 A.D to the present) |

**តាមប្រវត្តិវិទូម៉ាក្សនិយម :**

| សង្គមទាសភាព | សង្គមសក្តិភូមិ | សង្គមមូលធននិយម | សង្គមសង្គមនិយម |
|---|---|---|---|
| បុរាណសម័យ | មជ្ឈិមសម័យ | នវសម័យ | សហសម័យ |

ប្រហែល ៣២០០ ឆ្នាំ ០  ៤៧៦  ១៦៤០  ១៩១៧  បច្ចុប្បន្នកាល

ការដួលរលំ  បដិវត្តន៍  មហាបដិវត្តន៍
ចក្រភពរ៉ូមខាងលិច  គហបតីអង់គ្លេស  សង្គមនិយមខែតុលា

បណ្ឌិត ស៊ិន សំណាង

# លទ្ធផលសរុបនៃការជំរឿនប្រជារាស្ត្រ

ខ្ញុំមានសេចក្ដីសប្បាយរីករាយ ដោយបានយកមកចុះផ្សាយនូវលទ្ធផលនៃការជំរឿនប្រជារាស្ត្រខ្មែរ ជូនចំពោះបុគ្គលិកសិក្សាទូទាំងប្រទេស ដើម្បីទុកជាពត៌មានដ៏សំខាន់របស់ខ្លួនផ្ទាល់ និងសំរាប់សិស្សានុសិស្ស ។

ឯកសារជាផ្លូវការនេះ លោកគ្រូ-អ្នកគ្រូ អាចយកមកប្រើក្នុងមេរៀនភូមិវិទ្យា ដើម្បីកែតំរូវឯកសារចាស់ សូមបើកសៀវភៅសិក្សាសង្គមភូមិវិទ្យា, ប្រវត្តិវិទ្យា ថ្នាក់ទី ៧ ទំព័រ ៦៨ ។

ឯកឧត្តម ឆាយ ថន រដ្ឋមន្ត្រីផែនការមានប្រសាសន៍ថា " យើងជឿជាក់ថា របាយការណ៍នេះ មានអត្ថប្រយោជន៍យ៉ាងសំខាន់ចំពោះក្រសួង ស្ថាប័ន អង្គការអន្តរជាតិ អ្នកស្រាវជ្រាវ និងអ្នកប្រើប្រាស់នានា " ។

**ផែនទី កម្ពុជា ខេត្ត-ក្រុង**



## ចំនួនប្រជារាស្ត្រសរុប កម្ពុជា ១៩៩៨
## ( លទ្ធផលជំរឿនសរុបចុងក្រោយ )

| លេខកូដ | ឈ្មោះខេត្ត | សរុបចំនួនគ្រួសារ | ចំនួនប្រជារាស្ត្រ | | | អត្រាភេទ (១) | ទំហំគ្រួសារជាមធ្យម (*) |
|---|---|---|---|---|---|---|---|
| | | | សរុប | ប្រុស | ស្រី | | |
| ០១ | បន្ទាយមានជ័យ | ១១១.៨៥៦ | ៥៧៧.៧៧២ | ២៨៣.៣៥៨ | ២៩៤.៤១៤ | ៩៦,២ | ៥.១ |
| ០២ | បាត់ដំបង | ១៤៨.៣៥៦ | ៧៩៣.១២៩ | ៣៨៨.៥៩៩ | ៤០៤.៥៣០ | ៩៦,១ | ៥.៣ |
| ០៣ | កំពង់ចាម | ៣១២.៨៤១ | ១.៦០៨.៩១៤ | ៧៧៥.៧៩៦ | ៨៣៣.១១៨ | ៩៣,១ | ៥.១ |
| ០៤ | កំពង់ឆ្នាំង | ៨២.៦៣៨ | ៤១៧.៦៩៣ | ១៩៧.៦៩១ | ២២០.០០២ | ៨៩,៩ | ៥.០ |
| ០៥ | កំពង់ស្ពឺ | ១១៥.៧២៨ | ៥៩៨.៨៨២ | ២៨៧.៣៩២ | ៣១១.៤៩០ | ៩២,៣ | ៥.១ |
| ០៦ | កំពង់ធំ | ១០៦.៩០៨ | ៥៦៩.០៦០ | ២៧២.៨៤៤ | ២៩៦.២១៦ | ៩២,១ | ៥.៣ |
| ០៧ | កំពត | ១០៤.៩៩៣ | ៥២៨.៤០៥ | ២៥៣.០៨៥ | ២៧៥៣២០ | ៩១,៩ | ៥.០ |
| ០៨ | កណ្ដាល | ២០៦.១៨៩ | ១.០៧៥.១២៥ | ៥១៥.៥៥៦ | ៥៥៩.១២៩ | ៩២,៣ | ៥.២ |
| ០៩ | កោះកុង | ២៤.៥៦៤ | ១៣២.១០៦ | ៦៧.៧០០ | ៦៤.៤០៦ | ១០៥,១ | ៥.២ |
| ១០ | ក្រចេះ | ៤៩.៣២៦ | ២៦៣.១៧៥ | ១៣០.២៥៤ | ១៣២.៩២១ | ៩៨,០ | ៥.៣ |
| ១១ | មណ្ឌលគិរី | ៥.៦៥៧ | ៣២.៤០៧ | ១៦.៣៨០ | ១៦.០២៧ | ១០២,២ | ៥.៧ |
| ១២ | ភ្នំពេញ | ១៧៣.៦៧៨ | ៩៩៩.៨០៤ | ៤៨១.៩១១ | ៥១៧.៨៩៣ | ៩៣,១ | ៥.៧ |
| ១៣ | ព្រះវិហារ | ២១.៤៩១ | ១១៩.២៦១ | ៥៩.៣៣៣ | ៥៩.៩២៨ | ៩៩,០ | ៥.៥ |
| ១៤ | ព្រៃវែង | ១៩៤.១៨៥ | ៩៤៦.០៤២ | ៤៤៥.១៤០ | ៥០០.៩០២ | ៨៨,៩ | ៤.៩ |
| ១៥ | ពោធិសាត់ | ៦៨.២៣៥ | ៣៦០.៤៤៥ | ១៧២.៨៥០ | ១៨៧.៥៩៥ | ៩២,២ | ៥.២ |
| ១៦ | រតនគិរី | ១៦.៧៥៨ | ៩៤.២៤៣ | ៤៦.៣៩៦ | ៤៧.៨៤៧ | ៩៧,០ | ៥.៦ |
| ១៧ | សៀមរាប | ១២៧.២១៥ | ៦៩៦.១៦៤ | ៣៣៦.៦៨៥ | ៣៥៩.៤៧៩ | ៩៣,៧ | ៥.៤ |
| ១៨ | ក្រុងព្រះសីហនុ | ២៨.០១៥ | ១៥៥.៦៩០ | ៧៦.៩៤០ | ៧៨.៧៥០ | ៩៧,៧ | ៥.៥ |
| ១៩ | ស្ទឹងត្រែង | ១៤.៣២៣ | ៨១.០៧៤ | ៤០.១២៤ | ៤០.៩៥០ | ៩៨,០ | ៥.៦ |
| ២០ | ស្វាយរៀង | ៩៨.២៤៤ | ៤៧៨.២៥២ | ២២៥.១០៥ | ២៥៣.១៤៧ | ៨៨,៩ | ៤.៨ |
| ២១ | តាកែវ | ១៥៥.០៣០ | ៧៩០.១៦៨ | ៣៧៦.៩១១ | ៤១៣.២៥៧ | ៩១,២ | ៥.១ |
| ២២ | ឧត្តរមានជ័យ | ១២.៥៣១ | ៦៨.២៧៩ | ៣៤.៤៧២ | ៣៣.៨០៧ | ១០២,០ | ៥.៣ |
| ២៣ | ក្រុងកែប | ៥.៣៦៩ | ២៨.៦៦០ | ១៤.០១៤ | ១៤.៦៤៦ | ៩៥,៧ | ៥.៣ |
| ២៤ | ក្រុងប៉ៃលិន | ៤.១៣៣ | ២២.៩០៦ | ១២.៣៩២ | ១០.៥១៤ | ១១៧,៩ | ៥.២ |
| | កម្ពុជា-សរុប : | ២.១៨៨.៦៦៣ | ១១.៤៣៧.៦៥៦ | ៥.៥១១.៤០៨ | ៥.៩២៦.២៤៨ | ៩៣,០ | ៥,២ |

(*) ផ្អែកលើមូលដ្ឋានគ្រួសារធម្មតា រឺ គ្រួសារប្រក្រតី

(១) - ចំនួនបុរសធៀបនឹងស្ត្រី ១០០ នាក់ នៃប្រជារាស្ត្រ ។

# ដំណោះស្រាយចំនោទនៅបឋមសិក្សា

ដើម្បីអោយការបង្រៀនចំនោទនៅបឋមសិក្សាបានទទួលលទ្ធផលល្អ យើងគួរណែនាំសិស្សអោយចេះ :

- ស្វែងយល់ប្រធានចំនោទអោយបានស៊ីជម្រៅ ។
- ប៉ាន់ស្មានលទ្ធផលដែលគេរកឃើញ ទោះបីជាមិនសមហេតុផលក៏ដោយ ។
- រកវិធីដោះស្រាយចំនោទអោយបានត្រឹមត្រូវ ដោយគេយល់ថា ដោះស្រាយចំនោទ គឺធ្វើប្រមាណវិធីអោយគ្រប់ចំនួនតួលេខដែលមានក្នុងប្រធានចំនោទ ។
- រៀនខ្លួនឯងដោយអានឯកសារបន្ថែមនៅផ្ទះ ។

## ចំនោទទី ១

- កំរិតថ្នាក់ : ទី ៥ , ទី ៦
- ចំនេះដឹងគណិតវិទ្យាចាំបាច់ : ន័យនៃប្រមាណវិធីទាំងបួន និងបច្ចេកទេសប្រមាណវិធីទាំងបួន ។
- សមត្ថភាពដែលត្រូវអភិវឌ្ឍ : ផ្ទៀងផ្ទាត់ និងផ្តល់អំនះអំនាងអំពីលំនាំនៃការដោះស្រាយចំនោទ ។

**ចំនោទ**

មុនថ្ងៃចូលរៀន ម្តាយសុខាបានទិញប្រដាប់ប្រដារសិក្សាអោយកូនរបស់គាត់ ។ គាត់ទិញខ្មៅដៃ 3 ដើម ថ្លៃ 200៛ ក្នុងមួយដើម ហ្វឹតសរសេរក្តារខៀន 3 ដើម ក្នុង 1 ដើមថ្លៃ 1.100 ៛ និងសៀវភៅសរសេរចំនួន 14 ក្បាល ក្នុងមួយក្បាល ថ្លៃ 800៛ ។ គាត់អោយក្រដាសប្រាក់ 20.000 ៛ ទៅអ្នកលក់ ។ គាត់ចង់ទិញកាបូបមួយទៀតអោយកូនរពៅរបស់គាត់ថ្លៃ 4.500៛ ។ តើម្តាយសុខាមានប្រាក់គ្រប់គ្រាន់ដើម្បីទិញការបូបនេះរឺទេ ។

**សំនួរ** : សិស្សម្នាក់បានគិតលេខដូចខាងក្រោមនៅលើសៀវភៅព្រាង :

ក- $200 \times 3 = 600$

ខ- $800 \times 14 = 11\ 200$

គ- $1\ 100 + 1\ 100 + 1\ 100$

$2\ 200 + 1\ 100$

$3300$

ឃ- 600
+ 3 300
+ 11 200
_______
15 100

ង- 15 100
+ 4 900
_______
20 000

ច- 4 500 + 15 100

4 500 + ( 15 000 + 100 ) = 19 600

១- ចូរផ្ទៀងផ្ទាត់លទ្ធផលរបស់សិស្សនេះ ។ បើមានកំហុស ត្រូវកែតម្រូវ ។

២- ចំពោះល្បះលេខនីមួយៗ ចូរពន្យល់ពីអ្វីដែលសិស្សនោះចង់រក ។

៣- តើអ្នកយល់យ៉ាងដូចម្តេច ចំពោះល្បះលេខដែលនៅចុងក្រោយ ចូរពន្យល់ថាហេតុអ្វី ?

**សំគាល់នៃការបង្រៀន**

១- ចំលងចំនោទនៅលើក្តារខៀន ។

២- អោយសិស្សអានអំនានដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយសំដីរបស់គេផ្ទាល់អោយបានច្រើននាក់ មុននឹងអោយសិស្សធ្វើចំនោទ ។

៤- ទុកពេលអោយសិស្សរកចំលើយរបស់សំនួរទី 1 និងទី 2 លើក្រដាសព្រាង ។

៥- ធ្វើកំនែរួមលើក្តារខៀន ដោយអោយសិស្សម្នាក់ឡើងមកបង្ហាញលទ្ធផលនៃការគណនានីមួយៗ និងបង្ហាញពីអ្វីដែលសិស្សនោះចង់រក ។

៦- ទុកពេលអោយសិស្សឆ្លើយនឹងសំនួរទី 3 ។

៧- ធ្វើកំនែរួមនៅលើក្តារខៀន ។ សិស្ស 2 រឺ 3 នាក់ផ្តល់ចំលើយ និងផ្តល់អំនះអំនាង (បើសិនជាសិស្សមានចំលើយផ្ទុយពីចំលើយត្រូវ ប្រការសំខាន់គឺសិស្សបានបកស្រាយនូវអំនះអំនាងរបស់គេ) ។

**ចំលើយ :**

១ និង ២ - ក- ចំលើយត្រូវ : វារកថ្លៃទិញខ្មៅដៃ 3 ដើម

ខ- ចំលើយត្រូវ : វារកថ្លៃទិញសៀវភៅទាំងអស់

គ- ចំលើយត្រូវ : វារកថ្លៃទិញប៊ិចហ្វឺតទាំង 3 ដើម

ឃ- ចំលើយត្រូវ : វារកថ្លៃទិញសំភារៈសិក្សាទាំងអស់

ង- ចំលើយត្រូវ : វារកប្រាក់ដែលម្ដាយវានៅសល់

ច- ចំលើយត្រូវ : វារកប្រាក់ចំនាយសរុបបើសិនជាម្ដាយវាទិញកាបូបមួយទៀត

៣- ប្រមាណវិធីចុងក្រោយនេះ មិនចាំបាច់ទេ ពីព្រោះគេសួរថា តើម្ដាយសុខាអាចទិញកាបូបបានរឺមិនបាន ។ គេមិនមែនសួររកប្រាក់ដែលគាត់នៅសល់ទេ ។

## ចំនោទទី ២

- ក៏រិតថ្នាក់ : ទី ៤ , ទី ៥
- ចំនេះដឹងគណិតវិទ្យាចាំបាច់ : ប្រមាណវិធីបូក និងប្រមាណវិធីគុណ ។
- សមត្ថភាពផ្សេងៗ : ការអានតារាង ។
- សមត្ថភាពដែលត្រូវអភិវឌ្ឍ : រៀបចំពតិមានដែលបានមកពីបំរាប់ផ្សេងៗ ។

**ចំនោទ**

| តារាងតំលៃជួល | | | |
|---|---|---|---|
| រាយមុខវត្ថុ | មនុស្សចាស់ | កុមារ១០-១៧ឆ្នាំ | កុមារក្រោម ១០ឆ្នាំ |
| ប៉ោអ៊ីបត់ | 2 500៛ | 1 500៛ | 1 000៛ |
| ឆ័ត្រជ្រកម្លប់ | 1 000៛ | 1 000៛ | 1 000៛ |
| ពោងហែលទឹក | 1 500៛ | 1 000៛ | 500៛ |
| ម៉ូតូទឹក ( ១ម៉ ) | 30 000៛ | 20 000៛ | 10 000៛ |

តំលៃតូប : 5 000៛ ក្នុង ១ ថ្ងៃ

| តារាងតំលៃភេសជ្ជៈ | |
|---|---|
| រាយមុខភេសជ្ជៈ | តំលៃរាយ |
| ទឹកត្រឡាច | 3 500៛ |
| ទឹកក្រូច | 2 500៛ |
| ទឹកបរិសុទ្ធដបតូច | 1 000៛ |
| ទឹកបរិសុទ្ធដបធំ | 2 500៛ |
| ទឹកផ្លែឈើ | 2 500៛ |

គ្រួសារលោកសុខា មានកូន 3 នាក់ អាយុ 16 ឆ្នាំ 12 ឆ្នាំ និង 9 ឆ្នាំ គ្រួសារនេះបានទៅសំរាកកំសាន្តនៅមាត់សមុទ្ររយៈពេលមួយថ្ងៃ ។ គាត់បានជួលកន្លែងសំរាកមួយ ។ ម្ដាយជួលប៉ោអ៊ីបត់មួយសំរាប់អង្គុយលេង ។ ឪពុកម្ដាយនាំកូនច្បងពីរនាក់ជួលម៉ូតូទឹកជិះលេង ។ កូនពៅជួលពោងហែលទឹក ។

រយៈពេល 1 ម៉ោងក្រោយមក ពួកគេបាននាំគ្នាទៅសំរាកពិសារភេសជ្ជៈ ។ គេពិសារទឹកត្រឡាចអស់ 2 កំប៉ុងទឹកក្រូច 2 កំប៉ុង ទឹកបរិសុទ្ធដបធំ 1 ដប ។

តើគ្រួសារលោកសុខា ចំណាយអស់ប្រាក់ប៉ុន្មានសំរាប់ការលំហែរនៅមាត់សមុទ្រនេះ ?

**លំនាំនៃការបង្រៀន**

១- ចំលងចំនោទនៅលើក្ដារខៀន ។

២- អោយសិស្សអានចំនោទដោយស្ងៀមស្ងាត់ ។

៣- អោយសិស្សប្រាប់ពីអ្វីដែលគេត្រូវធ្វើដោយសំដីរបស់គេផ្ទាល់ មិនមែនអោយសិស្សអានចំនោទឡើងវិញទេ ។

**កំណត់សំគាល់** : សូមប្រយ័ត្ន បើសិនជាមានបញ្ហាក្នុងការអានតារាងត្រូវសួរសំនួរខ្លះ ដូចជា :

- តើកុមារអាយុ 15 ឆ្នាំ ត្រូវចំណាយប្រាក់ប៉ុន្មានដើម្បីជូលពោងហែលទឹកមួយ ?
- បើក្មេងអាយុ 7 ឆ្នាំវិញ តើត្រូវចំនាយប៉ុន្មានដែរ ?
- តើមនុស្សពេញវ័យ 2 នាក់ ត្រូវចំនាយប្រាក់ប៉ុន្មាន ដើម្បីជួលម៉ូតូទឹកក្នុងមួយម៉ោង ?

៤- អោយសិស្សដោះស្រាយចំនោទនេះជាបុគ្គលក្នុងសៀវភៅ ។

៥- អោយសិស្សប្តូរសៀវភៅគ្នាកែ ។

៦- ធ្វើកំនែរូមនៅលើក្តារខៀន ។

**ចំលើយ** :

**92 500៛**

គ្រួសារលោកសុខាចំនាយប្រាក់អស់ **92 500៛** សំរាប់ការលំហែកំសាន្តនេះ

**+ ជំនឹងសំរាប់លោកគ្រូ-អ្នកគ្រូថ្នាក់ទី ៣ !**

អស់លោកបានទទួលសៀវភៅកំរងលំហាត់អំនានភាសាខ្មែរ ថ្នាក់ទី 3 និងការប្រើប្រាស់សំភារ:ឧបទេសថ្មីនេះ ពីសំនាក់គ្រូឧទ្ទេស និងអធិការហើយមែនទេ ? យើងខ្ញុំគ្រាន់តែសូមអនុញ្ញាតបញ្ជាក់បន្ថែមនូវចំនុចសំខាន់ខ្លះ ?

អស់លោកដឹងទេ លំហាត់អំនានស្ងាត់ទាំងនេះ សុទ្ធតែបានតាក់តែងឡើង ដើម្បីអភិវឌ្ឍសមត្ថភាពថ្មីៗដល់សិស្សដែលក្នុងនោះអស់លោក :

- មិនត្រូវអានលំហាត់លឺៗ អោយសិស្សស្តាប់ រឺយ៉ាងហោចណាស់ សូម្បីតែអានឮសំនួមពររបស់លំហាត់ ពីព្រោះថា បើគ្រូធ្វើដូច្នេះ សិស្សនឹងប្តូរការយល់អត្ថន័យតាមរយ:អំនានទៅជាការយល់ តាមរយ:ការស្តាប់ទៅវិញ ។

- មិនត្រូវអោយសិស្សអានលំហាត់លឺៗទេ ក៏ប៉ុន្តែ ត្រូវសួរសិស្សអោយឆ្លើយដោយសំដីផ្ទាល់របស់គេមកវិញ នូវអ្វីដែលគេត្រូវធ្វើអោយបានច្រើននាក់ មុននឹងអោយសិស្សធ្វើលំហាត់ ។ ការសួរបៀបនេះ អាចបញ្ជាក់បានថា សិស្សពិតជាបានយល់លំហាត់ គឺបានដឹងថា ខ្លួនគេត្រូវធ្វើអ្វី ? ។

ដូចនេះ គួរតែអស់លោកទុកឱកាសអោយសិស្សស្វែងយល់អត្ថន័យរបស់អំនានដោយខ្លួនឯង ដែលជាយុទ្ធសាស្ត្រដ៏ល្អមួយ បំរើអោយយើងខ្ញុំសង្ឃឹមថា អស់លោកពិតជាយកការងារទាំងអស់នេះ ទៅសាកល្បងនៅក្នុងថ្នាក់រៀនជាមិនខាន ។

អធិការបឋមសិក្សាខេមរោទិទ្យាល័យគរុកោសល្យ

ក្រោមគំនិតផ្តួចផ្តើមនិងអាសុខ

# អំពីម៉ោងបង្រៀន និង រៀនពិតនៅក្នុងសាលារៀនបឋមសិក្សានៅកម្ពុជា

កាលពីថ្ងៃទី ៣ ខែ សីហា ១៩៩៩ នៅសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិមភ្នំពេញ មានបើកសិក្ខាសាលាមួយ ស្តីពីពេលម៉ោងបង្រៀន និងរៀនពិត នៃសាលារៀនបឋមសិក្សានៅកម្ពុជា ។

សមាសភាពចូលរួមមាន : ថ្នាក់ដឹកនាំរបស់ក្រសួង ថ្នាក់ដឹកនាំនាយកដ្ឋាន ថ្នាក់ដឹកនាំមន្ទីរអប់រំយុវជន និង កីឡា ខេត្ត-ក្រុង នាយកសាលាគរុកោសល្យខេត្ត-ក្រុង នាយកសាលារៀនបឋមសិក្សាភ្នំពេញខ្លះ និងតំណាងអង្គការនានា ដែលជួយបឋមសិក្សាមួយចំនួន ។

ឯកសារស្រាវជ្រាវពីរបានត្រូវយកមកជាឯកសារប្រើប្រាស់ក្នុងអង្គសិក្ខាសាលា :

១- ការស្រាវជ្រាវអំពីម៉ោងបង្រៀនពិតនៅក្នុងសាលាបឋមសិក្សានៅកម្ពុជា លទ្ធផលពីការសង្កេតថ្នាក់ជាតិ លើគ្រូបង្រៀន ដោយ Sophia Spreech mann អង្គការ Care international ឧសភា ១៩៩៩ ។

២- ការស្រាវជ្រាវលើចំនួនម៉ោងបង្រៀនពិតនៅសាលាបឋមសិក្សានៅកម្ពុជា ខែ មិថុនា ១៩៩៩ អង្គការ Care international អ្នកស្រាវជ្រាវ លោក BOB MC Laughlin និងលោក Sophia Spreech mann ។

ផ្អែកលើការស្រាវជ្រាវ និងតថភាពដែលយើងមានលើទីលានអប់រំ តើក្រសួងអប់រំគួរមានវិធានការអ្វីខ្លះ ដើម្បីកាត់បន្ថយបាតុភាពអវិជ្ជមាន ដែលប៉ះពាល់ដល់អនាគតនៃការសិក្សារបស់កុមារជាតិយើង ដល់សុភមង្គលកុមារ និងដល់អនាគតមាតុភូមិយើងនោះ ?

## I- សិក្ខាសាលានេះមានគោលបំណងដូចតទៅ :

១- ដើម្បីផ្សព្វផ្សាយលទ្ធផល និងអនុសាសន៍នៃការស្រាវជ្រាវថ្មីៗលើម៉ោងបង្រៀននៅតាមសាលារៀនបឋមសិក្សានៅកម្ពុជា ។

២- ដើម្បីធ្វើការពាក់ព័ន្ធជាមួយមន្ត្រីក្រសួង អ.យ.ក និងអ្នកអប់រំមកពីអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល ក្នុងការវិភាគកត្តាទាំងឡាយដែលកំរិតចំនួនម៉ោងរៀនសូត្ររបស់សិស្ស នៅក្នុងសាលារៀន ។

៣- ដើម្បីពិចារណាលើផលប៉ះពាល់នៃលទ្ធផលស្រាវជ្រាវចំពោះសកម្មភាពរបស់ក្រសួង អ.យ.ក ដើម្បីបង្កើនចំនួនម៉ោងរៀនសូត្ររបស់សិស្ស នៅក្នុងសាលារៀន ។

## II- សិក្ខាសាលាបានលើកឡើងអំពីបញ្ហាពីរ :

- លទ្ធផលសំខាន់ៗនៃការអង្កេតលើគ្រូបង្រៀនថ្នាក់ជាតិ និងលើចំនួនម៉ោងបង្រៀន និងរៀនពិត
- បញ្ហាជាអាទិភាព និង អនុសាសន៍

### II-1.1. លទ្ធផលសំខាន់ៗនៃការអង្កេតលើគ្រូបង្រៀន

- អវត្តមានច្រើនរបស់សិស្ស : ជំងឺ . ជួយធ្វើការឪពុកម្តាយ . ជួយថែប្អូន មករៀនយឺត ... ។

- អវត្តមានគ្រូ : ឈឺ, ធ្វើស្រែ, ចូលរួមបុណ្យទាន ... ។
- គ្រូគ្មានការតែងការបង្រៀន ...
- ការប្រើប្រាស់វិធីសាស្ត្របង្រៀនសិស្សមជ្ឈមណ្ឌលមានកំរិត
- ការមិនបង្រៀនតាមវិធីសាស្ត្រ
- សៀវភៅសិក្សាពិបាកប្រើ
- កំនកម្មវិធីសិក្សាមិនទាន់ល្អ
- រយៈពេល ៤០ នាទីក្នុង ១ ម៉ោងសិក្សា បង្រៀនមិនចប់មេរៀន
- ចូលរៀនយឺត ៣០ នាទី និងបញ្ចប់ម៉ោង ១១.០០
- សាលារៀនបិទទ្វារញឹកញាប់ : ប្រជុំ, បុណ្យចូលឆ្នាំចិន, ច្រូតស្រូវ " សំរាក ជាតិ ២៤ ថ្ងៃ, សំរាកខ្លួនឯង ១២ ថ្ងៃ"
- គ្មានសំភារៈឧបទេស
- នាយកសាលារៀនគ្មានការទទួលខុសត្រូវ លើពេលចេញ-ចូល
- ការងាររដ្ឋបាលកិច្ចជួយគ្រូ ជួយនាយកបានតិចតួច
- អគារសិក្សា និង មូលដ្ឋានសំភារៈមិនសមស្រប
- ការរំខានពីខាងក្រៅ
- បាតុភាពអវិជ្ជមានពីសង្គម

**បញ្ជាក់** : ក្នុងទីនេះ យើងលើកតែបញ្ហាចំនុចអវិជ្ជមានតែប៉ុននោះ ។

## II-1.2. លទ្ធផលនៃការអង្កេតចំនួនម៉ោងបង្រៀន និងរៀនពិតមានដូចតទៅ :

- កម្មវិធី និង ម៉ោងបង្រៀនជាក់ស្តែង តាមមុខវិជ្ជាសំរាប់ថ្នាក់ទី ១ ផ្អែកលើការប៉ាន់ប្រមាណទាបរបស់ក្រសួង អ.យ.ក គឺ ៣៣ សប្តាហ៍ បង្រៀនពិតប្រាកដ ។

| ចំនួនម៉ោងបង្រៀនពិតប្រាកដប្រចាំឆ្នាំ | | ចំនួនម៉ោងបង្រៀនពិតប្រាកដដែលបាត់បង់ | ភាគរយចំនួនម៉ោងបង្រៀនពិតប្រាកដដែលបាត់បង់ |
|---|---|---|---|
| កម្មវិធី | ជាក់ស្តែង | | |
| ៨៥៦ | ៥៥៣ | ៣០៣ | ៣៥ |

- កម្មវិធី និង ម៉ោងបង្រៀនជាក់ស្តែង តាមមុខវិជ្ជាសំរាប់ថ្នាក់ទី ១ ផ្អែកលើការប៉ាន់ប្រមាណខ្ពស់ គឺ ៣៨ សប្តាហ៍ បង្រៀនពិតក្នុង ១ ឆ្នាំ ។

| ចំនួនម៉ោងបង្រៀនពិតប្រាកដប្រចាំឆ្នាំ | | ចំនួនម៉ោងបង្រៀនពិត | ភាគរយចំនួនម៉ោងបង្រៀន |
|---|---|---|---|
| កម្មវិធី | ជាក់ស្តែង | ប្រាកដដែលបាត់បង់ | ពិតប្រាកដដែលបាត់បង់ |
| ៨៥៦ | ៦៣៥ | ២២១ | ២៦ |

- កម្មវិធី និង ម៉ោងបង្រៀនជាក់ស្តែង តាមមុខវិជ្ជាសំរាប់ថ្នាក់ទី ៥ និងទី ៦ ផ្អែកលើការប៉ាន់ប្រមាណខ្ពស់ គឺ ៣៨ សប្តាហ៍ បង្រៀនពិតក្នុង ១ ឆ្នាំ ។

| ចំនួនម៉ោងបង្រៀនពិតប្រាកដប្រចាំឆ្នាំ | | ចំនួនម៉ោងបង្រៀនពិត | ភាគរយចំនួនម៉ោងបង្រៀន |
|---|---|---|---|
| កម្មវិធី | ជាក់ស្តែង | ប្រាកដដែលបាត់បង់ | ពិតប្រាកដដែលបាត់បង់ |
| ៨៥៧ | ៦៣៦ | ២២១ | ២៦ |

- កម្មវិធី និង ម៉ោងបង្រៀនជាក់ស្តែង តាមមុខវិជ្ជាសំរាប់ថ្នាក់ទី ៥ និងទី ៦ ផ្អែកលើការប៉ាន់ប្រមាណទាប គឺ ៣៣ សប្តាហ៍ បង្រៀនពិតប្រាកដក្នុង ១ ឆ្នាំ ។

| ចំនួនម៉ោងបង្រៀនពិតប្រាកដប្រចាំឆ្នាំ | | ចំនួនម៉ោងបង្រៀនពិត | ភាគរយចំនួនម៉ោងបង្រៀន |
|---|---|---|---|
| កម្មវិធី | ជាក់ស្តែង | ប្រាកដដែលបាត់បង់ | ពិតប្រាកដដែលបាត់បង់ |
| ៨៥៦ | ៥៥៣ | ៣០៣ | ៣៥ |

- កម្មវិធីបច្ចុប្បន្ន បានផ្តល់សិស្សនូវម៉ោងបង្រៀន ១៦,៧ ម៉ោង ១ សប្តាហ៍ " ៦៣៥ ម៉ោងក្នុង ១ ឆ្នាំ " ដែលមានកំរិតទាបឆ្ងាយណាស់ពីស្តង់ដាអន្តរជាតិ ។

- កង្វះខាតបច្ចុប្បន្នអំពីចំនួនម៉ោងពិត ជាកត្តាយ៉ាងសំខាន់មួយ ដែលរាំងកុមារកម្ពុជានូវការទទួលការអប់រំប្រកបដោយគុណភាពដែលពួកគេគប្បីបានទទួល " ។

## II-2.1. ១៣បញ្ហា ជាអាទិភាព និង អនុសាសន៍

- បញ្ហាទី ១ : ភាពមិនប្រែប្រួល និង ភាពច្បាស់លាស់ក្នុងគោលនយោបាយ និងការកសាងកម្មវិធី
- បញ្ហាទី ២ : ស្តង់ដា ជាអប្បបរិមា រឺ សំនូមពរជាអតិបរិមា
- បញ្ហាទី ៣ : ការសំរេចចិត្តមជ្ឈការ រឺ វិមជ្ឈការ
- បញ្ហាទី ៤ : វិធីសាស្ត្របង្រៀនសិស្សមជ្ឈមណ្ឌល
- បញ្ហាទី ៥ : ការដឹកនាំសាលារៀន

ការដឹកនាំមិនបានល្អ ត្រូវបានចាត់ទុកជាឧបសគ្គចំបងមួយ ក្នុងការអភិវឌ្ឍសាលារៀន " ។

" បុគ្គលិកលក្ខណៈរបស់នាយកសាលារៀន ជាកត្តាសំខាន់ក្នុងការអនុវត្តកម្មវិធីបង្រៀន ប្រកបដោយប្រសិទ្ធិភាព " ។

- បញ្ហាទី ៦ : គ្រូបង្រៀនជាអ្នកមានវិជ្ជាជីវៈ រឺ ជាអ្នកអនុវត្ត

" ជាអ្នកមានវិជ្ជាជីវៈ ដែលអាចវិភាគ បកស្រាយ និងធ្វើការវិនិច្ឆ័យសមហេតុផល អំពីវិធីសាស្ត្របង្រៀន " ។

- បញ្ហាទី ៧ : ការបណ្តុះបណ្តាល និង អធិការកិច្ច " ក្នុងនេះស្ទ័យវាយតំលៃជាប្រការសំខាន់មួយ " ។

- បញ្ហាទី ៨ : ការផ្គត់ផ្គង់សំភារៈបង្រៀន ។

- បញ្ហាទី ៩ : ការចូលរួមរបស់សហគមន៍

- បញ្ហាទី ១០: ការរក្សាកត់ត្រា ផ្សារភ្ជាប់ទៅនឹងផែនការកម្ម ។

- បញ្ហាទី១១ : សុខភាព និង អាហារូបត្ថម្ភ និងការសិក្សា ។

- បញ្ហាទី១២ : តម្រូវការសំភារៈជាអប្បបរិមា សំរាប់គុណភាពអប់រំជាមូលដ្ឋាន សំរាប់សាលារៀនល្អ ។

- បញ្ហាទី១៣ : ការស្រាវជ្រាវអំពីលទ្ធផលសិក្សារបស់សិស្ស ដោយផ្អែកលើសាលារៀន ។

## III. សំនូមពរ នៃអង្គសិក្ខាសាលា

- កសាងបទបញ្ហាសិក្សានៃសាលារៀនបឋមសិក្សាសាធារណៈ ។

- បង្កើនមនសិការវិជ្ជាជីវៈរបស់គ្រូបង្រៀន ។

- ឧបត្ថម្ភមធ្យោបាយ អធិការកិច្ចចុនល្អមជួយណែនាំលើកទឹកចិត្ត និងវាយតំលៃគ្រូ និងនាយក ។

- ដោះស្រាយរបៀបតែងការបង្រៀន ដែលគ្រូជាទូទៅអាចអនុវត្តបាន ។

- បញ្ជាក់ពីវិធីសាស្ត្រសិស្សមជ្ឈមណ្ឌល លទ្ធភាពប្រើប្រាស់ ។

- បឋមសិក្សាសាធារណៈត្រូវមានរយៈពេលសិក្សាតាមស្តង់ដាអន្តរជាតិ ។

- រៀបចំកម្មវិធីសិក្សាអោយគងគ្នា ។

- គួរបង្កើនរយៈពេល ៤៥ នាទី ក្នុងម៉ោងសិក្សា ។

- នាយកដ្ឋាននានារបស់ក្រសួង. មន្ទីរ អ.យ.ក. ការិយាល័យ អ.យ.ក ស្រុក ប្រធានកំរងសាលារៀនគួរមានចំណែក ភារកិច្ចរៀង១ខ្លួន ដើម្បីស្តារស្ថានភាពគួរព្រួយបារម្ភនៅបឋមសិក្សាជាតិយើង ដើម្បីសុភមង្គលរបស់កុមារទាំងអស់ ។

- តំណកម្មវិធីសិក្សា

- ការធ្វើកម្មវិធីសិក្សា និង សៀវភៅសិក្សាអោយមានភាពងាយ

- បណ្តុះបណ្តាលដំបូងជូននាយកសាលារៀនទាំងអស់

- កែលំអ រឺដាក់វិន័យអ្នកខ្វះមនសិការវិជ្ជាជីវៈ និង លើកទឹកចិត្តគ្រូល្អ ។

## IV. បទបញ្ញាសិក្សានៃសាលាបឋមសិក្សាសាធារណៈនៅកម្ពុជា មុនឆ្នាំ ១៩៧៥

ធ្វើតារាងវាយម៉ោងដូចតទៅនេះ :

« ប្រការ ២៨ : តារាងវាយពេលម៉ោងក្នុង ១ អាទិត្យ ថ្ងៃរៀនមាន ៥ ថ្ងៃ ។ ថ្ងៃ ព្រហស្បតិ និងថ្ងៃអាទិត្យ ចាត់ទុកដូចថ្ងៃបុណ្យ ។ រយៈកាលនៃពេលបង្រៀនមាន : ពេលព្រឹក ៣ ម៉ោងកន្លះ ពេលរសៀល ២ ម៉ោងកន្លះ ដោយគិតទាំងពេលវិស្សមកាស និងការហាត់ប្រាណផង » ។

**រយៈពេលរៀន ៣០ ម៉ោង ក្នុង ១ សប្តាហ៍**

ផ្អែកលើការសាវជ្រាវដែលបានលើកឡើង ក្នុងអង្គសិក្ខាសាលា និងតថភាពដែលយើងមានលើទីលានអប់រំក្រសួងអប់រំ យុវជន និង កីឡា ត្រូវសិក្សាអនុសាសន៍ទាំងឡាយនេះ ទៅបែងចែកភារកិច្ច ដែលជាវត្ថុវិស័យផង និងជាប្រធានវិស័យផង ដោយគួបផ្សំនឹងវិធានការរដ្ឋបាលសមស្រប ដើម្បីស្តារស្ថានភាពប្រកាសអាសន្ន "S.O.S" អោយបាន ត្រូវកែលំអសមស្រប ។

យើងមិនត្រូវទុកអោយបឋមសិក្សាសាធារណៈអណ្តែតប៉ើលប៉ាល គ្មានទិសដៅជាក់លាក់នោះបានទេ ព្រោះថា " តម្លៃនៃការសិក្សារបស់កុមារ ជាតំលៃនៃអនាគតកម្ពុជាយើង " ។ សេចក្តីសង្ឃឹមដ៏រស់រវើករបស់ប្រទេសជាតិ គឺកុមារ « L'espoir vivant du pays, c'est l'Enfant » ។ កម្ពុជាមិនអាចអភិវឌ្ឍដល់ទីជំរៅបានទេ បើសិនជាបឋមសិក្សាសាធារណៈមិនបានគ្រប់ ៥០០០ ម៉ោង តាមស្តង់ដាយូណេស្កូ ព្រោះថា « បងប្អូនប្រជាកសិករយើង យកចិត្តទុកដាក់នឹងថ្នាលសំណាបយ៉ាងណា ការកសាងធនធានមនុស្សសំរាប់ប្រទេសជាតិគ្រប់វិស័យ ត្រូវតែចាប់ផ្តើមជាដំបូងដែ ដោយជាក់លាក់ជាទីបំផុត ចេញពីក្រោមដំបូលសាលារៀនបឋមសិក្សាសាធារណៈទាំងឡាយរបស់យើង » ។

ម្យ៉ាងទៀត " សត្វត្រចៀកកាំមួយ មិនអាចធ្វើនិទាឃរដូវបានយ៉ាងណា អំពើគុណធម៌មួយ មិនអាចធ្វើគុណធម៌បានយ៉ាងណា អំពើមួយ រឺ ពីរ ដើម្បីស្តារគុណភាពអប់រំ ក៏មិនអាចធ្វើគុណភាពអប់រំបានក៏យ៉ាងនោះដែរ ។

ការកសាងគុណភាពអប់រំ ជាសាធារណប្រយោជន៍ ជាអាទិភាព និង អចិន្ត្រៃយ៍ ។

លោក **ប៉ាច សុត**

# កម្មវិធីបុរេវិជ្ជាជីវៈ

យើងបានចាកចេញពីរណ្តៅប្រល័យពូជសាសន៍បង្កឡើងដោយម្រឹត្យុ ប៉ុល ពត បានម្ភៃឆ្នាំហើយ ។ ក្នុងរយៈពេលម្ភៃឆ្នាំនេះ ទាំងអ្នកដឹកនាំប្រទេសគ្រប់សំដាប់ថ្នាក់ ទាំងប្រជាពលរដ្ឋបានប្រឹងប្រែងក្រោកឈរ បង្កើតនិងពង្រឹងសមត្ថភាពក្នុងស្ថានភាពមានសង្គ្រាមផង មានសន្តិភាពផង បានយ៉ាងលំបាកលំបិន ។ ជាកុសល ក្នុងស្មារតីមនុស្សជាតិដ៏ខ្ពង់ខ្ពស់ អង្គការអន្តរជាតិ និងក្រៅរដ្ឋាភិបាលខ្លះ បានក្រាញនទៀលជំរៈការលំបាកអត្តខាតជាមួយយើង ហើយជួយយើងទាំងផ្នែកស្មារតី បច្ចេកទេស ទាំងហិរញ្ញវត្ថុ រហូតទាល់តែយើងមានកំលាំងចិត្ត ឆ្លងកាត់សម័យកាលដ៏លំបាកនេះ ដោយឈានទៅមុខបានមួយជំហានធំ ។ បច្ចុប្បន្ន ប្រទេសយើងមានភ័ព្វសំណាងរើខ្លួនរួចពីសំនាញ់សង្គ្រាមរ៉ាំរ៉ៃបានហើយ យើងប្តេជ្ញាបូជាកំលាំងកាយ ចិត្ត និងប្រាជ្ញា កសាងប្រទេសតែមួយមុខគត់ ។ យើងកំពុងនាំគ្នាគិតរកមធ្យោបាយរំដោះខ្លួនចេញពីសំនាញ់មួយទៀត នោះគឺភាពក្រីក្រ ។

វិស័យអប់រំក៏រួមចំនែកក្នុងការគិតរំដោះប្រជាជនចេញពីភាពក្រីក្រនេះដែរ ។ ចាប់តាំងពីឆ្នាំ ១៩៩៥ មក កម្មវិធីថ្មីមួយ ប្រព័ន្ធ ១២ ឆ្នាំ បានដាក់ចេញអនុវត្តទាំងបឋមសិក្សា ទាំងមធ្យមសិក្សា ទន្ទឹមគ្នាតែម្តង គឺនៅឆ្នាំ ១៩៩៦ បឋមសិក្សាប្រើកម្មវិធីថ្មីនៅថ្នាក់ទី ១ ឯនៅមធ្យមសិក្សាក៏អនុវត្តកម្មវិធីថ្មីនៅថ្នាក់ទី ៧ ដែរ ។ កម្មវិធីថ្មីនេះ ធ្វើឡើងក្នុងគោលបំនងផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្ត ផ្សារភ្ជាប់សាលាទៅនឹងសហគម ។ មានន័យថា អោយសិស្សយកចំនេះដឹងពីសាលារៀនទៅអនុវត្តបានក្នុងជីវភាពជាក់ស្តែង ដើម្បីលើកកំពស់ជីវភាពរបស់គេ អោយឈានទៅក្នុងអភិវឌ្ឍន៍ ។ ទន្ទឹមនឹងការអនុវត្តកម្មវិធីសិក្សាថ្មីនេះ យើងក៏បានសិក្សាដកពិសោធន៍ ដើម្បីរកចំនុចខ្វះខាត និងកែលំអជាបណ្តើរៗផងដែរ ។ មែនហើយ កម្មវិធីសិក្សាឆ្នាំ ១៩៩៦ បានតាក់តែងឡើងយ៉ាងរហ័ស ( ចាប់ផ្តើមឆ្នាំ ១៩៩៥) រយៈពេលសិក្សាក៏ខ្លី ហើយការយល់ដឹងពីលំនាំអភិវឌ្ឍ ក៏នៅមានកំរិត ។ ម៉្យាងទៀត ដោយសារបំរែបំរួលរហ័ស និងវិជ្ជមាននៃស្ថានភាពនយោបាយ នោះស្ថានភាពចិត្តសាស្ត្រ និងសេដ្ឋកិច្ច សង្គមក៏វិវឌ្ឍរហ័សផងដែរ ។ កម្មវិធីសិក្សា ដែលមានភារកិច្ចត្រៀមសិស្សអោយរីកចំរើនក្នុងកន្លងគុណធមិ ក៏ចាំបាច់ត្រូវកែលំអអោយសមស្របនឹងតំរូវការរបស់សហគមន៍ ។ ក្រៅពីនេះ នៅមានកត្តាច្រើនទៀត ដែលជំរុញអោយយើងគិតសាជាថ្មីឡើងវិញ ចំពោះកម្មវិធីដែលកំពុងតែមានអត្ថិភាព និងពិសោធនេះ ។ គឺនៅក្នុងស្មារតីនេះហើយ ដែលកម្មវិធីសិក្សាក្នុងប្រទេសជឿនលឿន តែងតែទទួលកែលំអជាអចិន្ត្រៃយ៍ តាមរយៈកាលកំនត់មួយសមស្របតាមលទ្ធភាពរបស់ប្រទេសនីមួយៗ ។

ចំពោះប្រទេសកម្ពុជា ដែលទើបនឹងចូលជាសមាជិកពេញសិទ្ធិនៃសមាគមអាស៊ាន ដែលបើកលទ្ធភាពប្រកួតប្រជែងរវាងធនធានមនុស្ស បច្ចេកទេសវិទ្យា និងផលិតកម្មនោះ ការពិចារណាពិៈរកគន្លឹះ ខ្លឹមសារ ផ្តល់ដល់សិស្សានុសិស្ស ដើម្បីបំពាក់អាវុធគ្រប់គ្រាន់អោយគេមានលទ្ធភាពចូលប្រលូក ដណ្តើមជោគជ័យក្នុងសៃវៀនប្រកួតប្រជែងនោះ គឺជាកាតព្វកិច្ចចាំបាច់របស់ក្រសួងអប់រំ ។ ម្យ៉ាងទៀត កត្តាបោះបង់ចោលសាលារៀនក៏រឹតតែជំរុញអោយអ្នកទទួលខុសត្រូវវិស័យអប់រំ និង

អង្គការអន្តរជាតិខ្លះ ចាប់អារម្មណ៍ និងវិរ:រកមធ្យោបាយជួយដល់អ្នកទាំងនោះបន្ថែមទៀត ។ កត្តាទាំងនោះកើតឡើងទន្ទឹមនឹងចរន្តសកលលោកនៃយុគសម័យថ្មី ដែលចង់បំពាក់ដល់សិស្សានុសិស្ស នូវ " សមត្ថភាពដោះស្រាយបញ្ហាដោយខ្លួនឯង " ។ ហេតុនេះហើយ ទើបក្រសួងអប់រំសហការ និងគំរោង PASEC បានខិតខំធ្វើអោយកម្មវិធីបុរេវិជ្ជាជីវៈ មានអត្ថិភាពឡើងបន្ថែមលើកម្មវិធីសិក្សា ដែលកំពុងដំណើរការសព្វថ្ងៃ ។

<u>គោលបំណងនៃកម្មវិធីបុរេវិជ្ជាជីវៈ</u>

កម្មវិធីបុរេវិជ្ជាជីវៈមានគោលបំណង :

- កាត់បន្ថយភាពឥតការធ្វើ
- ផ្តល់សមត្ថភាពលើកកំពស់ជីវភាពរស់នៅរបស់សិស្ស ដែលនឹងក្លាយជាអនាគតពលរដ្ឋ អោយរស់បានប្រសើរដោយសុចរិត ។
- បណ្តុះគំនិតផ្តួចផ្តើមច្នៃប្រឌិតដើម្បីអភិវឌ្ឍ
- បណ្តុះស្មារតីទទួលខុសត្រូវ ទុកចិត្តលើខ្លួន និងយល់ថា តុល្យភាពនៃទ្រឹស្តី និងការអនុវត្តជាការចាំបាច់ ។

<u>យុទ្ធវិធីរបស់កម្មវិធីបុរេវិជ្ជាជីវៈ</u>

កម្មវិធីបុរេវិជ្ជាជីវៈត្រៀមយុទ្ធវិធីសំរាប់សំរេចគោលបំណងខាងលើ ។ យុទ្ធវិធីទី ១ និងទី ២ អាចអនុវត្តទន្ទឹមគ្នាតែម្តង ឯយុទ្ធវិធីទី ៣ កំពុងស្ថិតនៅក្នុងការសិក្សា ។ យុទ្ធវិធីទាំងនោះមាន :

**<u>យុទ្ធវិធីទី ១</u>** : យុទ្ធវិធីនេះ គឺកម្មវិធីបញ្ជ្រាប ។

កម្មវិធីនេះគ្រោងអនុវត្តនៅថ្នាក់ទី ៦, ៧, ៨, ៩ លើមុខវិជ្ជា និងសៀវភៅសិក្សាដែលមានរួចហើយ កំពុងប្រើសព្វថ្ងៃ ។ យុទ្ធវិធីនេះ តំរូវអោយយើងពិនិត្យលើមេរៀន លើសកម្មភាពបង្រៀនបញ្ញត្តិនីមួយៗ ដើម្បីរកកន្លែងខ្វះខាត រឺចំនុចដែលអាចផ្តល់លទ្ធភាពអោយបញ្ជ្រាបសញ្ញាណវិជ្ជាជីវៈបាន ។ ក្នុងការបញ្ជ្រាបនេះ យើងណែនាំប្រើប្រាស់បញ្ញត្តិ រឺទ្រឹស្តីទៅក្នុងការអនុវត្តជាក់ស្តែងនៃមុខរបរផ្សេងៗ ។ ឧទាហរណ៍ : បញ្ញត្តិគណិតវិទ្យា អាចយកទៅប្រើក្នុងគណនេយ្យ, ស្ថិតិ, ជំនាំ -ល- ។ មុខវិជ្ជាខ្លះទៀត អាចផ្តល់សញ្ញាណមូលដ្ឋានផ្នែកសេដ្ឋកិច្ច, គ្រប់គ្រងសហគ្រាស, និងពត៌មានទីផ្សារជាដើម ។ ម្យ៉ាងទៀត កំណែលំអវិធីបង្រៀន រឺដំនឹកនាំសកម្មភាពខ្លះ ក៏ជួយអោយសិស្សមានបទពិសោធច្រើនបន្ថែមទៀតផងដែរ ។ យុទ្ធវិធីទី ១ នេះមានវត្ថុបំណងពង្រឹងពុទ្ធិ និងបំនិនសិស្ស ហើយមិនទាមទារពេលវេលាបន្ថែមច្រើន នឹងសំភារឧបទេសថ្លៃៗពេកទេ ។

**<u>យុទ្ធវិធីទី ២</u>** : យុទ្ធវិធីនេះ សំដៅបញ្ចូលកម្មវិធី " ការរៀបចំគំរោង " ក្នុងសាលារៀន ។

យុទ្ធវិធីនេះ មានសកម្មភាពប្លែកៗ ដែលតំរូវអោយសិស្សនិងគ្រូ ធ្វើសកម្មភាពរួមគ្នាក្នុងការរៀបចំគំរោង និងការគ្រប់គ្រងគំរោងអោយសិស្សជាអ្នកគ្រប់គ្រងខ្លួនឯងផ្ទាល់ ក្រោមការណែនាំរបស់គ្រូ ។ ការជ្រើសរើសគំរោងធ្វើឡើងដោយផ្អែកលើលទ្ធភាព និងតំរូវការជាក់ស្តែងរបស់មូលដ្ឋាន (សាលារៀន) ។ សកម្មភាពទាំងនេះ អាចជាដំណើរកំសាន្ត និងស្រាវជ្រាវបន្ថែមគ្នាមួយ ល្បែងដើរតួ, ឥណទានសាលារៀន, អាហារដ្ឋានសាលារៀន, មជ្ឈមណ្ឌលលក់ឧបករណ៍សិក្សាសាលារៀន, រោងជាងជួសជុលកង់ -ល- ។

យុទ្ធវិធីនេះ ជួយពង្រឹងជាពិសេស បំនិន និងឥរិយាបថរបស់សិស្ស ។ សិស្សរៀនយកចំនេះដឹង ទន្ទឹមនឹការអនុវត្ត ចំនេះដឹង (បំនិនជីវិត) ដូចជាគមនាគមន៍, គំនិត, ការលើកផែនការវង្វាយតំលៃ, វិភាគសភាពការណ៍, ការគ្រប់គ្រងគំរោង និង អង្គភាព -ល-។ សិស្សរៀលទទួលខុសត្រូវ បំរះនទៀល ជំនះឧបសគ្គ និងប្រថុយក្នុងការងារ ។ កម្មវិធីនេះ ផ្ដល់ឱកាសអោយ សិស្សបានផ្ដួចផ្ដើមគំនិត លើកទឹកចិត្តគ្នាទៅវិញទៅមក និងទុកចិត្តគ្នា ។

ការអនុវត្តយុទ្ធវិធីនេះ ត្រូវមានម៉ោងផ្ទាល់របស់ខ្លួន បន្ថែមលើម៉ោងសិក្សាមុខវិជ្ជាដែលមានរួចហើយ និងមានការ រៀបចំជាពិសេសរបស់សាលារៀនទៀតផង ។ ជួនកាល គ្រូគ្រប់មុខវិជ្ជា ត្រូវសហការណ៍គ្នា ដើម្បីរៀបចំសកម្មភាពពិសេស ទាំងនេះ ។

__យុទ្ធវិធីទី ៣__ : ការបញ្ចូលសញ្ញាណមូលដ្ឋាននៃមុខរបរ ។

បច្ចុប្បន្ន យុទ្ធវិធីទី ៣ នេះ គ្រាន់តែជាការគ្រូសត្រាយមួយសំរាប់ការពិចារណាកែលំអ ។ ប៉ុន្តែ យុទ្ធវិធីនេះ កំពុង តែឋិតនៅក្នុងបរិបទសារវន្តបំផុត និងចាំបាច់បំផុតសំរាប់ប្រទេសកម្ពុជាបច្ចុប្បន្ន ។ សំនើមានដូចតទៅ :

ចាប់តាំងពីថ្នាក់ទី ៧ ទៅ គួរមានសាខាអនុវត្តមួយ កម្មវិធីសាលានេះ ត្រូវផ្ដល់សញ្ញាណមូលដ្ឋាននៃមុខរបរនានា ដល់សិស្ស តំបន់នីមួយៗ សាលារៀននីមួយៗ អាចជ្រើសរើសមុខរបរណាដែលសាលាមានលទ្ធភាពនឹងទទួលយក រឺដែលមូល ដ្ឋាន រឺសហគមត្រូវការ រឺដែលសហគមន៏មានធនធានមនុស្សដឹកនាំដំណើរការសកម្មភាព ។

គេអាចមានលទ្ធភាពពីរយ៉ាងក្នុងការអនុវត្តយុទ្ធវិធីទី ៣ នេះ :

១- ដើម្បីអោយការអនុវត្តមានទំងន់ សិស្សទាំងអស់ត្រូវចាត់ទុកការឆ្លងកាត់កម្មវិធីសាខានេះជាកាតព្វកិច្ច ។

២- សិស្សដែលមានចំនង់ចំនូលចិត្តប៉ុននោះ ដែលត្រូវរៀនកម្មវិធីនៃសាខានេះ ។

គ្រូក៏អាចទូន្មានសិស្សក្នុងជំរើស និងការសំរេចចិត្តផងដែរ កម្មវិធីនៃសាខានេះ សំដៅបណ្ដុះបណ្ដាលសិស្សផ្នែក ទ្រឹស្ដី និងអោយសិស្សឆ្លងបទពិសោធអនុវត្តក្នុងសិប្បកម្មដែលមានក្នុងតំបន់ ដោយទស្សនកិច្ចសិក្សា រឺធ្វើកម្មសិក្សា ។

យុទ្ធវិធីនេះ ចង់ផ្ដោតចំនាប់អារម្មណ៏របស់សិស្សលើមុខរបរណាមួយដែលគេពេញចិត្ត រឺដែលគេយល់ថា សមស្រប នឹងលទ្ធភាពរបស់គេ ។ ម្យ៉ាងទៀត តាមរយៈកម្មវិធីនេះ សិស្សអាចពង្រឹងបំនិន និងសមត្ថភាពអនុវត្តរបស់គេ ។ កត្តានេះ នឹង ជួយអោយគេមានការងាយស្រួលក្នុងការរកមុខរបរបាន ។

ដើម្បីអនុវត្តយុទ្ធវិធីនេះ ចាំបាច់ត្រូវមានប្រភពធនធានមនុស្ស សំភារៈ និងហិរញ្ញវត្ថុគ្រប់គ្រាន់ : សាលាត្រូវ មានរោងជាង មានថវិកាសំរាប់ដំណើរការរោងជាង មានឧបករណ៏វត្ថុធាតុដើម និងអ្នកបង្ហាត់បង្រៀនប្រកបដោយសមត្ថភាព -ល-។

កម្មវិធីបុរេវិជ្ជាជីវៈបានយកចិត្តទុកដាក់លើចំនុចជាច្រើន :

១- សមភាពសំណាងរវាងបុរស និង នារី កម្មវិធីជួយនារី ជាពិសេសអោយមានតួនាទីក្នុងការអភិវឌ្ឍដូចយុវជន ដែរ ។

២- តុល្យភាពរវាងបរិដ្ឋាន និងមនុស្ស : មុខវិជ្ជាគ្រប់ប្រភេទសំដៅលើកកំពស់ការគ្រប់គ្រងធនធានធម្មជាតិ ។

៣- និរន្តរភាព : ឯកសាររៀនរបស់កម្មវិធីបុរេវិជ្ជាជីវៈមិនមានការបញ្ចប់ឡើយ : គេត្រូវគិតដល់ការបញ្ជ្រាប បច្ចេកវិទ្យាថ្មីបន្ថែមទៀត ដើម្បីអោយសមស្របតាមតំរូវការទីផ្សារ ដែលវិវត្តឥតឈប់ឈរ ។

៤- ភាពទន់ភ្លន់ : សាលារៀនមានលទ្ធភាពជ្រើសរើសឯកតាមេរៀនណាដែលសមស្របនឹងតំរូវការ រឺនឹងលទ្ធភាព របស់មូលដ្ឋាន ។

៥- ការចូលរួម : កម្មវិធីនឹងទទួលជោគជ័យបាន អាស្រ័យនឹងការចូលរួម ការសហការ និងការទទួលខុសត្រូវ របស់លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស មាតាបិតាសិស្ស ហើយនឹងសមាជិកដទៃទៀតនៃសហគមន៍ ។

ម្យ៉ាងទៀត នៅក្នុងកម្មវិធីបុរេវិជ្ជាជីវៈ ការបណ្តុះបណ្តាលគ្រូឧទ្ទេស គឺជាកត្តាមួយសារវន្តបំផុត ។ ក្នុងការបណ្តុះបណ្តាលនេះ មិនមែនមានតែពុទ្ធិថ្មីៗប៉ុននោះទេ ដែលគ្រូត្រូវត្រងត្រាប់ក្រេបជញ្ជក់នោះ ប៉ុន្តែ គ្រូត្រូវតែខំធ្វើអោយមានបំរែបំរួលឥរិយាបថទៅតាមគោលដៅនៃកម្មវិធីផងដែរ ។

ភារកិច្ចដែលគ្រូត្រូវខំបំពេញអោយបានសំរេចមានពីរ :

១- គ្រូជាអ្នកផ្តល់ពត៌មាន, គ្រូប្រមូលពត៌មានរៀបចំ, សំរបសំរួលពត៌មានតំរូវទៅតាមសេចក្តីត្រូវការរបស់សិស្ស និងមូលដ្ឋានដែលគេរស់នៅ ។

២- គ្រូជួយសិស្សអោយចេះរកពត៌មានដោយខ្លួនឯង

ដើម្បីជួយសិស្សបាន គ្រូត្រូវចេះ :

- សំរបសំរួលទៅតាមបទពិសោធដែលសិស្សមាន
- ដឹកនាំសិស្សដោយប្រើសំនួរបំផុស
- លើកទឹកចិត្តសិស្ស ធ្វើអោយសិស្សមានសំទុះជួសជុល
- បណ្តុះគំនិតផ្តួចផ្តើម និងទទួលខុសត្រូវ
- បង្រៀនសិស្សអោយចេះរៀន ។

គ្រូទទួលបន្ទុកបង្រៀនមុខវិជ្ជាបុរេវិជ្ជាជីវៈ ត្រូវមានពុទ្ធិលើច្រើនមុខវិជ្ជា និងចេះវិធីដឹកនាំមេរៀនច្រើនបែប ។ គ្រូនឹងទទួលការបណ្តុះបណ្តាល ដើម្បីទទួលបានគំនិតថ្មីបន្ថែមទៀត ។ ដើម្បីបន្តចំនេះដឹងទៅសិស្សបាន គ្រូត្រូវតែអនុវត្តជាក់ស្តែងដោយខ្លួនឯងផ្ទាល់ ។ ក្នុងករណីនេះ គ្រូត្រូវទទួលការបណ្តុះបណ្តាលច្រើនដំនាក់ បន្ទាប់ពីការបណ្តុះបណ្តាលជំហានបឋមរួច គ្រូត្រូវឆ្លងកាត់ការបណ្តុះបណ្តាលបំប៉នរយៈពេលខ្លីៗច្រើនសារទៀត ។

ប្រធានបទនៃការបណ្តុះបណ្តាលគ្រូឧទ្ទេសមានដូចតទៅ :

- នានាភាពនៃវិធីបង្រៀន ( ឧ : ការងារក្រុម, ល្បែង, ការដើរតួ -ល-)
- ការផលិត និងបំរើបំរាស់សំភារឧបទេសតាមលទ្ធភាពមូលដ្ឋាន
- វិធីដើម្បីបំផុសអោយសហគមន៍ចូលរួម ( បណ្តុះបទពិសោធ)
- ការគ្រប់គ្រងគំរោងគ្រប់គ្រងក្រុម ការបែងចែកការងារក្នុងក្រុម, ចំនាត់តាំង

- បច្ចេកទេសទំនាក់ទំនង : របៀបដឹកនាំសំនួរ ការរៀបចំទំរង់លទ្ធផល
- ពុទ្ធិមូលដ្ឋានទាក់ទងនឹងសេដ្ឋកិច្ច, ពាណិជ្ជកម្ម, ការអភិវឌ្ឍអង្គការ, និងការបណ្តុះភាពស្វាហាប់មុឺងម៉ាត់ម៉ត់ចត់ ។
- ពុទ្ធិទាក់ទងនឹងបច្ចេកវិទ្យាថ្មីៗនៃគមនាគមន៍ ។

ប្រធានបទនៃការបណ្តុះបណ្តាលនេះ ត្រូវតែផ្សារភ្ជាប់នឹងមេរៀនថ្មីៗ រឺគំរោងថ្មីៗ គេត្រូវតែទុកលទ្ធភាពខាងបណ្តុះបទពិសោធអោយបានច្រើនជាអតិបរមា ។

ម្យ៉ាងទៀត ការបណ្តុះបណ្តាលក៏ត្រូវតែមានប្រយោជន៍ចំពោះវិស័យផ្សេងទៀត ដែលអាចកើតមានជាយថាហេតុនៅតាមសាលាផងដែរ ។ (ឧ: ការគ្រប់គ្រងគំរោងឥណទាន -ល-) ។

សាលាត្រូវឆ្លៀតឱកាសប្រើប្រាស់ពុទ្ធិ និងសមត្ថភាពរបស់គ្រូ និងសិស្ស ដែលទទួលបាននៅក្នុងបទពិសោធនៃជីវភាពរាល់ថ្ងៃរបស់គេផងដែរ ។ សាលាត្រូវតែជាមជ្ឈមណ្ឌលរៀនសូត្រអចិន្ត្រៃយ៏របស់មនុស្សគ្រប់រូប ។

ឯកសាររបស់ ប៉ាសិច





# លិខិតចំហជូនចំពោះ
# សមាជិក-ជិកា សមាគមបុគ្គលិកសិក្សាខ្មែរ

កន្លងមកនេះ មានសមាជិកសមាគមយើងម្នាក់ បានសុំអោយខ្ញុំជួយបំភ្លឺអំពី :

១- ប្រាសាទអង្គរវត្តដែលមានកំពូលប្រាំ ។ តើកំពូលនីមួយ១តំណាងអ្វី ?

២- អច្ឆរិយវត្ថុនៃប្រាសាទអង្គរវត្ត

ដើម្បីជាគុណប្រយោជន៍ដល់បុគ្គលិកសិក្សាមួយចំនួន ដែលស្រពិចស្រពិលនៅឡើយពីបញ្ហានេះ ។

ក្នុងឋានៈខ្ញុំជារៀមច្បងនៃអង្គបុគ្គលិកសិក្សាខ្មែរ នឹងជាប្រធានសមាគម ខ្ញុំសូមបំភ្លឺជូន ក្នុងគោលបំនងបំពេញបន្ថែម កង្វះខាតចំនេះដឹង វីវប្បធមិទូទៅ ដើម្បីចៀសវាងចំលើយមិនត្រឹមត្រូវ ចំពោះសំនួររបស់សិស្ស វឺអ្នកដទៃដែលគេចាត់ទុកថា អ្នកមានវប្បធមិទូលាយ ។

<u>បញ្ហាទី ១</u> : មុននឹងនិយាយពីកំពូលប្រាំនៃប្រាសាទអង្គរវត្ត ខ្ញុំសូមជំរាបអំពីជំនឿរបស់អ្នកកាន់ព្រហ្មញ្ញសាសនាជាមុនសិន ។ តាមលោកធាតុសាស្ត្រឥណ្ឌា (cosmographie indienne) ភ្នំព្រះសុមេរុ រឺ ភ្នំមេរុ ជាមណ្ឌលកណ្ដាលនៃលោកធាតុ ។ ភ្នំមេរុ ព័ទ្ធជុំវិញដោយជួរភ្នំប្រាំពីរជាន់ ហើយជួរភ្នំនិមួយ១ ខ័ណ្ឌដាច់ពីគ្នាដោយសមុទ្រមួយជាន់១ មានសណ្ឋានមូល ។ នៅឯនាយជួរភ្នំខាងក្រោយបង្អស់ មានមហាសាគរលាតសន្ធឹង ។ នៅក្នុងមហាសាគរនេះ មានទ្វីបបួនតាំងនៅ ។ ទ្វីបនីមួយ១ឋិតនៅក្នុងទិសធំមួយក្នុងបណ្ដាទិសធំទាំងបួន ។ ទ្វីបឋិតនៅខាងត្បូងភ្នំមេរុ មានឈ្មោះថា **ជម្ពូទ្វីប** ជាលំនៅដ្ឋានរបស់មនុស្ស គឺប្រទេសឥណ្ឌាសព្វថ្ងៃ ។ នៅលើជំរាលភ្នំមេរុ មានភ្នំបួនឋិតនៅជុំវិញ មានឈ្មោះដូចគ្នាហៅថា **ភ្នំយុគន្ធរ** ។ នៅលើភ្នំទាំងបួននេះ មានឋានសួគ៌ជាន់ទាបបំផុតតាំងនៅ ។ ស្ថាននីមួយ១មានឈ្មោះដូចគ្នា ហៅថា (**ចាតុម្មហារាជិកាសួគ៌**) ដែលជាស្ថានរបស់ទេវតាចាំថែរក្សាពិភពលោក ។ (សូមអានឧបសម្ព័ន្ធ)

ខ្ញុំសូមស្លេះប៉ុននេះចុះ ដោយរចនាសម្ព័ន្ធពិភពលោកមានរឿងនិទានវែងឆ្ងាយច្រើនណាស់ ។ ខ្ញុំសូមត្រលប់មកដោះស្រាយសំនួរដែលសួរថា តើកំពូលទាំង ៥ នៃប្រាសាទអង្គរវត្តតំណាងអ្វី ?

<u>ចំលើយ</u> : * កំពូលធំកណ្ដាល តំណាងកំពូលភ្នំព្រះសុមេរុ

* កំពូលនៅជ្រុងទាំងបួន តំណាងកំពូលភ្នំយុគន្ធរ ដែលនៅលើភ្នំនីមួយៗ មានប្រាសាទរបស់ទេវតារក្សាពិភពលោក ។

លំដាប់តទៅនេះ ខ្ញុំសូមជំរាបបន្ថែមថា នាសម័យអង្គរ ព្រះមហាក្សត្រសោយរាជ្យដែលមានជំនឿ និងគោរពបូជាទេវអង្គណាមួយ តែងតែកសាងវិមានអនុស្សាវរីយ៍របស់ព្រះអង្គចំពោះទេវនោះ ដូចជា ប្រាសាទអង្គរវត្ត ឧទ្ទិសថ្វាយចំពោះព្រះវិស្ណុ ។ ប្រាសាទបាខែង ជារាជធានីថ្មីទី ២ នៃប្រទេសកម្ពុជា មានឈ្មោះថា **យសោធរបុរៈ** ដែលយើងនិយមហៅថា **មហានគរ រឺ អង្គរធំ** ។ ភ្នំបាខែងជាស្នូលនៃមហានគរ ។ ប្រាសាទដែលកសាងនៅលើភ្នំនេះ ឧទ្ទិសថ្វាយចំពោះព្រះសីវៈ រឺ ឥសូរ ដោយព្រះបាទយសោវរ្ម័នទី ១ (គ.ស. ៨៨៩ - ៩០០) ។

នៅពាក់កណ្ដាលទីពីរនៃស.វ ទី ១២ **ព្រះបាទជ័យវរ្ម័នទី ៧** បានកសាងប្រាសាទ **បាយ័ន រឺព្រហ្មបាយ័ន** ដើម្បីឧទ្ទិសថ្វាយចំពោះព្រះពុទ្ធសាសនា ដោយព្រះអង្គកាន់ពុទ្ធសាសនាមហាយាន ។ ប្រាសាទនេះជាមណ្ឌលកណ្ដាលនៃមហានគរ រឺអង្គរធំ ជំនួសប្រាសាទ **បាខែង** ។

សូមជំរាបបន្ថែមថា ព្រះបរមរាជវាំងនៃព្រះរាជាណាចក្រកម្ពុជាសព្វថ្ងៃ បានកសាងតាមទស្សនៈលោកធាតុ វិទ្យាដែលយកភ្នំព្រះសុមេរុជាស្នូល ។ ប្រាសាទទេវាវិនិច្ឆ័យចាត់ទុកជាភ្នំព្រះសុមេរុ ។

<u>បញ្ហាទី ២</u> : កាលណាគេធ្វើដំណើរចេញពីទីរួមខេត្តសៀមរាប ឆ្ពោះទៅទិសខាងជើង គេនឹងប្រទះឃើញប្រាសាទមួយដ៏ល្អអស្ចារ្យ ដែលធ្វើអោយស្ញប់ស្ញែងដល់ទេសចរបរទេស និង កម្ពុជា ។ ប្រាសាទអង្គរវត្ត ត្រូវបានចាត់ថ្នាក់ជាអច្ឆរិយវត្ថុដែលមានលើសកលលោកសព្វថ្ងៃ ។

ហេតុអ្វីបានជាបុរាណវត្ថុវិទូចាត់ទុកអង្គរវត្តជាអច្ឆរិយវត្ថុ ? សូមពិចារណាអោយច្បាស់ទើបឃើញភាពអស្ចារ្យ ។

* ប្រទេសកម្ពុជានៅស.វ. ទី ០៩-១០-១១ និង ១២ មានអរិយធម៌ និង វប្បធម៌ លូតលាស់ដល់កំពូលដែលជាកត្តាចំបងក្នុងការកសាងប្រាសាទ ។ ព្រះសុរិយាវរ្ម័នទី ២ (១១១៣ - ១១៥០) ដែលបានសាងប្រាសាទអង្គរវត្ត (ឯកសារខ្លះថា **នគរវត្ត**) ជាក្សត្រខ្លាំងពូកែក្នុងការធ្វើសឹកសង្គ្រាម និងក្នុងការរៀបចំកិច្ចការត្រួតត្រាដឹកនាំប្រទេសទៅរកសេចក្ដីសុខចំរើន ។

* សំណង់ប្រាសាទ មានបច្ចេកទេសខ្ពស់ ។ ថ្មបាយក្រៀម, ថ្មភក់, ថ្មភ្នំ បន្តុបលើគ្នាបានស្អិតជាប់គ្នា កើតបានជាជញ្ជាំង ជាដំបូល ជាកំពូល ។ កំពូលកណ្ដាលខ្ពស់ជាងគេ មានកំពស់ ៦៥ម សង់ដោយឥតមានស៊ីម៉ង់ត៍ និង ដែកឡើយ ។

* ប្លង់សំណង់ និង រូបចម្លាក់លើជញ្ជាំង គួរអោយកោតសរសើរចំពោះស្នាដៃស្ថាបត្យករ និង វិចិត្រករ ព្រោះទស្សនាទៅគ្រប់ទិសទីឃើញថា សមល្អ ។

ចំលើយខ្ញុំប៉ុននេះ ទុកគ្រាន់ជាពន្លឺបង្ហាញនូវភាពអស្ចារ្យនៃប្រាសាទអង្គរវត្ត ។ ខ្ញុំសូមលោកគ្រូ-អ្នកគ្រូសិក្សាខ្លួនឯងបន្ថែមទៀត ហើយសូមកុំមានវាចាថា មិនមានអ្វីដ៏អស្ចារ្យនោះឡើយ ខ្មាស់គេ ។

យ៉ង់ ឌី

# ឧបសម្ព័ន្ធ

**១- មហាទ្វីប គឺ :**

- បូព៌វិទេហទ្វីប នៅខាងកើត
- ជម្ពូទ្វីប នៅខាងត្បូង
- ឧត្តរកុរុទ្វីប នៅខាងជើង
- អបរគោយានទ្វីប នៅខាងលិច

**២- ចតុលោកបាល :** (ចៈតុលោកៈបាល) ចតុល្លោកបាល : ស្ដេចទេវតា ៤ អង្គជាធំក្នុងចាតុម្មហារាជិកាសួគ៌ ជាអ្នករក្សាលោក គឺ ព្រះបាទ

- ធតរដ្ឋ រក្សាទិសខាងកើត
- វិរុឡ្ហកៈ រក្សាទិសខាងត្បូង
- វិរូបក្ខៈ រក្សាទិសខាងលិច
- កុវេរៈ រក្សាទិសខាងជើង

# ប្រព័ន្ធសាលាសម្ព័ន្ធមេត្រី

## Système des écoles associées (SEA)

" យើងរស់នៅលើពិភពលោកតែមួយ. យើងរៀនដើម្បីពិភពលោកតែមួយ "
« Nous vivons dans un seul monde, nous apprenons pour un seul monde »

### អ្វីទៅជាប្រព័ន្ធសាលាសម្ព័ន្ធមេត្រី ?

ប្រព័ន្ធសាលារៀនសម្ព័ន្ធមេត្រី (ប.ស.ស) នៃអង្គការយូណេស្កូ គឺជាប្រព័ន្ធសាលារៀនទូទាំងពិភពលោក ដែលទទួលភារកិច្ចអនុវត្តតាមឧត្ដមគតិរបស់អង្គការយូណេស្កូ ។

ចាប់តាំងពីត្រូវបានបង្កើតឡើងនៅឆ្នាំ ១៩៥៣ សាលារៀនសម្ព័ន្ធមេត្រី បានលើកកំពស់ការអប់រំសំរាប់ការយោគយល់គ្នាជាអន្តរជាតិ ដើម្បីរៀបចំកុមារ និង យុវជន អោយចេះខិតខំប្រឹងប្រែងអស់ពីលទ្ធភាព ប្រឈមមុខដើម្បីអនាគត ។

នៅឆ្នាំ ១៩៩៩ ប្រព័ន្ធសាលារៀនសម្ព័ន្ធមេត្រី រួមមានជាង ៦០០០ ស្ថាប័ន ដែលរាប់ចាប់ពីសាលាមត្តេយ្យ រហូតដល់ស្ថាប័នបណ្ដុះបណ្ដាលគ្រូ នៅក្នុង ១៦៣ ប្រទេស ។

គោលបំណងសំខាន់នៃបណ្ដាញ គឺដើម្បីផ្ដល់ជាវិភាគទានចំពោះការផ្លាស់ប្ដូរពីវប្បធម៌នៃសង្គ្រាម និងអំពើហិង្សា ដែលមានសព្វថ្ងៃនេះ ទៅជាវប្បធម៌សន្តិភាព និង ប្រជាធិបតេយ្យ ។

គ្រូទាំងឡាយដែលមកពីសាលា ដែលបានមកចូលរួម ត្រូវបានអញ្ជើញអោយចូលរួមនៅក្នុងគំរោង ដើម្បីបន្តការអប់រំដើម្បីសន្តិភាព សិទ្ធិមនុស្ស និងប្រជាធិបតេយ្យ ដោយធ្វើការកែលំអ ខ្លឹមសារអប់រំ វិធីសាស្ត្រ និង សំភារៈ ។

ព្រះរាជាណាចក្រកម្ពុជា គឺជាផ្នែកមួយនៃបណ្ដាញប្រព័ន្ធសាលាសម្ព័ន្ធមេត្រី ចាប់តាំងពីឆ្នាំ ១៩៩៦ និងក្នុងនោះមានសាលា ៥០ ចូលរួម ។

សាលាដែលបានចូលរួម គឺអាចផ្ដួចផ្ដើមសកម្មភាព និងគំរោងផ្សេងៗដោយសេរី យោងទៅតាមការចាប់អារម្មណ៍របស់ខ្លួនរៀងៗខ្លួន ។ ខ្លឹមសារចំបងបួន ដែលមានរាយនាមខាងក្រោមនេះ គឺគ្របដណ្ដប់ទៅលើខ្លឹមសារតូចៗជាច្រើនទៀត ដែលខ្លឹមសារទាំងអស់នោះទាក់ទងគ្នា :

. ការយកចិត្តទុកដាក់របស់ពិភពលោក និង តួនាទីរបស់ប្រព័ន្ធអង្គការសហប្រជាជាតិ ដែលត្រូវដោះស្រាយចំពោះបញ្ហានេះ ។

. សិទ្ធិមនុស្ស ប្រជាធិបតេយ្យ និង ការអត់អោន

. ការសិក្សាវប្បធម៌ពីគ្នាទៅវិញទៅមក

. បញ្ហាបរិស្ថាន

លើសពីនេះទៅទៀត សាលារៀនទាំងឡាយត្រូវបានជំរុញលើកទឹកចិត្តអោយចូលរួម " គំរោងពិសោធ" អន្តរជាតិ ឺ តាមតំបន់ ។ តាមរយៈនេះ " ពិធីបុណ្យវប្បធម៌សន្តិភាពរបស់កុមារនៅតំបន់ " ចំនួនប្រាំពីរ ត្រូវបានរៀបចំឡើងនៅលើពិភពលោក ។ គ្រូ និង កុមារចំនួន ៥០០ នាក់ មកពីប្រទេសចំនួន ៥១ បានចូលរួមនៅក្នុងពិធីបុណ្យនេះ ដើម្បីពិភាក្សាពីបញ្ហាដែលទាក់ទិនទៅនឹងសន្តិភាព នៅក្នុងឱកាសខួបលើកទី ៥០ នៃអង្គការសហប្រជាជាតិ និងអង្គការយូណេស្កូ ។

ការខិតខំប្រឹងប្រែងរបស់អង្គការយូណេស្កូ គឺដើម្បីស្វែងរកវិធីដ៏គួរអោយរីករាយ ដើម្បីបង្រៀនអំពីសន្តិភាពនៅក្នុងពិភពជម្លោះ និង អំពើហិង្សា ។ លទ្ធផលគឺជាផ្នែកនៃការធ្វើពិសោធនៃ " ឯកសារសន្តិភាព " ដែលបានបំពេញដោយការអប់រំ ចំណាប់អារម្មណ៍ ឯកសារកំសាន្ត ដែលគ្រូទាំងឡាយអាចប្រើប្រាស់នៅក្នុងថ្នាក់ និងនៅតាមផ្ទះ ដើម្បីបណ្តុះនូវសារៈសំខាន់ក្នុងផ្នត់គំនិតរបស់ក្មេងៗ ។

មានឯកសារជាង ៦០០ ត្រូវបានផ្ញើទៅប្រព័ន្ធសាលាសម្ព័ន្ធមេត្រីរបស់អង្គការយូណេស្កូ ដើម្បីធ្វើការដកពិសោធ ។ យើងបានទទួលផងដែរ នូវការឆ្លើយតបដ៏ល្អឥតខ្ចោះ ពីសាលាសម្ព័ន្ធមេត្រីរបស់អង្គការយូណេស្កូជាច្រើន ដែលបានចូលរួមក្នុងការដកពិសោធនេះ ។

អាស្រ័យហេតុនេះ យើងយល់ឃើញថា ឯកសារសន្តិភាព អាចជាវិភាគទានមួយប្រកបដោយនិរន្តភាព ចំពោះ "ឆ្នាំអន្តរជាតិ សំរាប់វប្បធម៌សន្តិភាព " (២000) ។ បច្ចុប្បន្ន យើងកំពុងតែបកប្រែអោយទៅជាភាសាផ្លូវការរបស់អង្គការយូណេស្កូ ហើយយើងជំរុញលើកទឹកចិត្តអោយរដ្ឋ ដែលជាសមាជិកបកប្រែឯកសារទាំងនេះ អោយទៅជាភាសាកំណើតរបស់ពួកគេ ។ អាជ្ញាធរកម្ពុជាកំពុងធ្វើការលើផ្នែកឯកសារសន្តិភាពកម្ពុជា ។

ប្រព័ន្ធសាលាសម្ព័ន្ធមេត្រីមួយផ្សេងទៀត " គំរោងពិសោធ " គឺជាគំរោងអប់រំកេរដំណែលពិភពលោក ដែលគំរោងនេះ ព្រះរាជាណាចក្រកម្ពុជា មានការចាប់អារម្មណ៍ជាពិសេស ពីព្រោះតែប្រទេសនេះ សំបូរទៅដោយកេរដំណែល ។ ប្រព័ន្ធសាលាសម្ព័ន្ធមេត្រីនៅកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងគំរោងនេះ ។

កម្មវិធីភ្ជាប់រវាងសាលាដែលបានចូលរួម និង សំភារៈបំលាស់ប្តូរ សិស្ស និង គ្រូ នឹងត្រូវបានចាត់ទុកដូចជាសកម្មភាពដ៏សកម្មសំខាន់មួយនៃប្រព័ន្ធសាលាសម្ព័ន្ធមេត្រី ។

រាល់ប្រព័ន្ធសាលាសម្ព័ន្ធមេត្រីទាំងនេះ មានគោលបំណងរួមគឺ : សិក្សាដើម្បីរស់នៅជាមួយគ្នា ដោយចុះសម្រុងនឹងគ្នា សន្តិភាព និង កិត្តិយស ដោយកសាងទំនាក់ទំនង និង ការផ្លាស់ប្តូររវាងសាលា និងមនុស្សក្មេងៗនៅក្នុងពិភពលោក ។

ដោយ អៀង សុខ អង្គភាពសំរបសំរួល
ប្រព័ន្ធសាលាសម្ព័ន្ធមេត្រី - អង្គការយូណេស្កូ

# បញ្ជីរាយឈ្មោះសាលាសម្ព័ន្ធមេត្រីនៅកម្ពុជា

## ក- អនុវិទ្យាល័យ និង វិទ្យាល័យ :

១- វិទ្យាល័យ បាក់ទូក (ភ្នំពេញ)
២- វិទ្យាល័យ បឹងត្របែក (ភ្នំពេញ)
៣- វិទ្យាល័យ ច្បារអំពៅ (ភ្នំពេញ)
៤- វិទ្យាល័យ ឥន្ទ្រទេវី (ភ្នំពេញ)
៥- វិទ្យាល័យ ព្រះស៊ីសុវត្ថិ (ភ្នំពេញ)
៦- វិទ្យាល័យ ព្រះយុគន្ធរ (ភ្នំពេញ)
៧- វិទ្យាល័យ ទួលទំពូង (ភ្នំពេញ)
៨- វិទ្យាល័យ ឫស្សីកែវ (ភ្នំពេញ)
៩- វិទ្យាល័យ ១ ឧសភា (តាកែវ)
១០-វិទ្យាល័យ ជាស៊ីម តាកែវ (តាកែវ)
១១-វិទ្យាល័យ ត្បែងមានជ័យ (ព្រះវិហារ)
១២-វិទ្យាល័យដីដែក (សៀមរាប)
១៣- វិទ្យាល័យ ក្រឡាញ់ (សៀមរាប)
១៤- វិទ្យាល័យ ទេព្យប្រណម្យ (កណ្តាល)
១៥- វិទ្យាល័យ ស្វាយអន្ទរ (ព្រៃវែង)
១៦- វិទ្យាល័យ ស្រុកភ្នំពេញ (កណ្តាល)
១៧- វិទ្យាល័យ មុនីវង្ស (បាត់ដំបង)
១៨- វិទ្យាល័យ ហ៊ុនសែនចំបក់ (កំពង់ស្ពឺ)
១៩- វិទ្យាល័យ ហ៊ុនសែនប្រសូតិ (ស្វាយរៀង)
២០- វិទ្យាល័យ ពោធិសាត់ (ពោធិសាត់)
២១- វិទ្យាល័យ សម្តេចឪ (បន្ទាយមានជ័យ)
២២- វិទ្យាល័យ ទ្រៀល (កំពង់ធំ)
២៣- វិទ្យាល័យ ព្រះអង្គឌួង (ព្រៃវែង)
២៤- អនុវិទ្យាល័យ សង្គមរាស្រ្តនិយម (កែប)
២៥- វិទ្យាល័យ បវេល (បាត់ដំបង)
២៦- វិទ្យាល័យ សុភាម្រិត (កំពង់ឆ្នាំង)
២៧- វិទ្យាល័យ សុខាផល្លី (កំពង់ស្ពឺ)
២៨- វិទ្យាល័យ ព្រះបីតាថវិកាជាតិ (កំពត)
២៩- វិទ្យាល័យ ព្រះរាជសម្ភារ (កំពត)
៣០- អនុវិទ្យាល័យ អង្គរ (សៀមរាប)
៣១- វិទ្យាល័យ ហ៊ុនសែន (វាលរេញ) (ក្រុងព្រះសីហនុ)
៣២- វិទ្យាល័យ ព្រះសីហនុ (កំពង់ចាម)
៣៣- វិទ្យាល័យ ហ៊ុនសែន (ស្គន់) (កំពង់ចាម)
៣៤- វិទ្យាល័យ ព្រះរាជបូជនកិច្ច (ស្ទឹងត្រែង)
៣៥- វិទ្យាល័យ សម្តេចឪ សម្តេចម៉ែ (រតនគិរី)
៣៦- វិទ្យាល័យ កោះកុង (កោះកុង)

## ខ- សាលាបឋមសិក្សា

១- សាលាបឋមសិក្សា បល្ល័ង្ក (កំពង់ធំ)
២- សាលាបឋមសិក្សា ចំបក់ (កំពង់ស្ពឺ)
៣- សាលាបឋមសិក្សា ទក្សិណ (កំពង់ចាម)
៤- សាលាបឋមសិក្សា គំរូក្រុង (កំពង់ឆ្នាំង)
៥- សាលាបឋមសិក្សាហ៊ុន សែន (វត្តកំពត) (កំពត)
៦- សាលាបឋមសិក្សា ព្រះសីហនុ "ក្រុង" (ក្រុងព្រះសីហនុ)
៧- សាលាបឋមសិក្សា ប៊ុនរ៉ានីហ៊ុនសែន ប្រាសាទនាងខ្មៅ (តាកែវ)
៨- សាលាបឋមសិក្សា ពាមរក៍ (ព្រៃវែង)
៩- សាលាបឋមសិក្សា បាកាន (ពោធិសាត់)
១០- សាលាបឋមសិក្សា អន្លង់វិល (បាត់ដំបង)
១១- សាលាបឋមសិក្សា វត្តកំផែង (បាត់ដំបង)
១២- សាលាបឋមសិក្សា វត្តបូព៌ (សៀមរាប)
១៣- សាលាបឋមសិក្សា តាខ្មៅ (កណ្តាល)
១៤- សាលាបឋមសិក្សា ព្រះសីហនុ (ស្វាយរៀង)

# កំណើតពុម្ពអក្សរ និង ការបោះពុម្ព

ជនាន់ដើម សំនេរទាំងអស់ទោះជាកិច្ចការរដ្ឋក្តី គម្ពីរសាសនាក្តី សុទ្ធតែសរសេរដោយដៃ ។ ចំពោះប្រទេសខ្មែរយើងវិញ បានយកស្លឹករឹតមកចារធ្វើជាក្បួនច្បាប់ផ្សេងៗ និងគម្ពីរពុទ្ធសាសនា មានគម្ពីរព្រះត្រៃបិដកជាដើម សំរាប់កុលបុត្រសិក្សា ។ សំនេរបែបនេះ ឃើញយឺតយូរផង ហើយចំនាយអស់ប្រាក់ច្រើនផង ម្លោះហើយ សៀវភៅនិងគម្ពីរនីមួយៗ ត្រូវលក់ថ្លៃ ហើយមិនងាយនឹងរកទិញបានផង ។

នៅគ.ស ១០៤០ សិប្បករចិនម្នាក់ឈ្មោះ ពីសេង បានផ្ចង់ចិត្តឆ្លាក់អក្សរលើដុំបួនជ្រុងស្មើតូចៗ ធ្វើពីដីឥដ្ឋទន់ៗ រួចយកទៅកំដៅភ្លើងអោយរឹង ។ បន្ទាប់មក គាត់យកដីរឈើមកបិទពុម្ពអក្សរនេះភ្ជាប់លើក្តារកំនល់មួយ ហើយជ្រលក់លក្ត័មុននឹងយកក្រដាសមកសង្កត់ពីលើយ៉ាងខ្លាំង ដើម្បីបោះពុម្ព ។

ស្នាដៃរបស់សិប្បករចិនឈ្មោះ ពីសេង មិនទាន់បានបំរើផលប្រយោជន៏ទូលំទូលាយឡើយ គ្រាន់តែជាចំនុចចាប់ផ្តើមនៃការបង្កើតពុម្ពអក្សរប៉ុននោះ ។

នៅ គ.ស ១៤៤០ លោក ហ្គុតតង់ប៊ែរ (GUTENBERG) ជាតិអ័ល្លឺម៉ង់ នៅម៉ៃយ៉ង្ស (MAYENCE) បានបង្កើតពុម្ពឈើបោះពុម្ពអក្សរឡើង ។ កំនើតពុម្ពអក្សរឈើបោះដោយសង្កត់ពីលើនេះ មានតំលៃខ្ពស់ណាស់ ប៉ុន្តែគួរអោយស្តាយ ព្រោះដំបូងឡើយ គ្មាននរណាទទួលស្គាល់ និងជួយអបអរសាទរចំពោះការបង្កើតថ្មីនេះសោះ ។ ផ្ទុយទៅវិញ ពួកគេបារម្ភក្រែងវប្បធម៏ចុះអាប់រស្មី ព្រោះម្យ៉ាង គេមិនចង់អោយអក្សរសាស្ត្រធ្លាក់ចុះក្នុងកណ្តាប់ដៃពួកឈ្មួញ គេពុំចង់បង្កើតពុម្ពអក្សរ ដោយខ្លាចអ្នកចំលងអក្សរនិងស្មៀនកត់ត្រាត្រលប់ទៅជាមនុស្សអត់ការធ្វើ ។

ក្នុងពេលសន្និសីទមួយនៅស័របោន (SORBONNE) ទីក្រុងប៉ារីស សាស្ត្រាចារ្យម្នាក់បាននិយាយថា " ការបង្កើតពុម្ពអក្សរចេញពីក្បាល ហ្គុតតង់ប៊ែរ នោះជាបទឧក្រិដ្ឋមួយចំពោះវប្បធម៏ ។ ខ្ញុំគ្មានជំនឿលើពួកជាង និងយន្តការីថា មានសមត្ថភាពនឹងច្នៃអក្សរសាស្ត្រអោយលូតលាស់កើតឡើយ ខ្ញុំចេញមុខប្រឆាំងនឹងការបោះពុម្ពសៀវភៅជាដាច់ខាត " ។

អ្នកស្តាប់ទាំងប៉ុន្មានទះដៃសំដែងសេចក្តីគាប់ចិត្ត ចំពោះយោបល់នេះគ្រប់ៗគ្នា ។ ទោះបីមានគេមិនពេញចិត្តនឹងការបោះពុម្ពសៀវភៅក៏ដោយ ទឹកចិត្តរបស់លោក ហ្គុតតង់ប៊ែរ នៅតែឆ្ពោះទៅមុខជានិច្ច មិនរាថយឡើយ ។ នៅម៉ៃយ៉ង្ស (MAYENCE ) លោកហ្គុតតង់ប៊ែរ បានចូលហ៊ុនជាមួយនឹង ហ្ស ហ្វុស្ត (J. FUST) ដើម្បីបោះពុម្ពគម្ពីរសាសនាគ្រិស្ត ជាអក្សរឡាតាំង ។ ពោលនោះ អ្នកប្រឆាំងនឹងរោងពុម្ព បាននាំគ្នាដើរទិញសៀវភៅសរសេរដោយដៃប្រមូលទុក ព្រោះសង្ឃឹមថា នៅថ្ងៃក្រោយ មុខជាឡើងថ្លៃច្រើន ។

ក្នុង គ.ស ១៤៤៨ គម្ពីរសាសនាគ្រិស្ត បានផ្សាយចេញពីរោងពុម្ពហ្គុតតង់ប៊ែរ នៅលើកដំបូងជាច្រើនក្បាល ។ ពួកបញ្ញវ័ន្តនៅទ្វីបអឺរ៉ុប បាននាំគ្នាទៅប្រទេសអ័ល្លឺម៉ាញ (ALLEMAGNE ) ដើម្បីទិញគម្ពីរបោះពុម្ពមកពិនិត្យមើល ។ លុះឃើញថាអក្សរពុម្ពមានលំនាំដូចអក្សរដៃ ហើយសេចក្តីពាក្យពេចន៏ក្នុងគម្ពីរនៅដដែល ព្រមទាំងគម្ពីរនោះលក់ថ្លៃថោក ជាងគម្ពីរមុនពីរដងផង ទើបសេចក្តីថប់បារម្ភទាំងប៉ុន្មាន ក៏ស្រាកស្រាន្តទៅវិញ ។

លោកហ្គុតតង់ប៊ែរ មិនគ្រាន់តែបន្តការបោះពុម្ពគម្ពីរផ្សេងៗទេ លោកបានរំលាយសំនចាក់ពុម្ពអក្សរជំនួសពុម្ពឈើអោយកាន់តែប្រសើរជាងមុន ។ គ្រាក្រោយមក អ្នកបច្ចេកទេសនៅទ្វីបអឺរ៉ុប និងអាមេរិក បានកែសំរួលពុម្ពអក្សរពុម្ពរូបគំនូសំភារៈ

បោះពុម្ព ព្រមទាំងរបៀបបោះពុម្ពអោយកាន់តែបានច្រើន ហើយកាន់តែបានល្អប្រសើរឡើង ។ តែការបោះពុម្ពនេះ នៅប្រើកំលាំងមនុស្សនៅឡើយ ។ លុះដល់សតវត្សទី ១៩ ទើបគេបានបង្កើតម៉ាស៊ីនបោះពុម្ពដើរដោយកំលាំងចំហាយទឹក ។

ក្នុងសម័យតិកនិក គេកែប្រែម៉ាស៊ីនបោះពុម្ពអោយដើរដោយកំលាំងអគ្គិសនីវិញ ។ ម៉ាស៊ីនចុងក្រោយនេះ អាចបោះពុម្ពបានពី ១ ម៉ឺនទៅ ២ ម៉ឺនសន្លឹកក្នុងមួយម៉ោង ។ ជាពិសេសទៅទៀត សព្វថ្ងៃនេះជាសម័យកុំព្យូទ័រ គេកំពុងតែនិយមប្រើខ្នាតពុម្ពអក្សរចេញពីម៉ាស៊ីនកុំព្យូទ័រ ឯការបោះពុម្ពបន្តិចបន្តួច គេមិនចាំបាច់ទៅរោងពុម្ពទេ គឺគេប្រើម៉ាស៊ីនថតចំលងរហ័សទាន់ចិត្ត ងាយស្រួលបំផុត ។

ការបោះពុម្ពសៀវភៅនៅប្រទេសកម្ពុជាយើង ទើបតែចាប់ផ្ដើមនៅដើមសតវត្សទី ២០ នេះទេ ប៉ុន្តែគេមិនអាចធ្វើទៅបានដោយងាយស្រួលដូចបច្ចុប្បន្ននេះឡើយ ។ ដើម្បីបោះពុម្ពសៀវភៅណាមួយ ត្រូវឆ្លងកាត់ការត្រួតពិនិត្យពីសម្ដេចសង្ឃនាយកទាំងពីរគណៈ និងពីគណៈរដ្ឋមន្ត្រីជាមុនសិន ។

ខ្មែរយើងសម័យនោះ គេប្រកាន់ដាច់ខាតណាស់ ក្បួនតម្រាទំនៀមទំលាប់ប្រពៃណីផ្សេងៗ ជាពិសេស ធម៌វិន័យ ពុទ្ធសាសនា បើគេចារឹត រឹសរសេរលើស្លឹករឹត ទើបគេទទួលស្គាល់ថា ជារបស់ពិតត្រឹមត្រូវតពីបុរាណកាលមក ។ ឯការបោះពុម្ព ជាសៀវភៅគេសំគាល់ទុកថា ជារបស់កើតថ្មី របស់ក្លែងក្លាយមិនត្រឹមត្រូវ ។

ក្នុងរាជ្យព្រះបាទសម្ដេចព្រះស៊ីសុវត្ថិ គ្រងរាជ្យសម្បត្តិក្នុងអាណាចក្រកម្ពុជា សម្ដេចព្រះធម្មលិខិត ព្រះនាម តែ អ៊ុត សង្ឃនាយកគណៈមហានិកាយ មានចេញព្រះរាជប្រកាសមួយលេខ ៧១ ចុះថ្ងៃ ២ តុលា ១៩១៨ បានចេញផ្សាយទៅគ្រប់វត្តក្នុងព្រះរាជាណាចក្រកម្ពុជា ។ ព្រះរាជប្រកាសនោះបញ្ញត្តិថា " ភិក្ខុ សាមណេរ ខាងគណៈមហានិកាយ ត្រូវប្រតិបត្តិតាមទំនៀមទំលាប់នៃសម្ដេចព្រះមហាសង្ឃរាជ ព្រះនាម និល ទៀង ខាងគណៈធម្មយុត្តិកនិកាយ ត្រូវប្រតិបត្តិតាមទំនៀមទំលាប់ នៃសម្ដេចព្រះសុគន្ធាធិបតី ព្រះនាម ប៉ាន ។ ភិក្ខុសាមណេរប្រព្រឹត្តខុសពីទំនៀមទំលាប់ខាងលើនេះ នឹងត្រូវមានកំហុស ត្រូវទទួលទណ្ឌកម្មតាមទោសានុទោស ។

រឿងជាក់ស្ដែងមួយជាសក្ខីភាព គឺក្រោយចេញព្រះរាជប្រកាសលេខ ៧១ នេះ សម្ដេចព្រះសង្ឃរាជ គណៈមហានិកាយ ព្រះនាម ជួន ណាត (កាលស្ថិតនៅជាព្រះគ្រូសង្ឃសត្ថា) លោកបានព្យាយាមរៀបរៀងសៀវភៅវិន័យមួយឈ្មោះ **បាតិមោក្ខសង្ខេប** ជាវិន័យសំរាប់ភិក្ខុសង្ឃប្រតិបត្តិ ។ រៀបរៀងហើយ លោកបានយកទៅសុំការអនុញ្ញាតដើម្បីបោះពុម្ពជាសៀវភៅ ប៉ុន្តែ សម្ដេចសង្ឃនាយក និងគណៈរដ្ឋមន្ត្រីមិនយល់ព្រម លោកក៏យកសៀវភៅនោះមកវិញ ។ ដោយការចង់ចេះចង់ដឹង ភិក្ខុសាមណេរ ក៏នាំគ្នាចំលង **បាតិមោក្ខសង្ខេប** នោះ ដោយផ្ចិតពុម្ពចាហួយចែកគ្នារៀនសូត្រជាច្រើនច្បាប់ ។ មិនយូរប៉ុន្មាន ក៏បានដឹងដល់ក្រសួងធម្មការ. ក្រសួងធម្មការ ក៏បានអោយនិមន្តព្រះគ្រូសង្ឃសត្ថា **ជួន ណាត** មកសាកសួររឿងនេះ ហើយបានបង្គំអោយលោកដើរប្រមូលសៀវភៅ **បាតិមោក្ខសង្ខេប** ទាំងអស់នោះ យកមកប្រគល់ដល់ក្រសួងធម្មការ ។ ក្រសួងធម្មការ បាននិមន្តលោកមកសួរនោះអស់ចំនួន ២. ៣ ថ្ងៃ ដើម្បីរករឿងកំហុស ប៉ុន្តែលោកឆ្លើយបដិសេធថា លោកឥតបានដឹងជាអ្នកណាយកទៅចំលងទេ ។ រឿងនេះមិនយូរប៉ុន្មានក៏ស្ងប់ទៅវិញ ដោយសម្ដេចចក្រីកុញ្ញរាធិបតី **ពេជ ប៉ុន** ជួយធ្វើអន្តរាគម ។

លោក **អ៊ុយ សុន**

នាយកសាលាបឋមសិក្សា ព្រែកកំពឹស

ស្រុកកណ្ដាលស្ទឹង ខេត្តកណ្ដាល

# កុមារីត្រេនសុខនី ទទួលរង្វាន់គំនូរលេខ ១ នៅប្រទេសជប៉ុន

នៅដើមខែសីហា ១៩៩៩ កុមារី ត្រេន សុខនី បានចេញដំណើរទៅប្រទេសជប៉ុន ដើម្បីទទួលរង្វាន់នៅក្រុង យូកូហាម៉ា (Yokohama) ដោយមានអ្នកគ្រូ នួន ចាន់ថា នៅក្នុងអង្គការ ASPECA ជាអ្នកដឹកនាំ ។

កុមារី ត្រេន សុខនី រួមជាមួយកុមារតំណាងអោយប្រទេស ២១ ផ្សេងទៀត បានស្នាក់អាស្រ័យនៅក្រុង យូកូហាម៉ា ហើយនិងបានដើរកំសាន្តនៅទីក្រុងនេះ ។

ខាងក្រោមនេះ ជារូបថតអនុស្សាវរីយ៍ ។



អប់រំ គឺ ជាភារកិច្ចរបស់ យើងទាំងអស់គ្នា

រោងពុម្ព ក្រសួងអប់រំ